ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Mar-2012, 09:23
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៣៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ិត

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្ដម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ច័ន្ទ តារាវស្មី | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្ទាឯល | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ៊្គីសសេ | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការជាបន្តទៅនេះ គឺជាវេទិកាធ្វើសេចក្តីតបរបស់ក្រុមមេធាវីការពារក្តីទាំងបីក្រុមទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ កាលពីម្សិលមិញ មុនពេលចប់កិច្ចពិភាក្សាសវនាការ គឺអង្គជំនុំជម្រះបានជម្រាបទៅក្រុមមេធាវីទាំងបីក្រុមហើយថា មានពេលវេលាសរុបមួយម៉ោងនៅក្នុងការធ្វើសេចក្តីតបនេះ។ ហើយការបែងចែកពេលវេលាអាស្រ័យទៅលើក្រុមមេធាវីទាំងបីក្រុម ហើយប្រសិនបើគ្មានការបែងចែកទេ គឺមេធាវី សម្រាប់មេធាវីក្រុមនីមួយៗមានរយៈពេលម្ភៃនាទី។

សូមអញ្ជើញក្រុមមេធាវីការពារក្តី នួន ជា!

[០៩:០៣:២២]

**លោក អេនទ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីទាំងអស់គ្នា!

ខ្ញុំនឹងថ្លឹងថ្លែងអំពីពេលវេលារបស់ក្រុមយើងខ្ញុំ និងក្រុមអៀង សារី ខ្ញុំត្រូវការប្រហែលជាដប់ទៅដប់ប្រាំនាទីទេ មិនលើសពីនេះទេ។ ខ្ញុំមានដប់ចំណុច ដើម្បីឆ្លើយតបទៅសហព្រះរាជអាជ្ញាជាតិទាក់ទងនឹងចំណុចទូទៅ ដែលគាត់បានលើកឡើងកាលពីថ្ងៃអង្គារ។

ទី១) ខ្ញុំលើកឡើងថា ការលើកឡើងទាំងអស់ពាក់ព័ន្ធទៅនឹងវិធានទី៧ ជាពិសេសវិធាន៨៧(ក) ទាក់ទងទៅនឹងការដាក់ឯកសារក៏ដូចជាវិធាន៨៧(៣)(ឃ)។

ចំណុចទី២ ទាក់ទងទៅនឹង កម្រាស់នៃឯកសារដែលយើងខ្ញុំយល់ឃើញថា ភាគីទាំងអស់ក៏ដូចជាអង្គជំនុំជម្រះមិនមែនតែមេធាវីការពារក្តីទេ គឺថា យើងមានឯកសារដ៏ច្រើនសន្ធឹកសន្ធាប់នៅចំពោះមុខនេះ។ ហើយសហព្រះរាជអាជ្ញា-- គឺចំណុចរបស់ខ្ញុំទាក់ទងទៅនឹងដីកាបំបែកដំណើរការនីតិវិធី គឺខ្ញុំមិនជំទាស់ទៅនឹង-- ទៅៗដែលបានលើកឡើងកាលពីថ្ងៃអង្គារនោះទេ។

[០៩:០៤:៤១]

តាមពិតយើងខ្ញុំទទួលយកថា ដីកាបំបែកដំណើរការនីតិវិធីគឺបានរក្សានូវប្រធានបទទាំងអស់នេះ។ យើងជំទាស់តែនឹងឯកសារទាក់ទងទៅនឹងការអនុវត្តនូវគោលនយោបាយ ក្រៅពីការជម្លៀសប្រជាជនដោយបង្ខំ ដោយសារថា វាមិនពាក់ព័ន្ធទៅនឹងសវនាការនាពេលនេះទេ។ ដីកាបំបែកដំណើរការនីតិវិធី នៅតែជាសេចក្តីសម្រេចដ៏សំខាន់មួយ ដែលកើតចេញពី អ.វ.ត.ក នេះ។ ប៉ុន្តែវាហាក់បីដូចជាទឡ្ហីករណ៍ដែលបានលើកឡើង គឺវាមិនមានការទាក់ទាញយ៉ាងខ្លាំងនោះទេ ទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួមនេះ។ បើនិយាយអំពីគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យនេះ គឺយើងយោងទៅលើឯកសារ D199/2.6/2.5 គឺនិយាយអំពីការអនុវត្តនូវគោលនយោបាយទាំងអស់នេះ។ ដូចដែលឯកសារមួយចំនួនបានលើកឡើងនៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា។

[០៩:០៥:៥៤]

ខ្ញុំគិតថា មិនគ្រប់គ្រាន់ទេ ការដែលគ្រាន់តែលើកឡើងអំពីគោលនយោបាយតែប៉ុណ្ណោះនោះ។ ប៉ុន្តែវាត្រូវមានភស្តុតាងបង្ហាញ ដោយសារថាសហឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវដែលត្រូវមានកម្រិតទូលំទូលាយ។ ហើយក្នុងករណីយើងនេះ គឺថាដីកាបំបែកដំណើរការនីតិវិធី គឺជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានកែប្រែនោះ។ ដោយសារតែវាស្ថិតនៅក្នុងដៃរបស់សហព្រះរាជអាជ្ញា យើងចង់ឃើញ-- ចង់ឲ្យសហព្រះរាជអាជ្ញាបង្ហាញនូវដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ក៏ដូចជានូវដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះ និងក៏ដូចជាដីកាបំបែកដំណើរការនីតិវិធីនេះ។

យើងខ្ញុំយល់ឃើញថា ត្រូវតែមានវិសាលភាពទំហំ ក៏ដូចជាភាពច្បាស់លាស់ឲ្យបានគ្រប់គ្រាន់។ ទាក់ទងនឹងនេះលោក អាប់ឌុលឡាក់ កាលពីថ្ងៃអង្គារលើកឡើងថា មេធាវីការពារក្តី គឺបានដាក់បញ្ជីសាក្សីដែលមិនមានការពាក់ព័ន្ធទៅនឹងសវនាការពីថ្ងៃចន្ទទេ។ ប៉ុន្តែ តើយើងត្រូវធ្វើការជំទាស់ទៅនឹងសាក្សីនៅក្នុងតុលាការនេះតែម្តង ទាក់ទងទៅនឹងការអនុវត្តគោលនយោបាយដែលវាមិនពាក់ព័ន្ធទៅនឹងសវនាការនៅដំណាក់កាលដំបូងនេះទេ។

[០៩:០៧:២៤]

ហើយទាក់ទងទៅនឹងដីកាបំបែកដំណើរការនីតិវិធី យើងខ្ញុំយល់ស្របជាមួយសហព្រះរាជអាជ្ញាថា បរិបទនៃបញ្ហាផ្សេងៗនោះ គឺអាចពាក់ព័ន្ធទៅនឹងដំណាក់កាលក្រោយៗទៀតនៃសវនាការទៅវិញទេ។ ហើយចំណុចទីពីរ គឺទាក់ទងទៅនឹងអំពើនិងសកម្មភាពរបស់ជនជាប់ចោទ ទាក់ទងទៅនឹង

សារណារបស់ ក.ស.ព គឺថាវាអនុវត្តតែចំពោះតែចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ។ យើងខ្ញុំយល់ឃើញថា ចំណុចនេះ គឺថាមិនចំណុចមួយដែលគួរឲ្យចាប់អារម្មណ៍នោះទេ។ ជំហររបស់យើងគឺថា យើងមិនគួរណាអនុវត្តតាមវិធាននៃតុលាការដទៃៗទៀត ដោយ--។ ផ្ទុយទៅវិញ តើយើងត្រូវមើលទៅលើមូលហេតុ ឬក៏សនិទានភាពណាដែលយើងយល់ឃើញថា អនុវត្តមកអាចវាការពារទៅដល់សិទ្ធិរបស់ជនជាប់ចោទ។

[០៩:០៨:២៣]

ហើយក្នុងករណីរបស់ អាយ.ស៊ី.ធី.វ៉ាយ វិធាន៩០ស្ទួន ដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺមូលហេតុដែលលើកឡើងគឺដើម្បីការពារជនជាប់ចោទ ទាក់ទងទៅនឹងភាពគួរឲ្យជឿជាក់បាន ក៏ដូចជាចម្លើយដទៃៗ ដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទ។ ហើយអង្គជំនុំសាលាឧទ្ធរណ៍របស់ អាយ.ស៊ី.ធី.វ៉ាយ នៅក្នុងរឿងក្តីរបស់ ហ្កាលិក គឺលើកឡើងដើម្បីគោលបំណងនៃដំណើរការនីតិវិធី ជាពិសេសគឺបញ្ហាដែលមិនបានច្រានចោលនូវឯកសារដែលជា នូវចម្លើយណាមួយដោយលើកឡើងនូវមូលហេតុដូចគ្នានេះដែរ។ ឧទាហរណ៍ នៅក្នុងសេចក្តីប្រកាសចម្លើយដែលឆ្លើយដាក់ទៅលើជនជាប់ចោទ ដែលថាចម្លើយទាំងអស់នេះ គឺធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ហើយដែលយកមកដាក់មុខអង្គជំនុំជម្រះ។

[០៩:០៩:១៥]

យើងខ្ញុំទទួលស្គាល់ថា ក.ស.ព បានយល់ស្របឯកសារ បើមិនទាំងអស់ទេ គឺភាគច្រើនដែលថាវាស៊ីមានលក្ខណៈស៊ីសង្វាក់គ្នា។ ហើយខ្ញុំមិនចង់ដាក់ឈ្មោះ លើកឡើងពីបញ្ហានេះទៀតនោះទេ ហើយយើងក៏-- យើងខ្ញុំៗចង់សួរតទល់ប្រឈមមុខ។ ដូច្នេះ ខ្ញុំសូមអញ្ជើញឲ្យអង្គជំនុំជម្រះពិនិត្យឲ្យបានដិតដល់ទៅលើឯកសារទាំងអស់នេះ ហើយអង្គជំនុំជម្រះត្រូវតែដាក់ចេញនូវវិធានការណាមួយដែលជាការការពារដល់ផលប្រយោជន៍របស់ជនជាប់ចោទ។

ចំណុចទីបី របស់ខ្ញុំគឺយោងទៅលើដំណើរការនីតិវិធី ដែលថាវាជាសវនាការបំបែកទៅជាខ្នាតតូចៗ។ ភាគីទាំងអស់ ខ្ញុំជឿជាក់ថា នៅក្នុងដំណាក់កាលខ្លះ យើងមានអ្នកធ្វើអត្ថាធិប្បាយ ក៏ដូចសារព័ត៌មាន គឺថា បើខ្ញុំមិនច្រឡំទេ គឺបុគ្គលិក នៃអង្គជំនុំជម្រះ ក៏បានប្រើប្រាស់ដែរ ហើយពីម្សិលមិញពេលព្រឹក គឺសហព្រះរាជអាជ្ញា បានលើកឡើងនូវចំណុចនេះ។ ខ្ញុំគិតថា សវនាការខ្នាតតូចនេះគឺ យើងទទួលយកតែក្នុងករណីសំណុំរឿង០០២/០១ ដែលថា ការប្រតិចារឹក គឺថាបានកត់ត្រាយ៉ាងច្បាស់ថា

វាមានការចម្រូងចម្រាសគ្នាខ្លះ។

[០៩:១០:៥៣]

ក.ស.ព មិនអាចមានចេតនាមកប្រើប្រាស់ឱកាសនេះ នូវអ្វីដែលមេធាវីការពារក្តីបានលើកឡើងនោះ ហើយទាក់ទងនឹងឯកសារប្រឡាក់ប្រឡូស ទៅដោយការធ្វើទារុណកម្មនេះ គឺអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្មបានទទួលស្គាល់ហើយៗ គឺវាជាការជម្រះឲ្យបានដាច់ស្រឡះនូវបញ្ហានេះ ហើយទាក់ទងនឹងបញ្ហានេះ យើងខ្ញុំគ្រាន់តែសូមបញ្ជាក់ថា សហព្រះរាជអាជ្ញាកាលពីម្សិលមិញនោះ គឺយើងខ្ញុំមិនបានលើកឡើងថា គ្រប់ប្រវត្តិរូបទាំងអស់ គឺទទួលបានដោយការធ្វើទារុណកម្មនោះទេ ហើយកាលពីខ្ញុំចាំថា ប្រវត្តិរូបទាំងអស់នេះគឺបានទទួលឡើងដោយការធ្វើទារុណកម្ម ឬគំរាមកំហែង និងធ្វើទារុណកម្មដែលត្រូវបានហាមឃាត់ដោយអនុសញ្ញានេះ។ ដូច្នេះ យើងត្រូវចាត់ទុកថា វាជាចម្លើយសារភាព វាជាចម្លើយសារភាពមួយ។ ហើយទាក់ទងទៅនឹងកំណត់សម្គាល់មុនៗ គឺថា យើងមានជំនឿទុកចិត្តទៅលើអង្គជំនុំជម្រះក្នុងការពិចារណាទាក់ទងទៅនឹងបញ្ហានេះ ដោយអនុវត្តអនុសញ្ញាប្រឆាំងទៅនឹងការធ្វើទារុណកម្មមុននឹងទទួលយកឯកសារណាមួយនោះ។

[០៩:១២:១១]

ចំណុចទីប្រាំ របស់ខ្ញុំទាក់ទងទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ មេធាវីការពារក្តីមិនបានបោះបង់ចោលនូវចំណុចនេះទេ យើងខ្ញុំបានលើកឡើងនូវសារណាផ្ទាល់មាត់រួចហើយ ហើយយើងក៏បានដាក់គឺឯកសារ E1/39.1/1 ដែលបានដាក់ជូនអង្គជំនុំជម្រះហើយ។ ហើយខ្ញុំយល់ស្របថា បើសិនណាជាមិនពេញលេញនោះទេ ក៏យើងបានប្រើប្រាស់ពាក្យនេះដែរ។

ហើយចំណុចទីប្រាំមួយ ទាក់ទងទៅនឹងឈ្មោះរបស់សាក្សី សាក្សីសំខាន់ៗនៅរឿងក្តីនេះគឺថា យើងត្រូវតែវែកញែករវាងសាក្សីទាំងអស់នេះ ដោយមិនបង្ហាញនូវឈ្មោះរបស់ពួកគាត់ទេ ហើយសក្ខីកម្មនេះ គឺថា បានដាក់ជូនមកអង្គជំនុំជម្រះ។ ម៉្យាងវិញទៀត ដូចដែលខ្ញុំបានលើកឡើងគឺថា យើងអាចនឹងលើកឈ្មោះឡើងតែក្នុងករណីដែលបានស្នើសុំឡើងដោយភាគីនោះទេ។ ទាក់ទងទៅនឹងតួនាទីនៃការចូលរួមនេះគឺ អ្នកដែលត្រូវចូលរួមគឺថា យើងតែងតែលើកឈ្មោះឡើង ដូចកាលពីថ្ងៃអង្គារ សហព្រះរាជអាជ្ញា ក៏បានលើកឈ្មោះនោះផងដែរ ចំពោះ ឃើស៊ីងហ៊្វ័រ ដែលគាត់ស្នើសុំឲ្យមកផ្តល់សក្ខីកម្មនោះ។

ប៉ុន្តែនេះមិនមែនគ្រាន់តែចំពោះដែលឈ្មោះរបស់ ឃើស៊ីងហ៊្វ័រ តែប៉ុណ្ណោះទេ ប៉ុន្តែត្រូវឲ្យគាត់មានវត្តមាន ការយើងបានលើកឈ្មោះរបស់គាត់ឡើងនេះ គឺថាជាទូទៅហើយ។ ហើយដូចគ្នានេះ

ផងដែរ គឺសម្រាប់ជនទាំងឡាយ ដែលត្រូវកោះហៅមកជាសាក្សី ក៏យើងអាចនឹងលើកឈ្មោះរបស់គាត់នោះផងដែរ ដូចជា ខ្ញុំលើកឡើង អ៊ុក ប៊ុនឈឿន, មាស មុត, អ៊ឹម ចែម, ហោ ណាំហុង ដែលខ្ញុំលើកឡើងកាលពីថ្ងៃចន្ទ ហើយខ្ញុំនឹង-- ខ្ញុំយល់ឃើញថា អង្គជំនុំជម្រះគឺថា យល់ឃើញថា ក្រុមយើងខ្ញុំនឹងចង់ស្តាប់ចម្លើយរបស់អ្នកទាំងអស់នេះ។

ចំណុចទីប្រាំពីរ គឺសង្ខេបទេ ទាក់ទងទៅនឹងការថតសំឡេង និងខ្សែអាត់ គឺដូចសហព្រះរាជអាជ្ញា លីសាក់ បានលើកឡើងកាលពីម្សិលមិញ។ ខ្ញុំសូមកែប្រែ ខ្ញុំនិយាយអំពីអ្នកផលិត នូវខ្សែវីដេអូ ឬក៏ការថតសំឡេងទាំងអស់នេះ ពាក់ព័ន្ធទៅនឹងជនជាប់ចោទ។

ចំណុចទីប្រាំបី គឺទាក់ទងទៅនឹងសហចៅក្រមស៊ើបសង្កេត។ អ្នកសង្កេតការណ៍អព្យាក្រឹតទាំងឡាយ គឺនឹងសន្និដ្ឋានថា ការិយាល័យសហចៅក្រមស៊ើបអង្កេតនេះ គឺជាស្ថាប័នមួយដែលមានលក្ខណៈលម្អៀង រួមទាំងបុគ្គលិករបស់ការិយាល័យនេះផងដែរ ជាពិសេសទាក់ទងទៅនឹងការពិនិត្យពិច័យទៅលើកិច្ចការរបស់សហចៅក្រមស៊ើបអង្កេត គឺថាត្រូវតែពិនិត្យឡើងវិញឲ្យបានល្អិតល្អន់។ បើសិនណាជាសហការីរបស់ខ្ញុំគាត់មានអ្វីត្រូវបន្ថែមសូមអញ្ជើញ។ ខ្ញុំសូមចប់តែប៉ុណ្ណេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តសូមអញ្ជើញក្រុមមេធាវីការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរអស់លោក លោកស្រីទាំងអស់នៅក្នុងបន្ទប់សវនាការ។ ខ្ញុំមានចំណុចច្រើនណាស់ ប៉ុន្តែខ្ញុំព្យាយាមនិយាយឲ្យបានយឺត។

ដំបូងខ្ញុំសូមចាប់ផ្តើមជាមួយនឹងអ្វី ដែលសហព្រះរាជអាជ្ញា លីសាក់ បានលើកឡើងកាលពីព្រឹកម្សិលមិញ ទាក់ទងទៅនឹងឯកសារពីរ គឺឯកសារមួយ គឺសេចក្តីដកស្រង់មួយត្រូវគឺត្រូវបានយកមកប្រើប្រាស់ មានលេខ ERN ដែលជាផ្នែកមួយនៃឯកសារដដែល ឬក៏សម្រង់ឯកសារដែលយកឯកសារបីផ្សេងទៀតយកមកដាក់បញ្ចូល។ ចំណុចនេះហើយដែលធ្វើឲ្យយើងខ្ញុំមានការច្របូកច្របល់។ ខ្ញុំសូមអធ្យាស្រ័យចំពោះសហព្រះរាជអាជ្ញា ដែលថានៅពេលណាឯកសារមួយមានលេខឯកសារច្រើន យកលេខឯកសារដទៃទៀតយកមកយោងច្រើន ហើយមកដាក់ចូលនៅក្នុងសំណុំរឿង។ ខ្ញុំគិតថា ការធ្វើបែបនេះគឺមិនមានលក្ខណៈត្រឹមត្រូវទេ គួរតែដាក់វា-- លេខវាផ្សេងគ្នា ដើម្បីចៀសវាងកុំឲ្យមានការច្រឡំច្របូកច្របល់ ដោយយើងយោងទៅលេខ ERN។

[០៩:១៧:២៧]

ទាក់ទងទៅនឹងឯកសារមួយ ឯកសារ IS3.5 យើងខ្ញុំកត់សម្គាល់ឃើញថា នេះពាក់ព័ន្ធទៅនឹងប្រវត្តិរូប ដែលមានពាក់ព័ន្ធទៅនឹងរូបថតមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ នេះក៏ជាឯកសារមួយធ្វើឲ្យមានការច្រឡូកច្របល់ដែរ។ ដូច្នេះយើងខ្ញុំសូមអធ្យាស្រ័យទៅដល់សហព្រះរាជអាជ្ញា ហើយសុំឲ្យអង្គជំនុំជម្រះមេត្តាពិនិត្យពិច័យឲ្យបានហ្មត់ចត់ទៅលើចំណុចបែបនេះ។

ហើយចំណុចមួយទៀត ម្សិលមិញលោក លីសាក់ បានលើកឡើងនូវទឡ្ហីករណ៍នូវចំណុចមួយ ហើយបន្ទាប់មកបានអញ្ជើញឲ្យអង្គជំនុំជម្រះ ទទួលយកនូវការយល់ឃើញទៅលើអង្គហេតុនៅក្នុងសំណុំរឿង០០១មកដាក់ចូលក្នុងសំណុំរឿងនេះ។ លោក លោកស្រីចៅក្រមបានស្តាប់ចម្លើយរបស់ ឌុច ហើយថានេះគឺជាអ្វីដែលបានកើតឡើង។

[០៩:១៨:៤០]

ហើយទាក់ទងទៅនឹងការសម្រេចវិនិច្ឆ័យទៅលើអង្គហេតុនេះគឺ លោក លោកស្រីចៅក្រមប្រហែលជានៅចងចាំហើយថា ការស្តាប់ចម្លើយភស្តុតាងនៅក្នុងសំណុំរឿង០០១ យើងមិនចង់ស្តាប់ចម្លើយនេះដដែលទៀតនៅក្នុងសំណុំរឿង០០២ទេ។ យើងខ្ញុំបានដាក់សំណើសុំហើយ គឺសំណើសុំរបស់ក្រុម អៀង ធីរិទ្ធ យើងខ្ញុំបានដាក់បន្តបន្ទាប់។

អង្គជំនុំជម្រះបានចេញនូវសេចក្តីសម្រេចរួចហើយ ប៉ុន្តែយើងខ្ញុំគឺថាមានចំណាប់អារម្មណ៍មួយ គឺថាអង្គជំនុំជម្រះ គឺចង់ឲ្យយើងស្តាប់-- ចង់ស្តាប់ភស្តុតាងនេះឡើងវិញជាថ្មី ហើយសហព្រះរាជអាជ្ញាបានមើលទៅលោក លោកស្រី អង្គជំនុំជម្រះ។ លោក លោកស្រី អង្គជំនុំជម្រះបានដឹងហើយក្នុងសំណុំរឿង០០១ នេះគឺជាអង្គហេតុមួយដែលបានអះអាងច្បាស់លាស់ហើយ។ នេះខ្ញុំបានស្តាប់មកពីលោក លីសាក់ កាលពីម្សិលមិញ។ គាត់មិនបានលើកឡើងច្រើនណាស់ណានោះទេ ក៏ប៉ុន្តែខ្ញុំនឹងពន្យល់ពាក្យនេះនៅពេលក្រោយ។

ខ្ញុំនិយាយអំពីប្រតិចារឹកនៃសក្ខីកម្មដែលបានផ្តល់នោះ។ គឺថាសហព្រះរាជអាជ្ញានិយាយថា នេះជាប្រព័ន្ធច្បាប់ស៊ីវិល គឺថាស្តាប់ជាថ្មីទាក់ទងទៅនឹងភាពនៃអាចទទួលយកបាននេះ។

[០៩:២០:១២]

លោក លោកស្រីចៅក្រម ជាចៅក្រមវិជ្ជាជីវៈ ការិយាល័យសហចៅក្រមស៊ើបអង្កេតថា គឺថាខ្ញុំយល់ស្របជាមួយក្រុម នួន ជា ថា ស្ថាប័ន ជាស្ថាប័នលម្អៀង ចៅក្រម ឡឺម៉ុងដ៍ គឺថាគាត់ស្វែងរកតែ

ភស្តុតាងដាក់បន្ទុកទេ គាត់មិនរកភស្តុតាងដោះបន្ទុកទេ ហើយគាត់បែរជាច្រានចោលនូវភស្តុតាងដោះបន្ទុកទៅវិញ។ ដូច្នេះ នេះជាសកម្មភាពរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយអ្វីដែលសហព្រះរាជអាជ្ញាបានរៀបចំឡើង ហើយនៅពេលដែលយើងជ្រើសរើសបុគ្គលិកពីការិយាល័យសហព្រះរាជអាជ្ញាទៅធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត នោះវានឹងបង្ហាញឱ្យឃើញហើយថាតើភាពលម្អៀង វាមានលក្ខណៈប៉ុនណានៅក្នុងករណីនេះ? សូម្បីតែសហចៅក្រមស៊ើបអង្កេតក៏បានសារភាពថា គាត់-- ចំពោះខ្លួនគាត់គឺថាគាត់នៅអព្យាក្រឹតហើយ ក៏ប៉ុន្តែបុគ្គលិករបស់គាត់អាចរឿងផ្សេងដែលគាត់ជាអ្នកចុះទៅតាមទីតាំងផ្សេងៗតែម្តង ដើម្បីយកចម្លើយមកនោះ។

ខ្ញុំសូមរំឭកដល់អស់លោក លោកស្រីទាំងអស់គ្នា គឺថាយើងមិនមែននៅស្រុកបារាំងទេ ដែលបណ្តុះបណ្តាលមន្ត្រីយុត្តិធម៌ដើម្បីស៊ើបអង្កេតជំនួសចៅក្រមស៊ើបអង្កេតនោះ នៅក្នុងព្រឹត្តិការណ៍ណាមួយដែលវាកើតឡើងនៅក្នុងតំបន់ណាមួយដែលដាច់ស្រយាលដូច្នេះហើយ។ យើងបានធ្វើការស៊ើបអង្កេតនៅទូទាំងពិភពលោកនេះ គឺថាមានចរិតលក្ខណៈនៃការស៊ើបអង្កេតខុសគ្នាៗ ដែលខ្ញុំនៅតែរក្សាថាស្ថាប័ននេះ ជាស្ថាប័នមួយដែលមិនមានអព្យាក្រឹតភាពទេ។

[០៩:២១:៤៨]

សហព្រះរាជអាជ្ញាបានលើកហើយថា នេះគឺជាសហឧក្រិដ្ឋកម្មរួម។ ជាការពិតហើយ មេធាវីការពារក្តី គឺយើងចង់ស្តាប់នូវភស្តុតាង គឺថាយើងចង់សាងសង់របងមួយ គឺដើម្បីការពារករណីនេះឱ្យបានរឹងមាំ។ យើងខ្ញុំមិនបានដាក់ពាក្យសុំណាមួយ ខ្ញុំយល់ស្របទៅលើចំណុចនេះ។ នៅក្នុងការបំបែកដំណើរការនីតិវិធី គឺបំបែករឿងនេះទៅជា-- ភាគីទាំងអស់មានចំណាប់អារម្មណ៍ក្នុងការពិចារណាទៅលើចំណុចទាំងអស់នេះ។ ប្រសិនជាអង្គជំនុំជម្រះ--

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន! លោកមេធាវីញាប់ពេក អ្នកបកប្រែពិបាកនឹងតាម។

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

លោក--

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសលោកប្រធាន! ខ្ញុំព្យាយាមនឹងនិយាយឱ្យបានយឺតជាងនេះ។ ខ្ញុំសូមចាប់ផ្តើម

ឡើងវិញ ហើយយឺតទេ។

លោក លោកស្រីចៅក្រម ខ្ញុំសូមអញ្ជើញឲ្យលោក លោកស្រីចៅក្រមមើលទៅដីកាបំបែកដំណើរការនីតិវិធី ជាពិសេសកថាខណ្ឌ៦, ៧, ៨ ទាក់ទងទៅនឹងសេចក្តីណែនាំចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ វាក៏ទាក់ទងមកដល់យើងខ្ញុំនោះផងដែរ ហើយនៅក្នុងសេចក្តីសម្រេចនេះ នៅក្នុងដីកាបំបែកដំណើរការនីតិវិធី ដែលចុះថ្ងៃទី២២ ខែកញ្ញា ២០១១ នៅក្នុងកថាខណ្ឌ៨ គឺថាសាក្សីមួយចំនួន ក៏ដូចជាអ្នកជំនាញដែលត្រូវកោះហៅនោះ គឺត្រូវតែមានកម្រិត ជាពិសេសអ្នកដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងសវនាការក្នុងវគ្គដំបូងនេះ ដើម្បីបង្កលក្ខណៈឲ្យអង្គជំនុំជម្រះចេញនូវសេចក្តីសម្រេចបន្ទាប់ពីសវនាការដំណាក់កាលដំបូងនេះ។

[០៩:២៤:១៧]

នៅក្នុងសេចក្តីសម្រេចប្រើពាក្យថា "សវនាការខ្លីមួយ ដើម្បីធានាទៅដល់សិទ្ធិជាសារវន្ត ផលប្រយោជន៍ជាសារវន្តរបស់ជនរងគ្រោះ ក៏ដូចជាជនជាប់ចោទ"។ ប៉ុន្តែខ្ញុំគិតថា នៅពេលដែលអង្គជំនុំជម្រះប្រើពាក្យថា ត្រូវកោះហៅសាក្សីដោយមានកម្រិតនេះ គឺវាពាក់ព័ន្ធតែទៅនឹងសំណុំរឿង០០២/០១ សហព្រះរាជអាជ្ញាបាននិយាយថា នៅក្នុងឧបសម្ព័ន្ធនេះ គឺថាសម្រាប់រឿងទាំងមូលនេះ គឺថាឧបសម្ព័ន្ធសម្រាប់រឿង សំណុំរឿងនេះទាំងមូល។

នៅពេលដែលអង្គជំនុំជម្រះបានសម្រេចថា សហព្រះរាជអាជ្ញាធ្វើបំពេញកាតព្វកិច្ចរបស់ខ្លួនដោយពិនិត្យមើលទៅលើឧបសម្ព័ន្ធ និងធ្វើការកែប្រែ។ តើបានកែប្រែទេ? អត់បានកែប្រែទេ។ ពីម្សិលមិញសហព្រះរាជអាជ្ញា លីសាក់ បានលើកឡើងហើយ ដោយនិយាយអំពីខ្សែវីដេអូដែលមានជាប់ពាក់-- មិនជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/១ នោះទេ។ អ៊ីចឹងបានថា ហេតុអ្វីបានយកមកដាក់នៅក្នុង ព្រឹត្តិការណ៍នោះមកដាក់ក្នុងករណីនេះ?

យើងខ្ញុំចង់ជួយទៅដល់អង្គជំនុំជម្រះ ក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបំបែកដំណើរការនីតិវិធីនេះ។ ការបំបែកនេះ គឺគោលបំណងមិនមែនដើម្បីកាត់ចោលនូវផ្នែកណាមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ គឺសំណុំរឿង០០២/០១ គឺធ្វើឡើងដើម្បីឲ្យវាមានលក្ខណៈគ្រប់គ្រងទៅបាន។ ខ្ញុំថាមិនអាចគ្រប់គ្រងបានទេ បើធ្វើបែបនេះ។ បើសិនណាជាមានការចេះតែទទួលយកឯកសារ យកមកដាក់ហើយ ដោយមិនមានការពិនិត្យវាពិច័យ និងពិភាក្សាទៅលើឯកសារនោះទេ ហើយសំណើរបស់ខ្ញុំៗសូមដកស្រង់នូវផ្នែកពាក់ព័ន្ធ។

[០៩:២៦:២៩]

ខ្ញុំសូមចូលទៅសំណើរបស់ខ្ញុំដែលមានការពាក់ព័ន្ធទៅចំណុចនេះ។ នេះគឺបាន ដែលយើងខ្ញុំបាន ដាក់ក្នុងនាមឲ្យក្រុមការពារក្តី អៀង សារី គឺពាក់ព័ន្ធទៅនឹងប្រភេទឯកសារផ្សេងៗ ចុះថ្ងៃទី២០ ខែកញ្ញា ២០១១ E114 កថាខណ្ឌ១១។ គឺផ្នែកជាប់ពាក់ព័ន្ធ ភាពជាប់ពាក់ព័ន្ធ សូមដកស្រង់៖ “គឺ ភស្តុតាងដែលអាចបង្ហាញនូវភស្តុតាងនេះ មានន័យថាភស្តុតាងពាក់ព័ន្ធ ភស្តុតាងអាចពាក់ព័ន្ធប្រសិន ណាភស្តុតាងនោះអាចមានតម្លៃភរនីយហេតុរបស់តិច ឬក៏ច្រើន។ មានន័យថា អាចបង្ហាញទៅដល់ ពិរុទ្ធភាព ឬបង្ហាញថាគ្មានពិរុទ្ធភាព” ហើយចៅក្រម ចាមូឌីន (Shahabuddeen)ដែលនៅជំនួយសាលា ឧទ្ធរណ៍ នៅក្នុងអង្គជំនុំ-- នៅអង្គជំនុំជម្រះសាលាឧទ្ធរណ៍ អាយ.ស៊ី.ធី.វ៉ាយ ថាភស្តុតាងអាចទទួល យកបាន គឺភស្តុតាងដែលត្រូវបង្ហាញនូវសច្ចភាព ដែលត្រូវបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ មិនមែន គ្រាន់តែពាក់ព័ន្ធ ហើយត្រូវច្រានចោលនោះទេ ត្រូវតែមានភាពពាក់ព័ន្ធ។ ដូច្នេះសហព្រះរាជអាជ្ញា អន្តរជាតិលើកឡើង បញ្ជាក់ឲ្យឃើញថា មេធាវីការពារក្តី អៀង សារី បានដាក់សារណាជំទាស់ ហើយដោយសារតែគាត់ទទួលបាននូវការលើកលែងទោសអីដូច្នេះ។ ខ្ញុំសូមពន្យល់ទៅលើបញ្ហានេះ។ ដូច្នេះយើងទាំងអស់គ្នាអាចនឹងយល់ទៅលើបញ្ហានេះ ជាពិសេសគឺខាងភាគីសហព្រះរាជអាជ្ញាតែម្តង។ ហេតុអ្វីវាពាក់ព័ន្ធទៅនឹងសំណុំរឿងនេះ? លោក អៀង សារី ជាការពិតបានទទួលការលើកលែងទោស ពីព្រះមហាក្សត្រហើយ ទោះវាអនុវត្តបាន ឬអនុវត្តមិនបាននៅចំពោះស្ថាប័ននេះក៏ដោយ។ ថាតើនេះ ពាក់ព័ន្ធឬក៏អត់? មិនទាន់ទេ។ តើវាមានសារប្រយោជន៍ ឬក៏ម៉េច?

[០៩:២៨:៤៥]

នៅក្នុងករណីនេះ គឺដូច្នេះយើងខ្ញុំយល់ហើយថា តើខ្ញុំយកចិត្តទុកដាក់ តើយើងទាំងអស់គ្នាថា ភស្តុតាងបែបនេះត្រូវទទួលយកឬក៏អត់នោះ? សម្រាប់យើងខ្ញុំមានន័យថា មិនមានន័យនោះទេ។ ខ្ញុំ គ្រាន់តែលើកចំណុចនេះសម្រាប់ជាឧទាហរណ៍មួយ។ ឧទាហរណ៍ថា យើងបាន ដីកាចាត់ឲ្យស៊ើបសួរ ជំនួស យើងជាអ្នកស៊ើបអង្កេត អ៊ិច, វ៉ាយ, ហ្សែត ជាដើមនេះ បានចាប់ខ្លួន អៀង សារី, នួន ជា អីជា ដើម។ល។ តើវាសំខាន់ ចំណុចនេះសំខាន់ស្អី? ការចាប់ខ្លួនវាមានសារៈសំខាន់អី? ខ្ញុំសួរថា ហេតុអ្វីម៉េច ក៏មិនចំណាយពេលវេលា ដើម្បីសម្រួលទៅដល់ឧបសម្ព័ន្ធរបស់ខ្លួនដាក់ចូលទៅក្នុងសំណុំរឿងដែល ពាក់ព័ន្ធនៅក្នុងសវនាការនៃផ្នែកនេះតែម្តង?

[០៩:២៩:៣៧]

ដូច្នេះ ខ្ញុំសូមលើកឡើងថា គឺចង់-- គាត់ចង់បានដាក់អ្វីពីសំណុំរឿង០០១ ចូលមកតែម្តង។ ដែលគាត់បានលើកឡើងថាដូច្នេះ។ វាមានសារៈសំខាន់ណាស់សម្រាប់បញ្ហាផ្សេងៗទៀត ក៏ប៉ុន្តែសម្រាប់ករណីនេះ គឺវារឿងមួយផ្សេង។ នេះគឺអ្វីដែលគាត់បានលើកឡើង បានទទួលស្គាល់ជាលាយលក្ខណ៍អក្សររបស់គាត់នេះ។ យើងខ្ញុំបាននិយាយថា ដើម្បីឲ្យចាត់ចែងដំណើរការនីតិវិធីបានងាយស្រួលនោះ គឺយើងត្រូវទទួលយកតែព័ត៌មានទាំងឡាយណា ដែលពាក់ព័ន្ធទៅនឹងសំណុំរឿងនេះតែម្តង ផ្នែកនៃសំណុំរឿងនេះតែម្តង។ ដើម្បីការពារកុំឲ្យសហព្រះរាជអាជ្ញាចេះតែយកអ្វីមកដាក់ចូលទៅក្នុងសំណុំរឿងនេះ។

លោក លោកស្រីចៅក្រម គឺជាចៅក្រមដែលធ្វើការវិនិច្ឆ័យទៅលើដំណើរការក្តីនេះ។ ខ្ញុំសូមបន្តទៅមុខទៀត លោក លោកស្រីចៅក្រមជាទីគោរព។ ចូលទៅដល់ចំណុចមួយទៀតពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈរបស់ចៅក្រម ដោយសារតែខ្ញុំគិតថា នៅពេលដែលខ្ញុំទៅទីក្រុងឡាអេ ឆ្នាំ២០០១ គឺខ្ញុំយល់អំពីបញ្ហាវិជ្ជាជីវៈ។

[០៩:៣០:៥៤]

ខ្ញុំមកពីប្រទេសដែលមានចៅក្រមមានវិជ្ជាជីវៈ។ ដូច្នេះហើយ វាត្រូវឲ្យខ្ញុំគិតបន្តិចបន្តួចដើម្បីពិចារណាទៅលើបញ្ហានេះ។ ខ្ញុំឃើញតែចៅក្រមដែលជាអ្នកការទូត និងជាអ្នកសិក្សាស្រាវជ្រាវ ហើយពួកគាត់ពេលខ្លះទៅមិនចេញមកពីវិជ្ជាជីវៈរបស់ខ្លួន ហើយមកចូលខ្លួនជាចៅក្រមបន្ទាប់ពីខ្លួនជាសហព្រះរាជអាជ្ញា ឬក៏មេធាវីនោះទេ។ ពួកគាត់ភាគច្រើនឃើញជាអ្នកការទូត ឬក៏ជាអ្នកដែលធ្វើការងារផ្សេង។ ដូច្នេះ ខ្ញុំដឹងថាចៅក្រមមិនមែនថាអ្នកដែលគ្រាន់តែមានចំណេះដឹងនោះទេ គាត់ត្រូវតែអ្នកមានចំណេះដឹងធ្វើការពិនិត្យភស្តុតាង បំបែកថា តើភស្តុតាងណាទទួលបាន ភស្តុតាងណាមិនអាចទទួលយកបាន? ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមើលប្រតិចារឹកនៅក្នុងរឿងក្តីថ្មីៗមួយនៅ អាយ.ស៊ី.ធី.វ៉ាយ។ ដោយសារតែនៅពេលសហព្រះរាជអាជ្ញាមើលទៅលើ អាយ.ស៊ី.ធី.វ៉ាយ នោះ គឺកន្លែងដែលច្បាប់ដែលគេថាច្បាប់ គេដកចេញមកពីទីនោះទាំងអស់។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមើលប្រតិចារឹកពីរឿង *ខាឌី-- ហាឌីណាយ៉ា* នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០១ ប្រតិចារឹក គឺរឿងក្តីរវាងសហព្រះរាជអាជ្ញាទល់នឹង រ៉ាមូស ហារ៉ាឌីណា។ ខ្ញុំសូមប្រកប R-A-M-U-S-H នាមត្រកូល H-A-R-A-D-I-N-A-J រឿងក្តីនោះមានលេខ IT-04-84 ស្ទួន-T។ បាទ អក្សរតេ “T” នេះគឺសំដៅលើការជំនុំជម្រះសាលាដំបូង។

[០៩:៣២:៥៤]

នៅក្នុងរឿងក្តីមួយនេះ សហព្រះរាជអាជ្ញាគឺគាត់ធ្លាប់ធ្វើសេចក្តីសន្និដ្ឋានបើករបស់គាត់ ហើយ

យោងទៅលើសៀវភៅមួយចំនួន។ ខ្ញុំមើលទៅលើទំព័រ២២៤ នេះគឺអ្វីដែលចៅក្រមម៉ូឡូតូ មកពីអាហ្វ្រិកខាងត្បូង គាត់គឺជាមេធាវីមួយរូបតាំងពីឆ្នាំ១៩៧៨ ហើយគាត់ធ្វើជាចៅក្រមនៅអាហ្វ្រិកខាងត្បូង ហើយគាត់ធ្វើជាចៅក្រម អាយ.ស៊ី.ធី.វ៉ាយ តាំងពីឆ្នាំ២០០៥។ គាត់បានលើកឡើងថា "ខ្ញុំសូមធ្វើអត្ថាធិប្បាយទៅទៅមួយ ខ្ញុំយល់ថាសេចក្តីសន្និដ្ឋានបើកវាស្ទើរតែប៉ះពាល់ទៅដល់សក្ខីកម្មហើយនិងស្ទើរតែបង្ហាញភស្តុតាង ដែលមិនបានកំណត់សម្គាល់ថាជាភស្តុតាង ប៉ុន្តែឯកសារទាំងអស់នេះធ្វើឱ្យចៅក្រមអង្គជំនុំជម្រះពិចារណា"។ ហើយនៅក្នុងពេលនេះយើងមិនឃើញមានការវិវាទអំពីយថាភាពនិងប្រភពភាពពាក់ព័ន្ធនៃសៀវភៅដែលលោក លោកស្រីនឹងយោងទៅដល់នោះ អង្គជំនុំជម្រះគិតថាចាំបាច់ត្រូវអនុវត្តវិធាននៃការទទួលយកភស្តុតាងមុនពេលដែលអនុញ្ញាតឱ្យលោក លោកស្រីបន្តលើកឡើងអំពីបញ្ហានេះ។

[០៩:៣៤:១២]

នៅពេលនេះ ខ្ញុំនិយាយអំពីទំព័រ២២៥ អ្នកត្រូវតែផ្តល់យថាភាព ត្រូវតែនាំសាក្សីមកនិយាយថាតើអ្នកណាជាអ្នកនិពន្ធសៀវភៅ? លក្ខខណ្ឌទាំងអស់ត្រូវតែបំពេញចំពោះការទទួលយកបាននៃសៀវភៅ។ ដោយសារ-- ហេតុដូច្នេះហើយ អង្គជំនុំជម្រះមិនអាចទទួលយកថា អ្នកតែងតែលើកឡើងថាត្រូវតែដកសៀវភៅនេះចេញនៅពេលក្រោយ។ សៀវភៅនេះ គឺយើងត្រូវពិចារណាហើយគោលបំណងនៃការទទួលយកសៀវភៅទាំងអស់នេះ គឺដើម្បីកុំឱ្យអង្គជំនុំជម្រះទទួលយក-- ទទួលឥទ្ធិពលទៅលើអ្វីដែលយើងលើកឡើងចំពោះការច្រានចោលនេះ។ លោក រ៉ូជឺ គាត់បាននិយាយឆ្លើយតបទៅវិញនៅក្នុងជួរទី១១ នៃទំព័រដដែលនៅក្នុងសាលាក្តីអន្តរជាតិ។

លោក លោកស្រីចៅក្រម ជាចៅក្រមមានវិជ្ជាជីវៈ ដែលអាចៗមិនពិបាកទទួលឥទ្ធិពលនូវការលើកឡើងដែលវាអាច ឬក៏មិនអាចឱ្យពិចារណាទៅលើការទទួលយកឯកសារទាំងអស់នេះ។ ឯកសារទាំងអស់នេះ ទោះបីជាមិនពេញចិត្ត ឬក៏ពេញចិត្តក៏ដោយត្រូវតែយកមកពិចារណា។ នៅក្នុងទំព័របន្ទាប់ទៀត ទំព័រ២២៦ នេះជាអ្វីដែលចៅក្រម ម៉ូឡូតូ ឆ្លើយតប ដែលគាត់ជាចៅក្រមវិជ្ជាជីវៈ។ នៅក្នុងទំព័រ២២៦ ត្រង់ជួរ១៥ លោក លោកស្រីទាំងអស់មានហើយប្រតិចារឹកនេះ ដូច្នេះអាចមើលតាមបាន។ ខ្ញុំសូមអភ័យទោស ចំពោះអ្នកដែលគាត់មិនអាចជាភាសាអង់គ្លេសបាន។ នេះគឺជាអ្វីដែលខ្ញុំអាចធ្វើទៅបានដោយផ្តល់ជាឯកសារនេះតែប៉ុណ្ណោះ។

[០៩:៣៦:១២]

ខ្ញុំសូមផ្តល់យោបល់មួយចំនួនជាបឋម ខ្ញុំគ្រាន់តែចង់លើកឡើងថា ខ្ញុំទទួលស្គាល់ថាអង្គជំនុំជម្រះមានចៅក្រមវិជ្ជាជីវៈដែលអាចពិចារណាអំពីបញ្ហាដែលមិនពាក់ព័ន្ធ ក៏ប៉ុន្តែអង្គជំនុំជម្រះ គឺជាមនុស្សដូចគ្នា។ ហើយលោក លោកស្រីនឹងដឹងហើយថា នៅក្នុងសេចក្តីណែនាំដែលយើងបានផ្តល់ជូនបញ្ហានៃឯកសារ អ៊ុម.អេហ្វ.អាយ គឺត្រូវបានហាមឃាត់យ៉ាងច្បាស់លាស់ ដោយសារហេតុផលនេះ។ ប្រសិនបើ អស់លោក លោកស្រីចង់យកឯកសារមួយ លោក លោកស្រីត្រូវតែឲ្យយើងខ្ញុំជឿទៅលើខ្លឹមសាររបស់វា។ ដូច្នេះបានន័យថា ប្រសិនបើឯកសារមួយយកមកដាក់នោះ គឺយើងត្រូវតែយកមកគិតសិន នេះគឺជាទឡ្ហីករណ៍ដែលគេបានលើកឡើង។

ប្រសិនបើយើងចង់យកឯកសារ១៥០ នៅក្នុងរឿង-- ដាក់បញ្ចូលក្នុងរឿងក្តីរបស់យើងនៅទីនេះ វានឹងពិបាកណាស់សម្រាប់អង្គជំនុំជម្រះ គឺមនុស្សមិនអាចធ្វើបាននោះទេ។ ដូច្នេះហើយអង្គជំនុំជម្រះមានបំណងទុកឯកសារត្រឹមកម្រិតអប្បបរមា ចំពោះឯកសារទាំងឡាយណាដែលនឹងអាចច្រានចោលនៅពេលក្រោយ។ ដូច្នេះហើយចៅក្រមវិជ្ជាជីវៈគឺមិនមែនថាទទួលយកឯកសារទាំងអស់នោះទេ។ នៅទីនេះ គឺយើងខ្ញុំសូមលើកឡើងដូចគ្នា យើងមិនមែនលើកឡើងថាចៅក្រមនៅទីនេះមិនមានសមត្ថភាពនោះទេ។ យើងខ្ញុំសូមលើកឡើងថា យើងអាចឃើញថាឯកសារទាំងអស់នេះ វាអាចមកជាប់ជាមួយនឹង -- យកមកដាក់ជាមួយនឹងសាក្សី ហើយយើងស្តាប់សក្ខីកម្ម។ ដូច្នេះចំណុចនេះ គឺវាតាមអ្វីដែលខ្ញុំដឹងពីតុលាការ អាយ.ស៊ី.ធី.វ៉ាយ។

[០៩:៣៨:២២]

ការលើកឡើងរបស់ខ្ញុំពាក់ព័ន្ធទៅនឹងលិខិតចាត់ឲ្យសួរជំនួស ដីកាចាត់ឲ្យស៊ើបសួរជំនួស។ គឺ D9/-- D9.1/30 នេះគឺថាយើងមានសេចក្តីសង្ខេបចេញមកពីអ្នកស៊ើបអង្កេតដែលពួកគាត់បានស្តាប់សាក្សី ឡុង នរិន្ទ។ សាក្សី ឡុង នរិន្ទ បានមកផ្តល់សក្ខីកម្មរួចហើយ។ ហេតុអ្វីបានជាចាំបាច់? គាត់ត្រូវមកផ្តល់សក្ខីកម្ម។ សក្ខីកម្មគឺជាភស្តុតាង។ ហេតុអ្វីវាជាភស្តុតាង?

[០៩:៣៩:០៥]

វាគឺជាភស្តុតាងដែលស្នើថា ជាភស្តុតាងបន្ថែមក៏ប៉ុន្តែស្របទៅនឹងចំណុចហ្នឹងយើងក៏ឃើញមានសេចក្តីសង្ខេបសាក្សីមួយទៀត គឺមិនមែនត្រឹមតែជាសេចក្តីសង្ខេបប៉ុណ្ណោះទេ។ វាបានបែងចែកការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ខ្សែចង្វាក់នៃការទទួលខុសត្រូវ ការអប់រំបញ្ញាជន...។ល។

ដូច្នេះថា តើសាក្សីរូបនោះមកផ្តល់សក្ខីកម្មដែរឬទេ? ហើយប្រសិនបើអ៊ីចឹងមែន ហេតុអ្វីបានជា

យើងត្រូវការ? ប្រសិនបើមិនដូច្នេះទេ គឺវានឹងក្លាយទៅជាចម្លើយរបស់សាក្សី។ សាក្សី-- សហព្រះរាជអាជ្ញាលើកឡើងហើយថា សាក្សីនេះបានមកផ្តល់ចម្លើយដោយមានការសម្បថ ដូច្នេះហើយយើងត្រូវតែធ្វើការដេញដោលទៅលើសាក្សីរូបនេះ។

យើងខ្ញុំសូមលើកឡើងថា ប្រសិនបើសាក្សីមិនមកផ្តល់សក្ខីកម្មនោះទេ ហើយសហព្រះរាជអាជ្ញាចាំបាច់ព័ត៌មានទាំងអស់នេះ ដោយសារតែយើងខ្ញុំសង្ស័យទៅលើព័ត៌មានទាំងអស់នេះ យើងមិនអាចបង្ហាញរឿងក្តីនោះទេ។ ដូច្នេះហើយយើងខ្ញុំនឹងធ្វើសំណើនាពេលក្រោយ។ ប៉ុន្តែនៅពេលនេះវាហាក់ដូចជាលឿនពេក។ នេះគឺជាវិធីសាស្ត្ររបស់យើងខ្ញុំដែលបានលើកឡើង យើងមិនមែនសុំដកចេញគ្រប់ឯកសារទាំងអស់នោះទេ។

[០៩:៤០:២៩]

យើងខ្ញុំសូមចូលទៅដល់ប្រតិចារឹកមួយទៀត លោក លោកស្រីចៅក្រម ដោយសារតែយើងខ្ញុំជិតអស់ពេលវេលា ខ្ញុំគិតថា ខ្ញុំត្រូវការពេលវេលាច្រើនជាងនេះ។ ខ្ញុំបានផ្តល់ជូនភាគីទាំងអស់គ្នាហើយរួមទាំងចៅក្រមផងដែរ។ សហសេវិករបស់ខ្ញុំ គឺបានលើកឡើងថា ខ្ញុំគួរតែសុំការអនុញ្ញាតមុនពេលដែលខ្ញុំចូលទៅឯកសារនេះ និងផ្តល់ជូនឯកសារនេះ។ ខ្ញុំសូមអភ័យទោស យើងគួរតែសុំការអនុញ្ញាតជាមុនយើងបានផ្តល់ជូនឯកសារនេះរួចទៅហើយទៅដល់ដល់តុលាការ។ ហេតុផលដែលខ្ញុំប្រើប្រាស់ និងយោងទៅលើឯកសារជាក្រដាសនេះ ដោយសារតែវាពិបាកក្នុងការអានតាម ប្រសិនបើមិនមានឯកសារជាក្រដាសនោះទេ។

[០៩:៤១:២០]

រឿងប្រតិចារឹកមួយនេះ គឺចេញមកពីរឿងក្តីតែមួយទេ គឺប្រតិចារឹកថ្ងៃ២៤ ខែសីហា ឆ្នាំ២០១១។ ខ្ញុំក៏បានផ្តល់ជូនលោក លោកស្រីចៅក្រមនូវវិធាន ស្តីពីភស្តុតាង និងនីតិវិធី ដើម្បីយោងហើយនិងប្រតិចារឹកដើម្បីឲ្យលោក លោកស្រីចៅក្រមមើលជាឯកសារយោង ហើយអាចឲ្យលោកលោកស្រីពិចារណា។ ការធ្វើដូច្នេះគឺដើម្បីឲ្យងាយស្រួលសម្រាប់អង្គសវនាការ និងលោក លោកស្រីធ្វើការពិនិត្យមើលតែប៉ុណ្ណោះ។

នៅក្នុងរឿងក្តីនេះ ករណីទាំងមូលទាំងនោះ គឺថាប្រតិចារឹកពាក់ព័ន្ធទៅនឹងសាក្សីដែលចូលមកផ្តល់សក្ខីកម្មក្នុងតុលាការ ក៏ប៉ុន្តែគាត់បដិសេធមិនផ្តល់សក្ខីកម្ម។ ដូច្នេះឧទាហរណ៍-- ដូច្នេះចំណុចនេះវាអាចពាក់ព័ន្ធទៅនឹងកូនក្តីរបស់ខ្ញុំ ប្រសិនបើគាត់មកផ្តល់សក្ខីកម្ម។

[០៩:៤២:២៤]

នៅអ្វីដែលខ្ញុំសូមបង្ហាញជូននេះ គឺត្រង់ទំព័រ៤៥៣ នៃប្រតិចារឹកក្នុងរឿងក្ដីនោះ ទៅដល់ទំព័រ ៤៦២ ដែលវាជាសេចក្ដីសម្រេចចេញ ដោយផ្ទាល់មាត់នៅក្នុងរឿងក្ដីនោះ។

ដោយសារតែពេលវេលា ខ្ញុំមិនអានឲ្យបានច្រើនតាមចិត្តដែលខ្ញុំចង់នោះទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែអាន នូវសេចក្ដីសង្ខេបនូវអ្វីដែលបានលើកឡើងនៅទីនោះ ហើយនិងឲ្យលោក លោកស្រីមើលទៅលើទំព័រ ដែលខ្ញុំយោង។ សាក្សីបានចូលខ្លួនមកក្នុងតុលាការ អាចឆ្លើយសំណួរមួយចំនួន ហើយបដិសេធមិន ឆ្លើយសំណួរផ្សេងទៀតពីខាងអយ្យការ។ សហព្រះរាជអាជ្ញាបន្ទាប់មក គឺសុំឲ្យសាក្សីនោះ ថាតើ សក្ខីកម្មរបស់សាក្សីរូបនោះពីមុនស្មោះត្រង់ដែរឬទេ? សាក្សីឆ្លើយថា ពិតជាស្មោះត្រង់។ សាក្សីបាន បញ្ជាក់ថា គាត់មិនចង់ ឬក៏មិនអាចផ្ដល់សក្ខីកម្មទៀត ដោយសារតែហេតុផលមួយចំនួន។

[០៩:៤៣:៣១]

ដូច្នេះសម្រាប់គោលបំណងរបស់យើងដែលដឹងនៅទីនេះ គឺសាក្សី គឺគាត់មិនផ្ដល់សក្ខីកម្ម ទោះ បីជាគាត់ចូលខ្លួនក៏ដោយ។ ភស្តុតាងដែលគាត់មាន គឺគាត់មិនចង់ចែករំលែក និងផ្ដល់ជូនអង្គជំនុំជម្រះ។ ដូច្នេះហើយសហព្រះរាជអាជ្ញានៅពេលនោះ គឺជាប់គាំងតែម្ដង។ តែគាត់បានកោះហៅសាក្សី ហើយ បែរជាមិនទទួលបានសក្ខីកម្ម។ ហើយគាត់បែរជាផ្អែកទៅលើចម្លើយរបស់សាក្សីនេះនាពេលមុន ដែល បានធ្វើសម្បថទៅវិញ។ នេះគឺជា *សេណារីយ៉ូ*មួយ។

នៅក្នុងករណីបែបនេះ លោក លោកស្រីចៅក្រមនឹងឃើញហើយ ខ្ញុំអស់ពេលហើយ។ តុលាការ នៅពេលនោះព្យាយាមពន្យល់អំពីវិធានមួយចំនួន នៅក្នុងករណីនុ៎ង ចៅក្រមនៅចុងក្រោយអនុញ្ញាតឲ្យ យកប្រតិចារឹកដាក់ចូលជាឯកសារ ហើយអនុញ្ញាតឲ្យផ្ដល់ឱកាសទៅដល់ភាគីធ្វើការដេញដោល និង តទល់។ ហើយនៅចុងក្រោយនៅក្នុងថ្ងៃនោះ អ្វីដែលកើតឡើង គឺគេបញ្ចូលប្រតិចារឹក គឺអង្គជំនុំជម្រះ បានបញ្ចូលប្រតិចារឹក។ ហើយគឺគេបានលើកឡើងវិធានមួយចំនួន។

[០៩:៤៤:៤៨]

ដោយសារតែពេលវេលាជិតអស់ហើយ ខ្ញុំសូមចូលទៅដល់ទំព័រ៤៥៩ អានតែចំណុចមួយចំនួន តែប៉ុណ្ណោះ។ យើងលើកអំពីវិធាន៩២ នៅ អាយ.ស៊ី.ធី.វ៉ាយ នៅក្នុងរឿងក្ដីនេះ គេនិយាយអំពីវិធាន ៩២ស្ទួនពីរ។ វិធាន៩២ស្ទួនពីរ គឺពាក់ព័ន្ធទៅនឹងទម្រង់ដែលសាក្សីផ្ដល់ភស្តុតាង ទោះបីជាដោយផ្ទាល់ មាត់ក៏ដោយ គឺចម្លើយទាំងអស់នោះ អាចទទួលយកជាលាយលក្ខណ៍អក្សរ ប្រសិនបើសាក្សីរូបនោះ

ចូលមកតុលាការដេញដោលតទល់បាន។ ហើយប្រសិនបើប្រតិចារឹកនោះគឺមិនបានឆ្លុះបញ្ចាំងគ្រប់គ្រាន់នូវអ្វីដែលសាក្សីបានឆ្លើយ បានន័យថា វិធាន៩២ស្ទួនពីរនេះ គឺមិនមែនថាជំនួសភស្តុតាងរបស់សាក្សីនោះឡើយ។

ខ្ញុំសូមផ្តល់ជាឧទាហរណ៍ខ្លះនៅ អាយ.ស៊ី.ធី.វ៉ាយ យើងមានរឿងក្តីដែលវាពាក់ព័ន្ធ ឧទាហរណ៍រឿងក្តី ពាក់ព័ន្ធទៅនឹង ស្រ៊ិប្រេនីសា។ ក្រុមប្រឹក្សាជំនុំជម្រះ មានចៅក្រមជំនុំជម្រះខុសៗគ្នា យើងមានសាក្សីផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០១ បន្ទាប់មក ប្លេកូណូវិក (Blagojević) បន្ទាប់មក ថូណូវិក។ ជាទូទៅ សាក្សីគាត់មកផ្តល់សក្ខីកម្មម្តងៗមួយពេលម្តងៗ ហើយចាប់ផ្តើមសក្ខីកម្មតាំងពីដើមមក។ ប្រសិនបើ សហព្រះរាជអាជ្ញា ឬភាគីជាអ្នកស្នើសុំដាក់បញ្ចូលសាក្សី ដើម្បីសន្សំពេលវេលា ពីព្រោះនៅទីនេះយើងមានបញ្ហាពេលវេលា។ យើងដាក់សំណើ គេដាក់សំណើតាមវិធាន៩២ស្ទួនពីរ គឺដើម្បីសុំអនុញ្ញាតឱ្យយកចម្លើយមុននោះ យកមកដេញដោលបានក្រោយពីសួរសាក្សីនោះ នៅក្នុងតុលាការបានបីបួនប្រាំសំណួរ។

[០៩:៤៦:៥៧]

ដូច្នេះ នៅពេលនោះគឺគេបានយកសក្ខីកម្មយកមកដាក់បញ្ចូលតែម្តង។ វាចេញមកពីភស្តុតាងរបស់សហព្រះរាជអាជ្ញា ដែលគាត់ជាអ្នកសួរទៅលើសាក្សី។ ដូច្នេះភាគីបន្ទាប់មកត្រូវការដេញដោលតទល់។ នេះគឺជាវិធានដែលចែងនៅក្នុងវិធាន៩២ស្ទួនពីរនេះ។ នៅក្នុងអង្គជំនុំជម្រះនេះ យើងមានវិធានផ្សេង វាជាស៊ីវិលឡ ក៏ប៉ុន្តែយើងក៏មិនមែនថា យកស៊ីវិលឡទាំងអស់នោះទេ យើងនៅចន្លោះស៊ីវិលឡ។ យើងក៏មិនមែនចាកឆ្ងាយចេញពីស៊ីវិលឡនោះដែរ ក៏ប៉ុន្តែវាក៏អាចពាក់ព័ន្ធទៅនឹងប្រព័ន្ធច្បាប់ខំមិនឡផងដែរ។ ខ្ញុំដឹងថាចៅក្រមយល់។ យើងនៅក្នុងផ្នែកនៃវិធានទាំងពីរនេះ។

លោក លោកស្រីចៅក្រម ត្រូវតែផ្តល់សិទ្ធិទៅដល់ភាគី។ ភាគីមួយចំនួន គឺស្វាគមន៍ ភាគីមួយចំនួនគឺមិនពេញចិត្ត ក៏ប៉ុន្តែសហព្រះរាជអាជ្ញា គឺមានសិទ្ធិក្នុងការដឹកនាំសាក្សី ដឹកមុខសាក្សី។ នៅពេលនេះ ប្រសិនបើយើងទទួលយកប្រតិចារឹកយកមកដាក់បញ្ចូល ហើយសហព្រះរាជអាជ្ញាគាត់មានឆន្ទៈថានេះជាភស្តុតាងចំពោះសាក្សី ដែលគាត់បានស្តាប់ចម្លើយ។ ប្រសិនបើអ៊ីចឹងមែន យើងនៅពេលនេះគឺត្រូវតែអនុវត្តនីតិវិធីតទល់។ នេះហើយដែលយើងមានបញ្ហានៅទីនេះ។ ក៏ប៉ុន្តែអ្វីដែលសំខាន់នោះ គឺប្រសិនបើសាក្សីមកផ្តល់សក្ខីកម្ម ឱ្យសាក្សីនោះឆ្លើយទៅ ហើយប្រសិនបើសហព្រះរាជអាជ្ញាចង់ប្រើប្រាស់ភស្តុតាងចេញពីរឿងក្តីមុន ដែលជាផ្នែកមួយនៃសក្ខីកម្ម គឺមិនបញ្ហាទេ។ សហព្រះរាជអាជ្ញា ត្រូវតែ

ចង្អុលបញ្ជាក់ ថាផ្នែកណាមួយចង់យកមកប្រើប្រាស់ដោយសារមូលហេតុអ្វី ដើម្បីឲ្យយើងដឹង។ សហព្រះរាជអាជ្ញាមិនអាចឲ្យចូលទៅដល់ផ្នែកផ្សេងទៀត ដែលគាត់បានសួរទៅលើសាក្សីនោះទេ។ នៅពេលដែលយើងធ្វើដូច្នេះ យើងត្រូវតែប្រុងប្រយ័ត្ន។ យើងបានស្នើសុំហើយ ពេលវេលាប៉ុន្មានដែលយើងចង់មានសម្រាប់សួរទៅលើបញ្ហា ឌុច។

[០៩:៤៩:០១]

នេះជាចំណុចដែលនៅពេលម៉ោងបីភ្លឺនេះ គឺថាវាធ្វើឲ្យខ្ញុំគិតហើយគិតឃើញទៅលើបញ្ហាមួយ។ លោក លោកស្រីចៅក្រមសួរថា យើងចង់បានពេលវេលាប៉ុន្មាន ប្រតិចារឹក០០១ យកមកដាក់នៅក្នុងនេះទាំងមូល។ ចម្លើយរបស់គាត់ទាំងអស់យកមកដាក់បញ្ចូល។ សហព្រះរាជអាជ្ញា គឺគាត់មកផ្តល់--គាត់ស្តាប់ចម្លើយ ហើយប្រសិនបើចៅក្រមសួរថា ខ្ញុំត្រូវការប៉ុន្មាននោះ? ពេលវេលាប៉ុន្មាននោះ? គឺខ្ញុំនិយាយថា មួយម៉ោង ឬក៏ពីរម៉ោង ហើយនៅពេលដែលខ្ញុំមានតែមួយម៉ោង ឬពីរម៉ោង គឺខ្ញុំសួរសាក្សីរូបនេះនៅក្នុងតុលាការ ហើយខ្ញុំត្រូវតែសួរទាំងអស់នូវរឿងក្តី ដែលគាត់ឆ្លើយនៅក្នុងសំណុំរឿងមុន។ ដូចដែល លីសាក់ គាត់បានលើកឡើងម្សិលមិញ គាត់ថា ចៅក្រមដឹងទាំងអស់ហើយរឿងក្តីនោះបានចៅក្រមបានសម្រេចរួចហើយ។ បញ្ហាវានៅត្រង់ហ្នឹង។ យើងមានបញ្ហាយ៉ាងធំនៅទីនេះ។ ខ្ញុំសូមលើកឡើង ហើយសូមបញ្ជាក់ថា ប្រសិនបើសាក្សីមកផ្តល់សក្ខីកម្ម យើងស្តាប់សក្ខីកម្មគាត់សិនទៅ ប្រសិនបើយើងចង់ចូលទៅដល់សក្ខីកម្មរបស់សាក្សីនេះនាពេលមុនយើងអាចធ្វើបាន។ ជាធម្មតាគឺយើងអាចធ្វើទៅបាន នៅពេលដែលយើងសួរតទល់គ្នាជាមួយនឹងសាក្សី។ វាជាបញ្ហាមួយដែលយើងសន្សំពេលវេលា។ ដូច្នេះហើយយើងគួរតែកំណត់ទៅលើផ្នែកណាមួយ ដែលយើងកំណត់ថានឹងយកមកបញ្ចូលឲ្យយើងដឹងជាមុន ដើម្បីឲ្យយើងអាចរៀបចំកាលវិភាគ ការពិនិត្យដេញដោលពិនិត្យសាក្សីរូបនេះ ថាតើវាជាផ្នែកមួយនៃវិធានដែលមានចែងដែរឬទេ? អត់មានចែងទេ។ តែយើងអាចធ្វើបានដែរឬទេ ដើម្បីយើងគោរពសិទ្ធិរបស់ភាគីនីមួយៗ គឺយើងអាចធ្វើបាន។

ដូច្នេះយើងត្រូវតែមានគំនិតច្នៃប្រឌិដ្ឋ យើងក៏មិនមែនថាយកបញ្ហាទាំងអស់ ឯកសារទាំងអស់យកមកដាក់បញ្ចូល ហើយដកចេញនៅពេលក្រោយនោះទេ។ យើងត្រូវតែប្រុងប្រយ័ត្ននូវអ្វីដែលយើងយក ទទួលយកមកដាក់ចូលនៅក្នុងសវនាការនេះ។

[០៩:៥០:៥៨]

ចំពោះប្រតិចារឹក ប្រតិចារឹកមួយដែលបានស្នើឡើងនោះគឺរបស់លោក ហ្គោលស្តូន ចៅក្រម

ហ្គោលស្តូន ៗគឺជាចៅក្រមតុលាការកំពូល នៅប្រទេសអាហ្វ្រិកខាងត្បូង ដែលគាត់ក្រោយមកជាសហព្រះរាជអាជ្ញានៅ អាយ.ស៊ី.ធី.វ៉ាយ ហើយជាសាស្ត្រាចារ្យ ហើយគាត់ក៏បានចូលរួមនៅក្នុងគណៈកម្មការ ពាក់ព័ន្ធទៅនឹងហេតុការណ៍នៅហ្គាហ្សា។ ខ្ញុំមិនចូលទៅនឹងចំណុចហ្នឹងជ្រៅទេ។ ចៅក្រមហ្គោលស្តូន គាត់មកផ្តល់សក្ខីកម្មនៅតុលាការនេះ នៅក្នុងរឿងក្តី ឌុច លើកបញ្ហាដែលមិនពាក់ព័ន្ធទៅនឹងរឿងក្តីជាក់លាក់មួយ។

វាមិនពាក់ព័ន្ធទៅនឹងរឿងក្តីរបស់យើងនេះទេ ខ្ញុំមើលសក្ខីកម្មរបស់គាត់ វាអាចពាក់ព័ន្ធទៅនឹងផ្នែកផ្សេង ទៅនឹងផ្នែកផ្សេងទៀតនៃសំណុំរឿងនេះ ប៉ុន្តែសក្ខីកម្មរបស់គាត់មិនពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១ នោះទេ។ ក៏ប៉ុន្តែហេតុអ្វីបានសហព្រះរាជអាជ្ញាចង់យកមកបញ្ចូលនៅក្នុងពេលនេះ? ដោយសារតែវាពាក់ព័ន្ធទៅនឹងបញ្ហាខាងឧក្រិដ្ឋកម្មរួម ឬក៏យ៉ាងណា? វាមិនពាក់ព័ន្ធនោះទេ ទៅនឹងសហឧក្រិដ្ឋកម្មរួម។

[០៩:៥២:១៤]

យើងមានប្រតិចារឹកផ្សេងទៀត ប្រតិចារឹករបស់អ្នកជំនាញ របស់ប្រវត្តិវិទូ ដូចជាលោកឆេនដ័ល័រ, ណាយ៉ាន់ ចាន់ដា ប្រសិនបើសាក្សី ឬក៏បុគ្គលទាំងពីរ-- ប្រសិនបុគ្គលទាំងពីរនេះមកចូលផ្តល់សក្ខីកម្ម អ្វីដែលសហព្រះរាជអាជ្ញាចង់ស្នើសុំ គឺទទួលយកសក្ខីកម្មមុនទាំងអស់។ ក៏ប៉ុន្តែគឺថាតើយើងគួរតែទទួលយកសក្ខីកម្មអង្គហេតុទាំងអស់ ដែលលោក លោកស្រីចៅក្រមបានសម្រេចដោយផ្អែកទៅលើសំណុំរឿង០០១ ឬក៏យ៉ាងម៉េច?

[០៩:៥២:៥៤]

លោក លោកស្រីចៅក្រម ខ្ញុំជិតអស់ពេលហើយ ប៉ុន្តែខ្ញុំសូមអធ្យាស្រ័យអនុគ្រោះឲ្យខ្ញុំមួយនាទីពីរនាទី ដើម្បីធ្វើការបញ្ចប់ការអត្ថាធិប្បាយរបស់ខ្ញុំ។

ប៉ុន្តែបញ្ហានៅត្រង់នេះ វាកើតឡើងចំពោះយើងខ្ញុំ។ ប្រសិនបើសាក្សីទាំងអស់នោះ បុគ្គលទាំងអស់នោះមិនមកចូលផ្តល់សក្ខីកម្មតទល់នោះទេ យើងនឹងជាប់គាំងលើបញ្ហានីតិវិធី។ សហព្រះរាជអាជ្ញាបានលើកឡើង ថាពួកគាត់គឺបានដេញដោលសាក្សី បុគ្គលទាំងអស់នោះរួចមកហើយ នៅក្នុងរឿងក្តីមុន។ សហព្រះរាជអាជ្ញាអំមិញគ្រវីក្បាលហើយ ក៏ប៉ុន្តែយើងគួរតែមើលប្រតិចារឹកទៅ គាត់ថា ប្រតិចារឹកគួរតែចាត់ទុកដូចគ្នាចម្លើយនៅសហចៅក្រមស៊ើបអង្កេត ក៏យើងត្រូវតែចាត់ទុកដូចគ្នា ដោយសារតែមានការសម្បថ។ នេះជាអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងសារណារបស់ខ្លួនជាលាយ

លក្ខណ៍អក្សររួមទាំងកាលពីម្សិលមិញផងដែរ។

ក៏ប៉ុន្តែប្រសិនបើសាក្សីដូចជា ឆេនដ៍ល័រជាដើម គឺសាក្សីមកពី០០១ គាត់មកចូលខ្លួន។ ហេតុអ្វីបានជាយើងយកសក្ខីកម្មរបស់គាត់ពីសំណុំរឿង០០១មកដាក់ចូលនៅក្នុងវគ្គនេះធ្វើអី? ហេតុអ្វីបានជាពាក់ព័ន្ធ? ថាតើយើងហាក់ដូចជាដំណើរការទៅមុននីតិវិធី ឬក៏យ៉ាងម៉េច? ប្រសិនបើបុគ្គលនេះត្រូវបានកោះហៅ ហើយយើងអាចដេញដោលតទល់ ដូច្នេះហើយថាតើវាចាំបាច់យ៉ាងម៉េចដែលយើងត្រូវយោងទៅលើផ្នែកមុននៃសក្ខីកម្មរបស់គាត់។

[០៩:៥៤:១៥]

ដោយសារតែយើងគិតទៅលើពេលវេលា យើងមិនអាចសួរដេញដោលទៅលើគ្រប់អង្គហេតុពីមុនទាំងអស់នោះទេ នៅក្នុងផ្នែកជាក់លាក់ដាច់ដោយឡែកនេះទេ។ យើងត្រូវតែចូលទៅលើអំពើ និងតួនាទីរបស់ជនជាប់ចោទ ចាំបាច់ត្រូវតែធ្វើការរៀបរាប់ទៅលើអង្គហេតុរបស់យើង។

ក៏ប៉ុន្តែហេតុអ្វីបានជាសហព្រះរាជអាជ្ញា ភាគី ព្យាយាមសុំបញ្ចូលផ្នែកដែលពាក់ព័ន្ធទៅនឹងបុគ្គលរូបនេះ យកមកដាក់បញ្ចូល? ថាតើវាពាក់ព័ន្ធយ៉ាងម៉េច? ហើយភាគី បើសិនជាភាគីគាត់មិនដឹងផងនោះ។ នៅពេលដែលសាក្សីគាត់ចូលមកដល់ទីនេះហើយ យើងអាចដេញដោល ចាំបាច់បញ្ចូលធ្វើអីផ្នែកមុន។ ប្រសិនបើសាក្សីហ្នឹងគឺគាត់មិនមានវត្តមានដូចរឿងក្ដី ហាឌីណា ដូច្នេះហើយ យើងអាចដេញដោលនៅពេលដំណាក់កាលដែលពេលក្រោយ ប៉ុន្តែយើងមិនទាន់ដល់ដំណាក់កាលនោះឡើយ។ ហេតុដូច្នេះហើយ ជំហរមូលដ្ឋានរបស់យើង គឺយើងបញ្ជាក់បានច្បាស់ហើយកាលពីម្សិលមិញ ខ្ញុំបានអង្គុយនៅទីនេះ យ៉ាងស៊ូទ្រាំ ហើយនិងព្យាយាមអត់ធ្មត់ ខ្ញុំចង់លើកឡើងជំទាស់កាលពីម្សិលមិញ ក៏ប៉ុន្តែខ្ញុំមិនចង់។ ក៏ប៉ុន្តែយើងហាក់ដូចជាមានការត្រូវបានកម្រិតអំពីអត្ថិភាពនៃ ស-២១។ យើងព្យាយាមដកចេញទៅលើសក្ខីកម្ម និងបដិសេធឯកសារនេះ ឯកសារនោះ។ ក៏ប៉ុន្តែយើងមិនធ្វើអីចឹងទេ យើងខ្ញុំគ្រាន់តែចង់លើកឡើងថា ដោយសារតែលោក លោកស្រីចៅក្រមមានឆន្ទានុសិទ្ធិក្នុងការកម្រិតវិសាលភាពសំណុំរឿងវគ្គមួយនេះ ដើម្បីប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ដើម្បីអាចឲ្យចេញសាលក្រមលឿននោះ។ លោក លោកស្រីចៅក្រមហ្នឹងមិនអាចចេញសាលក្រមលឿននោះទេ ប្រសិនបើមានកំណត់គោលដៅច្បាស់លាស់នៅក្នុងការទទួលយកភស្តុតាងនៅក្នុងពេលនេះ។

[០៩:៥៦:១៣]

ខ្ញុំគិតថា សវនាការនេះ ខ្ញុំក៏ឯកភាពជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីកាលពីម្សិលមិញផងដែរ

សវនាការនេះគឺវាជាបញ្ហាដែលសំខាន់ផងដែរសម្រាប់ភាគី។ យើងដឹងហើយ យើងត្រូវដឹងអំពីប្រភពនៃឯកសារ ក៏ប៉ុន្តែនៅពេលនេះ យើងព្យាយាមលើកទឡ្ហីករណ៍ឡើងថា ហេតុអ្វីបានជាឯកសារនោះបង្ហាញនូវពិរុទ្ធភាព ឬក៏មិនបង្ហាញនូវពិរុទ្ធភាព ដូចដែលបានលើកឡើងកាលពីម្សិលមិញ។

ដូច្នេះសម្រាប់វិធីសាស្ត្ររបស់ចៅក្រម យើងសង្ឃឹម និងជឿជាក់ថា លោក លោកស្រីចៅក្រមនឹងមើលទៅលើឯកសារទាំងអស់ដែលបានស្នើឡើង។ ហើយនៅពេលដែលលោក លោកស្រីចៅក្រមមើលទៅលើប្រតិចារឹក ចេញពីសេចក្តីសម្រេចដោយផ្ទាល់មាត់នៅក្នុងរឿងក្តី ហាឌីណា លោក លោកស្រីចៅក្រមនឹងឃើញចម្លើយដែលគេលើកឡើងនៅក្នុងទីនេះរួចហើយ។ យើងមិនចាំបាច់ធ្វើឲ្យប៉ះពាល់ទៅដល់បញ្ហាណាមួយនោះទេ ក៏ប៉ុន្តែយើងត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ យើងត្រូវតែមានសវនាការមួយជាក់លាក់អាចគ្រប់គ្រងបាន។ នៅពេលដែលយើងធ្វើសេចក្តីបញ្ចប់នោះ គឺយើងនឹងដឹងហើយថាមានអ្វីពាក់ព័ន្ធខ្លះ។

[០៩:៥៧:២៥]

ដូច្នេះមិនគ្រប់គ្រាន់ទេ នៅពេលដែលសហព្រះរាជអាជ្ញាក្រោកឡើង ហើយបញ្ជាក់ថា អង្គជំនុំជម្រះត្រូវតែសម្រេចទៅលើឯកសារ ទោះបីជាមិនសម្រេចពេលនេះក៏ដោយ និងពេលក្រោយ។ សហព្រះរាជអាជ្ញាត្រូវតែពិនិត្យទៅលើឧបសម្ព័ន្ធរបស់ខ្លួន។ ចំណុចនេះ ខ្ញុំសូមលើកផងដែរមុនពេលដែលខ្ញុំអង្គុយចុះ។ នៅពេលដែលយើងមើលឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា ជាក់ស្តែងគឺយើងមិនអាចធ្វើការបែងចែកក្នុងករណីជាច្រើន ដោយសារតែឯកសារមួយចំនួននៅក្នុងនោះ។ កូនក្តីរបស់ខ្ញុំ គឺយើងដឹងហើយ គឺគាត់ទទួលបាននូវការអនុគ្រោះទោស និងការលើកលែងទោស គឺយើងខ្ញុំក៏អាចចេះគិតពិចារណាផងដែរ។

[០៩:៥៨:១៤]

កាលពីម្សិលមិញ លោក ឡៃសិក-- លីសាក់ លើកឡើងអំពីសារណារបស់គាត់តែហាក់ដូចជាសន្និដ្ឋានបិទ ក៏ប៉ុន្តែវាប្រសិនបើសហព្រះរាជអាជ្ញា ខ្ញុំមិនមែនរិះគន់ ក៏ប៉ុន្តែនេះជាអ្វីដែលសាលាដំបូងគួរតែពិចារណា។ ប្រសិនបើសហព្រះរាជអាជ្ញានៅក្នុងឧបសម្ព័ន្ធរបស់ខ្លួននោះ ផ្តល់ព័ត៌មានឲ្យបានច្រើនជាងនេះ មិនចាំបាច់យោងទៅលើកថាខណ្ឌណាមួយជាក់លាក់នោះទេ គួរគាត់ហ្នឹងប្រសិនបើគាត់គួរតែផ្តល់ព័ត៌មានឲ្យបានច្រើនជាងនេះ ជាការរៀបរាប់ វានឹងផ្តល់ឱកាសទៅដល់ភាគីយល់ដឹង។ ដូច្នេះហើយ នៅពេលនោះយើងជាភាគីនឹងមិនធ្វើការជំទាស់ខ្លាំងទៅលើបញ្ហាទាំងអស់នេះទេ ទោះបីជាយ៉ាង

ណាក៏ដោយ ខ្ញុំនៅពេលនេះ សូមថ្លែងអំណរគុណដល់អង្គជំនុំជម្រះដែលផ្តល់ពេលវេលាបន្ថែមឲ្យខ្ញុំ ហើយព្យាយាមអត់ធ្មត់ក្នុងការស្តាប់នូវសេចក្តីសន្និដ្ឋានរបស់ខ្ញុំ នាព្រឹកនេះ សូមអរគុណ។

[០៩:៥៩:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន!

សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទ ក្រោយពីបានស្តាប់ចម្លើយតបរបស់សហព្រះរាជអាជ្ញា ខ្ញុំបាទសូមធ្វើសេចក្តីឆ្លើយតបជារួមទៅលើចម្លើយរបស់សហព្រះរាជអាជ្ញា ហើយនិងខ្ញុំបាទសូមលោកប្រធានអនុញ្ញាតឲ្យសហភាតារបស់ខ្ញុំ ធ្វើសេចក្តីឆ្លើយតបជាក់លាក់ទៅលើចំណុច ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា។

[១០:០០:០៩]

ជាបឋម ខ្ញុំសូមគាំទ្រចំពោះមេធាវីការពារទាំងពីរក្រុម ដែលបានលើកពីអម្បាញ់មិញនេះ ជាពិសេសទាក់ទងទៅលើការបដិសេធ ចំពោះឯកសារទាំងឡាយ ដែលបានដាក់ដោយសហព្រះរាជអាជ្ញា។ ជំហររបស់យើងខ្ញុំ មិនមានន័យថា គ្រប់ឯកសារទាំងអស់ដែលបានដាក់ដោយសហព្រះរាជអាជ្ញា យើងបដិសេធទាំងស្រុងនោះទេ។ ក៏ប៉ុន្តែវាមានឯកសារមួយចំនួនដែលយើងយល់ថាមិនជាប់ពាក់ព័ន្ធទៅនឹងឯក-- ទៅនឹងសវនាការនាពេលនេះ ហើយឯកសារទាំងអស់នោះគួរតែលើកសម្រាប់ទៅលើប្រើប្រាស់នៅពេលក្រោយដែលមិនត្រូវយកមកប្រើប្រាស់នៅពេលនេះ ឬក៏ឯកសារមួយចំនួនទៀតដែលមិនមានប្រយោជន៍សម្រាប់រឿងក្តី ហើយដែលសហព្រះរាជអាជ្ញាបានលើកយកមកដាក់សម្រាប់ការដេញដោលនៅពេលនេះ ដែលធ្វើឲ្យមានការលំបាកក្នុងការចំណាយពេលវេលាដើម្បីជំទាស់។

[១០:០១:០៨]

ទទ្បឹករណ៍មួយដែលខ្ញុំមើលឃើញជារួម គឺថាការយល់ខ្វែងគំនិតគ្នារវាងសហព្រះរាជាអាជ្ញា និងសេចក្តី-- ដីកាសម្រេចរបស់អង្គជំនុំជម្រះ លេខ E124 ទាក់ទងទៅនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន៨៩ស្ទួន២ នៃវិធានផ្ទៃក្នុង ដែលបញ្ហានេះវាជាគន្លឹះធំដែលធ្វើឲ្យ

សហព្រះរាជអាជ្ញាយល់ឃើញថា រាល់ឯកសារទាំងអស់វាតែងតែជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង០០២ នេះ ប៉ុន្តែដោយឡែកការបំបែកនូវកិច្ចនីតិវិធីរបស់អង្គជំនុំជម្រះនាពេលនេះ គឺបានធ្វើឲ្យឯកសារមួយចំនួនរបស់សហព្រះរាជអាជ្ញាមិនជាប់ពាក់ព័ន្ធទាំងស្រុងនៅក្នុងការជំនុំជម្រះនាពេលនេះទេ។

ដូច្នេះខ្ញុំយល់ថា តើនីតិវិធីមួយណាដែលៗត្រូវអនុវត្តនៅពេលនេះ? ជាចំណោទមួយដែលអង្គជំនុំជម្រះអាចសម្រេច ដែលជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការសម្រេច ថាតើឯកសារណាដែលជាប់ពាក់ព័ន្ធទៅលើនីតិវិធីនៃដំណើរការសវនាការនៅពេលនេះនោះ?

ដោយហេតុថា ការកំណត់របស់សហព្រះរាជអាជ្ញាកន្លងមក គឺផ្តោតទៅលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតច្រើនជាង ការពិនិត្យទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះនាពេលនេះ។

[១០:០២:៥៧]

ដូច្នេះធ្វើឲ្យឯកសារទាំងឡាយដែលសហព្រះរាជអាជ្ញាលើកឡើងនៅពេលនេះ មិនជាប់ពាក់ព័ន្ធទៅនឹងនីតិវិធីនៅក្នុងពេលបច្ចុប្បន្ននេះ។ ហើយអ្វីដែលយើងខ្ញុំយល់ គឺថារវាងឯកសារដែលជាប់ពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយ ហើយនិងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលមានលេខយោង E124 សួរថា តើយើងគួរអនុវត្តតាមដីកាដំណោះស្រាយ ឬមួយក៏អនុវត្តតាមឯកសារ E124 ក្នុងករណីដែលមានទំនាស់គ្នានោះ។ បាទ នេះជាចំណុចមួយដែលខ្ញុំយល់ឃើញថា ដំណាក់កាលនៃការស៊ើបសួរបានកន្លងផុងទៅហើយ ហើយដីកាដំណោះស្រាយនោះមិនមែនជាគោលសំខាន់សម្រាប់ដំណើរការសវនាការនៅពេលនេះទេ។ ហើយអង្គជំនុំជម្រះនៅពេលនេះ គឺមានឆន្ទានុសិទ្ធិយ៉ាងពិតប្រាកដ ដើម្បីសម្រេចបំបែកនូវកិច្ចដំណើរការនីតិវិធីនេះ។ ហើយដូច្នេះការកំណត់ទៅលើវគ្គនីមួយៗនៃដំណើរការនីតិវិធីវាជារឿងចាំបាច់ដែលអាចសម្រួលដល់ដំណើរការនេះ។ ហើយដូច្នេះ អង្គជំនុំជម្រះត្រូវកំណត់ថាតើឯកសារដែលសហព្រះរាជអាជ្ញាលើកយកមកនេះ មានឯកសារណាខ្លះដែលជាប់ពាក់ព័ន្ធសម្រាប់ដំណើរការនាពេលនេះ? ហើយដែលត្រូវធ្វើការដេញដោលដើម្បីស្វែងរកការពិតអំពីឯកសារទាំងអស់នោះ។

ទីពីរ ទាក់ទងទៅនឹងគោលការណ៍ជារួមមួយទៀត ដែលយើងបានស្តាប់ឮក្នុងរយៈពេលពីរថ្ងៃដែលសហព្រះរាជអាជ្ញាបានលើកឡើង ហាក់ដូចជាចង់បង្ហាញថា មេធាវីការពារគួរតែបង្ហាញនូវឯកសារការពាររបស់ខ្លួន។ ដូចសហព្រះរាជអាជ្ញាបានលើកអំពីខ្សែវីដេអូ របស់លោក ខៀវ សំផន

ដែលនិយាយអំពីឈ្មោះរបស់គាត់ ឈ្មោះឪពុកម្ដាយរបស់គាត់ជាដើម ពីម្សិលមិញនេះ ដែលលោកបានបញ្ជាក់ថា គ្មានអ្នកណាដឹងទេ គឺមានមនុស្សម្នាក់នៅក្នុងនេះគឺលោក ខៀវ សំផន ដែលអាចដឹងអាចផ្ដល់ព័ត៌មានបានអំពីបញ្ហាដែលជាប់ពាក់ព័ន្ធទៅនឹងខ្សែវីដេអូនេះ ជាដើម។

[១០:០៥:៥០]

ការលើកបែបនេះហាក់ដូចជាបំភ្លេចចោលនូវតួនាទីរបស់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញភស្តុតាងដែលលោកមានភារៈជាអ្នកបង្ហាញភស្តុតាងចំពោះរឿងក្ដីនេះ មិនមែនៗជនជាប់ចោទជាអ្នកត្រូវបង្ហាញភស្តុតាងដោះបន្ទុកនោះទេ។ អ៊ីចឹងល្គឹកណាតំណាងសហព្រះរាជអាជ្ញាបង្ហាញភស្តុតាងមិនបានលើសពីវិមតិសង្ស័យទេ អ៊ីចឹងការឆ្លើយតបរបស់ភាគីជនជាប់ចោទ គឺមិនត្រូវការទេ មិនចាំបាច់ទេ។ អ៊ីចឹងកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា គឺមិនអាចរំលងបាននោះគឺបន្ទុកនៃការបង្ហាញភស្តុតាងនេះដែលមិនត្រូវផ្ទេរមកជនជាប់ចោទវិញទេ។ បាទ ខ្ញុំបាទសូមអរគុណ ដោយសារពេលវេលាខ្លី ខ្ញុំសូមជូនសហភាតារបស់ខ្ញុំដើម្បីបង្ហាញបន្ត។

[១០:០៦:៥៨]

**លោកស្រី អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព! ដោយសារពេលវេលារបស់យើងមានពេលខ្លីនោះ ខ្ញុំនិយាយដោយសង្ខេបលើចំណុចមួយចំនួនដែលខ្ញុំយល់ឃើញថា មានសារៈសំខាន់ ហើយនិងដែលត្រូវតែបំភ្លឺ។ ខ្ញុំសូមឆ្លើយតបទៅនឹងប្រធានបទមួយចំនួនដែលខាងសហព្រះរាជអាជ្ញាបានលើកឡើង ក៏ប៉ុន្តែជាបឋម ខ្ញុំសូមគូសបញ្ជាក់ចំណុចមួយដែលបានលើកឡើងដោយសហភាតារបស់ខ្ញុំអម្បាញ់មិញនេះ ហៅថាយើងមិនដែលសង្ស័យទៅលើសមត្ថភាពរបស់ចៅក្រមនោះទេ។ ដោយសារខ្លួនមានសមត្ថភាពក្នុងការវាយតម្លៃលើតម្លៃភស្តុតាង ក៏ប៉ុន្តែចំពោះខ្ញុំ គឺថាការធ្វើការងារយើងនេះ ដែលថាយើងពិភាក្សាគ្នាពីរថ្ងៃមកហើយគឺថាយើងត្រូវធ្វើយ៉ាងណាដើម្បីឲ្យមានការជ្រើសរើសឯកសារដែលដាក់ជូនទៅចៅក្រម គឺថាត្រូវជ្រើសរើសជាបឋម។

[១០:០៨:០៨]

ខ្ញុំសូមបញ្ជាក់ផងដែរថា ដោយសារតែមានការស្ដីបន្ទោសមកខាងយើង ទោះបីជាខាងដើមបណ្ដឹងរដ្ឋប្បវេណីក៏ខាងសហព្រះរាជអាជ្ញាក៏ដោយគឺថា គេនិយាយថាយើងមានទំនោរចង់និយាយអំពីតម្លៃភស្តុតាងជាជាងភាពទទួលយកបាននៃឯកសារ។ កាលពីថ្ងៃទី០១ សហព្រះរាជអាជ្ញាជាតិបាន

និយាយអំពីអត្ថបទ ខ្ញុំសូមរំឭកថាវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងបញ្ជាក់ថា បញ្ជាក់នូវបញ្ជីនូវភស្តុតាងមួយចំនួនទាក់ទងនឹងភាពទទួលយកបាននៃឯកសារ។ ខ្ញុំសូមទាញចំណាប់អារម្មណ៍ទៅលើពីរចំណុច។ វិធាន៨៧(៣) គឺថានិយាយពីភាពមិនពាក់ព័ន្ធ ដូច្នេះយើង-- ហើយក៏មានចំណុចមួយដែរ ដែលសំខាន់ដែរ គឺថា ៨៨-- ៨៧ចំណុច(គ) គឺថាយើង-- ដែលមាននិយាយអំពីភាពមិនសមស្របសម្រាប់បញ្ជាក់ពីអង្គហេតុដែលគោល-- ដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង។

[១០:០៩:៣៤]

នេះគឺជាធាតុសំខាន់ដែលត្រូវតែពិចារណា ពីព្រោះថានៅពេលយើង ដែលយើងនិយាយអំពីភស្តុតាងនោះ គឺថាដោយសារមានការចែងមានវិធានចែង វិធាន៨៧ចំណុច(គ) នេះ។ ដូច្នេះគឺថាយើងអាចមានសិទ្ធិជំទាស់បាន ដើម្បីឲ្យយើងធ្វើការវាយតម្លៃលើចំណុចពីរនេះ គឺថាភាពពាក់ព័ន្ធដែលឯកសារមួយ ដែលអាចបង្ហាញថាមានភាពពាក់ព័ន្ធនោះ។ យើងត្រូវតែនិយាយអំពីមូលហេតុដែលសហព្រះរាជអាជ្ញាលើកឡើង ហើយមូលហេតុនេះត្រូវបានបង្ហាញហើយ។ ហើយឧទាហរណ៍ គាត់បានយោងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះគឺឯកសារ E9/31 ហើយនិងនៅក្នុងតារាងនៅឧបសម្ព័ន្ធ ហើយយើង-- គាត់បានបង្ហាញតារាងទាំងអស់នោះ គាត់បង្ហាញពីលេខកូដ លេខតារាង និងផ្នែកមួយតារាងដែលគាត់បង្ហាញពីភាពពាក់ព័ន្ធនៅក្នុងហ្នឹង។ យើងខាងភាគីការពារក្ដីនោះ យើងក៏បានត្រៀមការជំទាស់ទៅតាមអ្វីដែលគាត់បានបង្ហាញនោះដែរ។ គឺថាគាត់ចង់បង្ហាញពីអ្វី ហើយដែល-- ហើយយើងនោះ យើងត្រូវធ្វើវាយតម្លៃទៅលើការភាពទទួលយកបាន ដែលថា អនុលោមទៅតាមវិធាន៨៧(គ)។

[១០:១១:២៣]

ទាក់ទងនឹងភាពពាក់ព័ន្ធ សហភាតារបស់ខ្ញុំអម្បាញ់មិញនេះបានលើកឡើងថា ថ្ងៃនេះគឺថាភាគីការពារក្ដីមិនមែន-- ការងាររបស់ភាគីការពារក្ដីហ្នឹង មិនមែនថាយើងប្រើអំណាចរបស់យើងក្នុងការកំណត់ រឹតត្បិតដែនកំណត់នៃវគ្គទីមួយនេះទេ។ នេះគឺជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ដែលកើតចេញពីដីកាបំបែកនីតិវិធី គឺថាឯកសារ E124 ដែលបដិសេធចោលនូវ-- គឺឯកសារ E124/2។ ដូចដែលបានលើកឡើងកាលពីម្សិលមិញ គឺថាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងម្សិលមិញ គឺថាអង្គជំនុំជម្រះបានបញ្ជាក់នូវឯកសារដែលត្រូវពិនិត្យនៅក្នុងវគ្គមួយនេះ ហើយលោកបាន អង្គជំនុំជម្រះក៏បានបង្ហាញអំពីឯកសារដែលត្រូវពិភាក្សា។ ហើយដោយអាស្រ័យតាមការបង្គាប់បញ្ជា របស់អង្គជំនុំ

ជម្រះនេះហើយ ដែលយើងត្រៀមនឹងជំទាស់ទៅលើភាពពាក់ព័ន្ធនេះ។ ហើយយើងសូមជម្រាបផងដែរថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ មានភាពចម្រូងចម្រាសជាមួយនឹងគោលជំហររបស់សហព្រះរាជអាជ្ញា ដូចដែលគាត់បានលើកឡើងប៉ុន្មានថ្ងៃនេះ។ ហើយៗ គឺសហព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ក៏មានភាពចម្រូងចម្រាសដែរនៅក្នុងតារាងរបស់ខ្លួននោះ មានភាពមិនស៊ីគ្នា។ ហើយ--

[១០:១៣:១០]

ខ្ញុំមិននិយាយលម្អិតអំពីភាពចម្រូងចម្រាសគ្នានេះទេ ពីព្រោះថាពេលវេលាខ្លី។ ខ្ញុំគ្រាន់តែចង់ជម្រាបជូនថា យ៉ាងហោចណាស់ក៏មានឯកសារចំនួន១១៧ ដែលថាមានឯកសារនៅក្នុងឧបសម្ព័ន្ធ ឯកសារជាច្រើននៅក្នុងឧបសម្ព័ន្ធនោះមិនទាក់ទងនឹងវគ្គទីមួយនេះទេ។ នៅក្នុងសេចក្ដីសម្រេចនៃឯកសារ 124/2 នេះ ខ្ញុំសូមកត់សម្គាល់ថា ដូចដែលលោក កាណាវាស បានលើកឡើងដែរ គឺថាវាហាក់ដូចជាមានភាពលម្អៀង ឬក៏មិន-- ភាពស្រពេចស្រពិលពីសំណាក់សហព្រះរាជអាជ្ញា។ វាហាក់ដូចជាការនិយាយម្សិលមិញនេះ វាហាក់ដូចជាការនិយាយការកត់សម្គាល់ចុងក្រោយទៅវិញ។ នៅក្នុងឯកសារ E9/3-- /31 (សូមទោស) គឺថាគាត់ព្យាយាមក្នុងការផ្ដល់ទឡ្ហីករណ៍ហាក់ដូចជាយើងពិភាក្សាអំពីលើអង្គហេតុអ៊ីចឹង។

[១០:១៤:២៩]

មានឯកសារមួយទៀត ដែលសំខាន់ដែលលើកឡើងថា-- ដោយសហព្រះរាជអាជ្ញា ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណី គឺថាដែនកំណត់នៃវគ្គទីមួយនេះអាចពន្លាតបាន ពង្រីកបាន។ ហើយនៅក្នុងករណីនេះ យើងត្រូវតែយកឯកសារទាំងអស់ដែលដាក់ជូនទៅអង្គជំនុំជម្រះ។ ហើយកន្លែងនេះខ្ញុំមិនយល់ពីវិធីសាស្ត្រនេះណាស់។

លោកចៅក្រមបានចេញសេចក្ដីសម្រេច គឺថា E172 ទំព័រទី៤ គឺថាអង្គជំនុំជម្រះបានជម្រាបថាខ្លួនមិនចង់ អានេះជាទំព័របារាំងទេ សូមទោស នេះជាយោង ជាភាសាបារាំង។ នៅពេលដែលខាងសហព្រះរាជអាជ្ញា បានស្នើសុំឱ្យពង្រីកពាក់ព័ន្ធទៅនឹងរណ្ដៅរួមនោះ អង្គជំនុំជម្រះបានជម្រាបថាខ្លួននឹងផ្ដល់ជូន-- ដំណឹងជូនទាក់ទងទៅនឹងការពង្រីកនេះនៅក្នុងរយៈពេលសមស្រប។

[១០:១៥:៥២]

នៅក្នុងអនុស្សរណៈ E172 នៅពេលដែលអង្គជំនុំជម្រះឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា។ ខ្ញុំធ្វើការនៅក្នុងតុលាការអន្តរជាតិផ្សេងដែរ ថ្វីត្បិតតែខ្ញុំជំនួសឱ្យមេធាវីលោក ខៀវ

សំផន។ ខ្ញុំយល់ថា គួរឲ្យការសោកស្ដាយណាស់ ដែលថាមានការសេចក្ដីសម្រេច ដែលថាចេញជាសាធារណៈហើយនោះពុំមានលក្ខណៈជាសេចក្ដីសម្រេចច្បាស់លាស់ ហើយមានតែជាកថាខណ្ឌមួយចំនួន ដែលពុំមានលក្ខណៈច្បាស់លាស់នោះ។ ខ្ញុំគិតថា គួរតែចេញសេចក្ដីសម្រេចឲ្យជាក់លាក់ ដែលថាមានលក្ខណៈជាសេចក្ដីសម្រេច ហើយខ្ញុំនឹងនិយាយលម្អិតអំពីករណីនេះនៅពេលក្រោយទៀត។

ដោយសង្ខេប ខ្ញុំនឹងនិយាយអំពីបញ្ហាឯកសារដើម ហើយនិងភាពអាចគួរឲ្យទុកចិត្តបាននៃឯកសារ ដែលទទួលបាន ស៊ី.ឌី.ខេម។ លោកបានសង្កត់ធ្ងន់ទៅលើសក្ខីកម្មរបស់លោក ឆាំង យុ ហើយនិងលោក ដារ៉ា។ ខ្ញុំសូមយោងទៅនឹងសម្រង់មួយ នៃឯកសារនៃបណ្ណសារជាតិ គឺប្រតិចារឹកជាភាសាបារាំងគឺ E1/30.1 ទំព័រ ៨៤ និង៨៥។ នៅក្នុងទំព័រនេះគាត់បានលើកឡើងថា ឯកសារដែលបានមកពីឌី.ស៊ី.ខេម គឺ-- ពីបណ្ណសារជាតិ គឺជាឯកសារហ្វូតូកូពី។ ឯកសារដែលនៅ-- អ៊ីចឹងខ្ញុំគិតថា ទាក់ទងនឹងឯកសារនេះ ដោយសារជាឯកសារហ្វូតូកូពីនោះ អ៊ីចឹងយើងគួរតែប្រយ័ត្នប្រយែង។ ទាក់ទងទៅនឹងទង្វើរបស់ជនជាប់ចោទ យើងសូមឲ្យអង្គជំនុំជម្រះអានឯកសារ E96/4។ នៅក្នុងនេះ យើងបានផ្ដល់ព័ត៌មានលម្អិត សេចក្ដីពន្យល់លម្អិត ហើយនិងផ្ដល់ទៅឲ្យយោងទៅនឹងវិធាន៩២។ ខ្ញុំសូម-- កន្លែងនេះគឺថា ខ្ញុំគាំទ្រទៅនឹងគំនិតយោបល់របស់លោកមេធាវី កាណាវាស។

[១០:១៨:៣៧]

ចំណុចមួយទៀត គឺថាចំណុចឯកសារថ្មី។ ខាងសហព្រះរាជអាជ្ញាបានលើកឡើងថា សញ្ញាណនៃឯកសារថ្មីនេះ វាមិនសមស្របទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះ។ តាមអនុស្សរណៈលេខ E172/5 គឺថាអង្គជំនុំជម្រះបានបញ្ជាក់ច្បាស់ហើយថា ឯកសារនេះនឹងត្រូវពិនិត្យនៅពេលក្រោយ ហើយគឺមិនដែលបានខាង ខៀវ សំផន-- គោលជំហររបស់ ខៀវ សំផន នោះគឺថាគោរពទៅតាមវិធាន ៨៧(៤) និងវិធាន៨០(៣)(ឃ)។ នេះគឺជាធាតុសំខាន់ ដែលត្រូវគិត នៅក្នុងបញ្ជីរបស់យើងគឺ E109/1.1 នៅទំព័រ២១ លោកបានលើកឡើងអំពីឯកសារថ្មីចំនួន៣៤ ហើយដែលត្រូវដកចេញពីប្រធានបទនៃការពិភាក្សា គឺមាននៅក្នុងអនុស្សរណៈ 172/5 កថាខណ្ឌទី៣ ពីព្រោះនៅក្នុងនោះបានលើកឡើងថា មានឯកសារមួយក្នុងចំណោមឯកសារ ៣១៨ គឺថាមានឯកសារមួយចំនួនដែលត្រូវដកចេញ។ ហើយមានឯកសារចំនួន៣៤ថ្មីរបស់ ខៀវ សំផន។

នៅក្នុងឯកសារ E109/2.3 ហើយឯកសារថ្មីទាំងអស់នេះមិនជាកម្មវត្ថុនៃការពិភាក្សាយើងនេះទេ ហើយខ្ញុំសូមរំឭកថា ឧបសម្ព័ន្ធ២១ របស់សហព្រះរាជអាជ្ញា គឺជាកម្រងឯកសារថ្មីទាំងអស់នេះ ក៏

ស្ថិតនៅក្នុងចំណោមឯកសារថ្មីទាំងអស់នេះដែរ។ ហើយអង្គជំនុំជម្រះបានជម្រាបហើយថា ឯកសារថ្មីទាំងអស់នេះនឹងពិនិត្យនៅពេលក្រោយ។

**អ្នកបកប្រែ៖**

លោកប្រធាន ៗអ្នកបកប្រែសូមឲ្យមេធាវីគាត់កុំឲ្យនិយាយក្បែរមីក្រូពេក ព្រោះអីអ្នកបកប្រែបុកត្រចៀកខ្លាំងពេកស្តាប់អត់ឮទេ។

**លោកស្រី អង់តា ហ្គីសសេ៖**

-- ទាក់ទងទៅនឹងផែនទី និងរូបថត មេធាវីអន្តរជាតិ អាប់ឌុលឡាក់ បានផ្តល់ទឡ្ហីករណ៍ដែលថា អាចជំទាស់បាន ដែលគាត់និយាយថា យើងមិន ខាងភាគីការពារក្តីមិនត្រូវជំទាស់លើឯកសារទាំងអស់នោះទេ។ អ៊ីចឹង ខ្ញុំគិតថា នេះគឺជាទឡ្ហីករណ៍មិនសមរម្យទេ ពីព្រោះថា កម្មវត្ថុនៃសវនាការយើងនេះ គឺថាពិភាក្សាឧបសម្ព័ន្ធទាំងអស់ពីមួយទៅមួយ ហើយខ្ញុំគិតថាមិនមែនជា គឺថាវាមិនមានប្រយោជន៍សម្រាប់តុលាការនោះទេ បើសិនជាយើងមិនពិភាក្សាពីឧបសម្ព័ន្ធពីមួយទៅមួយទេហ្នឹង។ ខ្ញុំគិតថា សុំឲ្យខាងសហព្រះរាជអាជ្ញាហ្នឹងយល់ឲ្យច្បាស់អំពីបញ្ហានេះ គឺថាយើងត្រូវតែផ្តល់ឧទាហរណ៍ទាក់ទងនឹងការជំទាស់របស់យើងគ្រប់ការជំទាស់។

ទាក់ទងនឹងឧបសម្ព័ន្ធ១៦ គឺទាក់ទងវីដេអូ គឺឯកសារ D3039R ហើយនិង 10R, 11R ត្រង់ចំណុចនេះគឺថា សហភាតារបស់ខ្ញុំបាននិយាយដោយខ្លី ខ្ញុំ-- ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កាលពីម្សិលមិញនេះ ហាក់ដូចជាគ្មានប្រយោជន៍អីទេ ពីព្រោះថាចំពោះយើងមិនមែនមានន័យថា យើងមិនមែនជំទាស់ថារឿងថា រូបដែលនៅក្នុងវីដេអូហ្នឹងមិនមែនរូប ខៀវ សំផន ទេ យើងដឹងហើយ-- ព្រោះថា រូបវាច្បាស់ហើយ ហើយដឹងថា រូបនេះមកពីណា? ធ្វើនៅទីណា? អ្នកណាអ្នកសួរលោក ខៀវ សំផន? ក៏ប៉ុន្តែដោយសារតែឯកសារនេះមានតែជាភាសាខ្មែរនោះ ខ្ញុំមិនយល់ពីខ្លឹមសារនៃខ្សែវីដេអូនោះទេ ពីការសម្ភាសគាត់នោះទេ។ តើមានការកាត់តឬក៏យ៉ាងម៉េច? អ៊ីចឹងគឺថា ការជំទាស់របស់យើងនៅត្រង់ចំណុចនេះហើយ ហើយមិនមែនជំទាស់ដោយមូលហេតុថា អានេះមិនមែនជារូបលោក ខៀវ សំផន នោះទេ។

[១០:២៣:៤៥]

ចំណុចមួយទៀត គឺថាទាក់ទងទៅនឹងឧបសម្ព័ន្ធ១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ប្រហែលជាមានការ-- ភាពចម្រូងចម្រាសទាក់ទងទៅនឹងឯកសារទំនាក់ទំនងអន្តរជាតិ នៅ

ពេលដែលឆ្លើយតបទៅនឹងបណ្ណសារបារាំង។ ហើយគាត់ ៗបាននិយាយប្រាប់យើងថា នេះជាបញ្ជីរបស់ក្រុមខៀវ សំផន ផ្ទាល់ ហើយខ្ញុំសូមរំឭកថា នេះគឺជាចំណុចសំខាន់ គឺនៅពេលនោះ យើងបានស្នើបញ្ជីឯកសារនោះ ដែលទាក់ទងទៅនឹងសាក្សីដែលយើងចង់ឲ្យអង្គជំនុំជម្រះស្តាប់។ ក៏ប៉ុន្តែយើងសូមរំឭកៗទៅឯកសារមួយ ឯកសារ E9/29.2 និង E109/1.1 និងសេចក្តីប្រកាសរបស់សាក្សី TCW-56 នៅក្នុងឯកសារ E9/11.2 ដែលនៅក្នុងឯកសារនេះមានការលើកឡើងថា សាក្សីនេះនឹងនិយាយអំពីបណ្ណសារបារាំងដែលមានតាំងពីឆ្នាំ១៩១៥ មក។ ដូច្នេះ ខាងក្រុម ខៀវ សំផន នឹងបង្ហាញឯកសារទាំងអស់នេះដោយមានវត្តមានរបស់គាត់ នេះគឺជារបៀបវិធីសាស្ត្រមួយដែលប្លែក ខ្ញុំយល់ឃើញថាជាការចាប់អារម្មណ៍សម្រាប់ចៅក្រម ចំពោះមុខងាររបស់យើង តួនាទីរបស់យើងដែលថាការពារក្តីកូនក្តីរបស់យើង ហើយនិងផ្តល់ព័ត៌មាន ដើម្បីឲ្យអស់លោកចៅក្រមធ្វើការកាត់សេចក្តី។ បើខ្ញុំសូមរំឭកម្តងទៀតថា នៅពេលដែលខ្ញុំបានលើកអំពីការជំទាស់នេះ គឺថាគោលបំណងមិនមែនថាផ្តល់ឯកសាររាប់តោនទៅឲ្យតុលាការនោះទេ ប៉ុន្តែសូមឲ្យជ្រើសរើសយកព័ត៌មាន ឬក៏ឯកសារដែលអស់លោកចៅក្រមនឹងយកទៅពិចារណា ហើយដើម្បីធ្វើសេចក្តីសម្រេចនៅពេលក្រោយ។

សូមអរគុណ ខ្ញុំសូមបញ្ចប់ត្រឹមនេះ។

[១០:២៦:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ។

**លោកស្រី អង់តា ហ្គីសសេ៖**

សូម-- ដោយសារខ្ញុំច្រឡំអម្បាញ់មិញ គឺថាខ្ញុំច្រឡំ គឺថាឮ គឺសាក្សី TCW-156 ទេ នេះ ដើម្បីខាងប្រតិចារឹកកត់កែតម្រូវ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលវេលាសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពលោកប្រធាន ហើយនិងលោក លោកស្រីចៅក្រម ដោយសារបញ្ហាសុខភាព ជាពិសេសបញ្ហា--

**ប្រធានអង្គជំនុំ៖**

ឈប់សិន! អ្នកណាគេជជែកគ្នាអីហ្នឹង? មានឮសំឡេងជជែកគ្នាអី រំខានដល់អ្នកដទៃកំពុងតែធ្វើអត្ថាធិប្បាយ។ សូមបញ្ឈប់ជាបន្ទាន់នូវការជជែករបៀបនេះ។

[១០:២៧:៥១]

**លោក អាង ឧត្តម៖**

ខ្ញុំបាទសូមចាប់ផ្តើមទាន សាថ្មី។ ដោយសារបញ្ហាសុខភាព ជាពិសេសបញ្ហាឈឺចង្កេះឆ្អឹងខ្នង ហើយនិងហើមជើងផង ដែលមិនអាចទ្រាំអង្គុយនៅទីនេះបាន លោក អៀង សារី ពេលនេះស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់នៅបន្ទប់សវនាការសម្រាប់មួយថ្ងៃនេះពេញ ប៉ុន្តែសុំចូលរួមដោយប្រយោលពីបន្ទប់រង់ចាំនៅខាងក្រោម។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

[១០:២៨:២០]

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ នៅក្នុងសម្រាប់ថ្ងៃនេះចាប់ពីពេលនេះតទៅ ហើយសូមទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោម បន្ទប់សវនាការនេះ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយតាមដានក្នុងកិច្ចដំណើរការសវនាការបាន។

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ ដោយទៅតាមដានកិច្ចដំណើរសវនាការពីចម្ងាយ ពីបន្ទប់ស្ថិតខាងក្រោមបន្ទប់សវនាការ តាមរយៈឧបករណ៍សោតទស្សន៍។ អង្គជំនុំជម្រះតម្រូវឱ្យមេធាវីការពារក្តីជនជាប់ចោទប្រគល់មកឱ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមក្នុងបន្ទប់សវនាការ ដែលធ្វើឡើងដោយជនជាប់ចោទ។ បង្គាប់ឱ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទតាមដានកិច្ចដំណើរការ

សវនាការពីចម្ងាយសម្រាប់សវនាការថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោមចុះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:២៩ នាទី ដល់ម៉ោង ១០:៤៩ នាទី)*

[១០:៤៩:១៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តនេះគឺ អង្គជំនុំជម្រះស្តាប់នូវសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងកិច្ចដំណើរសវនាការពិភាក្សាដេញដោលនៅក្នុងសប្តាហ៍ក្រោយ ដែលគ្រោងនឹងប្រព្រឹត្តទៅក្នុងការស្តាប់សួរចម្លើយជនជាប់ចោទ នួន ជា ដែលទន្ទឹមគ្នានោះ គឺអាចនឹងដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ហើយប៉ុន្តែដោយសារបញ្ហាពេលវេលា ដោយសារនៅរសៀលនេះ អង្គជំនុំជម្រះមានបំណងបញ្ចប់នូវរបៀបវារៈនៃបញ្ហាទាំងឡាយ ដែលយើងលើកមកធ្វើកិច្ចពិភាក្សានៅក្នុងដំណើរការសវនាការមួយសប្តាហ៍នេះ ហើយប្រសិនបើជាការពន្យារពេលទៅដល់ថ្ងៃចន្ទនោះ ក៏ដូចជាមិនទំនងដែរ ពីព្រោះរបៀបវារៈនៅតែមួយទៀតទេ។

[១០:៥០:៣០]

ដូច្នេះ សូមភាគីដែលពាក់ព័ន្ធនឹងបញ្ហាទាំងអស់ សូមកំហិតនូវពេលវេលាដែលបែងចែកឲ្យ។ ហើយម្សិលមិញ គឺខាងក្រុមមេធាវីការពារក្តី នួន ជា មានបំណងស្នើសុំពី១០ ទៅ១៥ នាទី។ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសនៅក្នុងការឡើងធ្វើសំណើសុំ។ ហើយក្រុមមេធាវីការពារក្តីមានពេលវេលាអតិបរមា១៥នាទី ប៉ុណ្ណោះ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ តើខ្ញុំត្រឹម-- លើកឡើងត្រឹមត្រូវដែរឬទេ ថាយើងនៅមានសល់ប្រធានបទពីរ ដែលយើងនៅពិភាក្សានៅក្នុងថ្ងៃនេះ។ ទីមួយគឺប្រធានបទ ដែលខ្ញុំនឹងស្នើសុំនេះ ពាក់ព័ន្ធនឹង ឌុច ដែលមកផ្តល់សក្ខីកម្មនៅពេលរសៀលថ្ងៃចន្ទ។ បញ្ហាប្រធានបទទីពីរ គឺបញ្ហាពាក់ព័ន្ធ

ទៅនឹងប្រព័ន្ធសោតទស្សន៍ ដែលផ្តល់សក្ខីកម្មតាមរយៈ ប្រព័ន្ធសោតទស្សន៍នេះ ដោយ ប៉ែន យៀរនិន។

ដូច្នេះ ខ្ញុំគិតថាអ្វីដែលខ្ញុំបញ្ជាក់នេះពិតជាត្រឹមត្រូវ។ យើងនៅសល់ប្រធានបទចំនួនពីរ។

[១០:៥១:៥៦]

យើងប្រហែលជាសូមលើកឡើងនូវសំណើរបស់ខ្ញុំ ដែលយើងខ្ញុំសូមបញ្ជាក់ ឌុច នឹងមកផ្តល់សក្ខីកម្មនៅក្នុងសប្តាហ៍ក្រោយ។ ជាបឋម ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់លាស់ថា ឌុច គឺជាសាក្សីសំខាន់សម្រាប់កូនក្តីរបស់យើងខ្ញុំ។ ឌុច គឺជាបុគ្គលមួយរូបដែលអាចផ្តល់សក្ខីកម្មដាក់បន្ទុកមកលើកូនក្តៅរបស់យើងខ្ញុំ។ ក៏ប៉ុន្តែយើងខ្ញុំមានបំណងសូមបញ្ជាក់ថា គាត់នោះមិនមានអ្វីច្រើនត្រូវលើកឡើង តាមអ្វីដែលយើងដឹង មិនមានអ្វីច្រើនត្រូវលើកឡើងពាក់ព័ន្ធទៅនឹងការជំនុំជម្រះគូចវគ្គដំបូងរបស់យើងនេះនោះទេ។ ជាពិសេសដោយសារតែវគ្គដំបូងនេះ គឺមិនពាក់ព័ន្ធទៅនឹងស-២១ ការបោសសម្អាតផ្ទៃក្នុងកើតឡើងនៅក្នុងឆ្នាំ១៩០០-- ទសវត្សរ៍ឆ្នាំ១៩៧០។ គឺគាត់បានដឹង គឺគាត់នៅក្នុងប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧៥ ថ្ងៃទី១៧ ខែមេសា ហើយគឺគាត់ដឹងតិចតួចណាស់អំពីការជម្លៀសផ្លាស់ទីលំនៅប្រជាជននៅក្នុងឆ្នាំ១៩៧៥-៧៦។

[១០:៥៣:២១]

យើងអាចលើកឡើងអំពីបញ្ហាភស្តុតាងពាក្យចចាមអារ៉ាម ដែលភស្តុតាងពាក្យចចាមអារ៉ាមនេះគឺអាចជាប់ប្រឡាក់ប្រឡូសនឹងទារុណកម្មផងដែរ។ នៅពេលដែលខ្ញុំលើកឡើងដូច្នេះ យ៉ាងនេះក៏ដោយក៏បុគ្គលនេះ ឌុច ហ្នឹង គឺនៅតែជាសាក្សីសំខាន់ដដែល។ ហើយយើងនឹងសួរគាត់នូវអ្វីដែលបានកើតឡើងនៅពេលដែលអង្គជំនុំជម្រះបានសម្រេចស្តាប់សក្ខីកម្មរបស់គាត់នៅថ្ងៃចន្ទ រសៀល។ កូនក្តីរបស់ខ្ញុំ គឺតែងតែបោះបង់សិទ្ធិរបស់គាត់មិនចូលរួមដោយផ្ទាល់នៅក្នុងពេលរសៀល។ ដូច្នេះបានន័យថា យើងនឹងមិនមានវត្តមានកូនក្តីរបស់ខ្ញុំចូលរួមដោយផ្ទាល់ នៅពេលសាក្សីនេះមកផ្តល់សក្ខីកម្ម។ ក៏ប៉ុន្តែសាក្សីនេះសំខាន់ ដូច្នេះហើយកូនក្តីរបស់ខ្ញុំ គាត់សូមវត្តមាននៅពេលរសៀលថ្ងៃចន្ទ ដោយសូមចូលរួមដោយផ្ទាល់។

[១០:៥៤:២៤]

ខ្ញុំសូមធ្វើការពន្យល់ដល់អង្គជំនុំជម្រះថា លោក នួន ជា មានសិទ្ធិមានវត្តមានដោយផ្ទាល់នៅពេលដែល ឌុច មកផ្តល់សក្ខីកម្ម ហើយគាត់ក៏មានសិទ្ធិតទល់ជាមួយនឹងសាក្សីជាពិសេសសាក្សីដែលសំខាន់ដូចរូប ឌុច នេះជាដើម។

ខ្ញុំអាចយោងទៅលើវិធាន ក្នុងវិធាន៨១ ច្បាប់ អ.វ.ត.ក លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ អាយ.ស៊ី.ស៊ី.ភី.អ័រ មាត្រា១៤ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៩៧ ដែលមានចែងសិទ្ធិមូលដ្ឋានថា "ជនជាប់ចោទមានសិទ្ធិតទល់សាក្សីដោយផ្ទាល់ និងនៅចំពោះមុខ"។ សិទ្ធិនេះនឹងត្រូវបានរំលោភនៅពេលដែលខ្លួនមិនមានសិទ្ធិតវ៉ា តទល់ទៅនឹងសក្ខីកម្មរបស់សាក្សី។ នៅក្នុងថ្ងៃចន្ទ អាទិត្យក្រោយអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្ម ឌុច ហើយកូនក្តីរបស់ខ្ញុំគឺគាត់មិនមានវត្តមានដោយផ្ទាល់តទល់ជាមួយនឹងសាក្សីរូបនេះ។ ការឲ្យគាត់តាមដានពីបន្ទប់រង់ចាំខាងក្រោយមិនមែនជាដំណោះស្រាយមួយល្អនោះទេ។ លោក កាណាវាស បានលើកឡើងកាលពីម្សិលមិញរួចមកហើយ បន្ថែមទៅលើចំណុចនោះ ខ្ញុំសូមបញ្ជាក់ទៀតថា វាមានហេតុផលចម្បងចំនួនបី ដែលហេតុអ្វីបានជាបន្ទប់រង់ចាំនេះមិនមែនជាដំណោះស្រាយមួយល្អចំពោះបញ្ហាដូចដែលខ្ញុំបានលើកឡើងខាងដើម។

[១០:៥៦:០៧]

បើទោះជាមាន-- ជនជាប់ចោទមានលទ្ធភាពតាមដានដំណើរការសវនាការតាម *វីដេអូលីង* ក៏ដោយ តាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់ខាងក្រោមក៏ដោយ វាមិនមានភាពចាំបាច់ដែលបង្ហាញថា កូនក្តីរបស់ខ្ញុំចូលរួមដោយប្រសិទ្ធភាពនោះឡើយ។ ប្រសិនបើយើងមើលវិធាន៨១(៥)ៗ នៅក្នុងនោះគឺយើងឃើញមានជនជាប់ចោទព្រួយបារម្ភទៅលើលក្ខខណ្ឌមួយចំនួន នៅក្នុងការបន្តតាមដានសវនាការរបស់ខ្លួន ជាពិសេសនៅពេលដែលគាត់នៅបន្ទប់រង់ចាំ។ ហេតុផលមួយទៀត ហេតុអ្វីបានជាបន្ទប់រង់ចាំមិនមែនជាដំណោះស្រាយនោះ? គឺវាមិនមានជាការពន្យារពេល នួន ជា គឺគាត់ចង់មានវត្តមាននៅក្នុងតុលាការ ហើយគឺគាត់ចង់ឲ្យ ឌុច នេះមកផ្តល់សក្ខីកម្មនៅពេលព្រឹកវិញ ដើម្បីឲ្យកូនក្តីរបស់ខ្ញុំចូលរួមដោយប្រសិទ្ធភាព។

[១០:៥៧:១៦]

ហើយបន្ទាប់មកសាក្សីអាចផ្សេងអាចមកផ្តល់សក្ខីកម្មនៅពេលរសៀលបាន។ ប្រសិនបើសាក្សីផ្សេងមកផ្តល់សក្ខីកម្ម កូនក្តីរបស់ខ្ញុំសូមបន្តបោះបង់សិទ្ធិមិនចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។ ហេតុផលទីបី ក៏ជាហេតុផលសំខាន់ ទោះបីជានៅក្នុងបន្ទប់រង់ចាំក៏ដោយ ជាពិសេសនៅក្នុងបន្ទប់រង់ចាំនេះ ខ្ញុំគួរតែនិយាយអ៊ីចឹង កូនក្តីរបស់ខ្ញុំនោះនៅក្នុងបន្ទប់ហ្នឹងមិនបានចូលរួមដោយប្រសិទ្ធភាពក្នុងកិច្ចដំណើរការនីតិវិធីនេះទេ។ ហើយវាមិនមែនជាលក្ខខណ្ឌនៃវិធាន៨១(៥) នោះឡើយ។ នួន ជា ត្រូវបានបញ្ជូនទៅបន្ទប់រង់ចាំខាងក្រោម មិនមែនថា គាត់ចង់បន្តតាមដាននីតិវិធីពីបន្ទប់ខាងក្រោមនោះទេ។

[១០:៥៨:០៦]

កូនក្តីរបស់ខ្ញុំត្រូវបានបញ្ជូនទៅបន្ទប់ខាងក្រោមនោះ គឺដោយសារតែគាត់មិនមានលទ្ធភាពបន្ត តាមដានសវនាការនៅក្នុងបន្ទប់នេះ ឬក៏នៅបន្ទប់ខាងក្រោម គាត់មិនមានសុខភាពល្អ។ ដូច្នេះហើយ គាត់មិនមានសិទ្ធិចូលរួមដោយប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការនីតិវិធី។ យើងចាំហើយកាលពីប៉ុន្មាន សប្តាហ៍មុន គឺយើងបានជម្រាបអង្គសវនាការអំពីលក្ខខណ្ឌស្ថានភាពរបស់កូនក្តីរបស់ខ្ញុំ ដែលកូនក្តី របស់ខ្ញុំនោះគឺគាត់តែងតែសម្រាន្តនៅបន្ទប់ខាងក្រោម។ ខ្ញុំសូមបញ្ជាក់ឡើងវិញថា វាតែងតែកើតឡើង នៅពេលដែលគាត់ត្រូវបានបញ្ជូនទៅបន្ទប់រង់ចាំនៅខាងក្រោម គឺគាត់សម្រាន្តលក់។ ខ្ញុំមិនចាំបាច់ពន្យល់ នោះទេ ដូច្នេះបានន័យថា នៅពេលដែលគាត់សម្រាន្តលក់ គឺគាត់មិនបានតាមដាននីតិវិធីដោយមាន ប្រសិទ្ធភាពនោះឡើយ។

[១០:៥៨:៥៥]

យើងបានជម្រាបអំពីស្ថានភាពកូនក្តីរបស់ខ្ញុំ ក៏ប៉ុន្តែលោក លោកស្រីចៅក្រមត្រូវតែដឹងថា តាម អនុលោមតាមវិធានផ្ទៃក្នុង និងតាមវិធាន គឺស្ថានភាពស្មារតីកូនក្តីរបស់ខ្ញុំទោះបីនៅបន្ទប់ខាងក្រោមក៏ ដោយគាត់មិនបានចូលរួមដោយប្រសិទ្ធភាពនៅក្នុងសវនាការនេះទេ។ មិនថា តាមរយៈប្រព័ន្ធសោត ទស្សន៍ ឬក៏ទាក់ទងយើងខ្ញុំតាមទូរស័ព្ទយ៉ាងណាក៏ដោយ។

សេចក្តីសម្រេចដែលបានលើកឡើងចំពោះបញ្ហានេះ គឺសេចក្តីសម្រេចរបស់តុលាការកំពូល តុលាការ អាយ.ស៊ី.ធី.វ៉ាយ រឿងក្តី ស្តានីស៊ីក។ ប្រសិនបើអង្គជំនុំជម្រះពេញចិត្តនឹងចង់បាននោះ គឺខ្ញុំ នឹងផ្តល់លេខកូដសេចក្តីសម្រេចនេះ គឺ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៨ លើកឡើងអំពីបញ្ហានេះ។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តីនោះ គឺគេបង្កើតបន្ទប់ប្រព័ន្ធសោតទស្សន៍នៅក្នុងបន្ទប់ឃុំឃាំង ដើម្បីឲ្យជនជាប់ចោទតាមដាននីតិវិធី ដែលនីតិវិធីនេះកើតឡើងនៅកន្លែងផ្សេង។

អង្គជំនុំជម្រះតុលាការកំពូលនៅទីនោះ បានលើកឡើងថា-- បានមោឃភាពសេចក្តីសម្រេច របស់សាលាដំបូង ហើយឲ្យសាលាដំបូងធ្វើការកែប្រែសេចក្តីសម្រេចរបស់ខ្លួន ដោយឈរលើមូល ហេតុចំនួនបី។ ទីមួយ អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់សិទ្ធិទៅដល់ជនជាប់ចោទក្នុងការមាន វត្តមានដោយផ្ទាល់។ អង្គជំនុំជម្រះសាលាដំបូងមិនបានថ្លឹងថ្លែងអំពីបញ្ហានេះឲ្យបានត្រឹមត្រូវ។ បន្ថែម ទៅលើចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានមើល ជម្រើសផ្សេង ដោយប្រើប្រាស់ប្រព័ន្ធសោតទស្សន៍នេះ។ អង្គជំនុំជម្រះសាលាដំបូងគួរតែផ្អាកនីតិវិធីនេះ

តាំងពីដំបូង សម្រាប់រយៈពេលបីទៅប្រាំមួយខែ ដើម្បីឲ្យជនជាប់ចោទនេះពិនិត្យមើលស្ថានភាពថា តើគាត់ហ្នឹងអាចល្អឡើងវិញដែរទេ ឲ្យគាត់តាមដាននីតិវិធី? បីទៅប្រាំមួយខែ រយៈពេលដែលគេស្នើសុំនោះ គឺមិនបានធ្វើការពិចារណា ដែលបានលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូល។

[១១:០១:២៥]

ចំណុចចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើង វាជាចំណុចសំខាន់ពាក់ព័ន្ធទៅនឹងអង្គជំនុំជម្រះយើងផងដែរ។ ដោយលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងគួរតែធ្វើការស៊ើបអង្កេតជនជាប់ចោទរូបនោះ ថាតើគាត់មានលទ្ធភាពចូលរួមតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំឃាំងនោះដែរឬទេ? នៅខណៈពេលដែលគាត់នុំង មិនមានលទ្ធភាព មានសុខភាពមិនល្អចូលរួមក្នុងតុលាការ។

ដូច្នេះ បានន័យថា ជនជាប់ចោទនោះក៏មិនមានលទ្ធភាពតាមប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំឃាំងផងដែរ។ ហើយអង្គជំនុំជម្រះសាលាដំបូងតាមការលើកឡើងនោះ គឺមិនបានស៊ើបអង្កេតទៅលើបញ្ហានេះ។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះពិចារណាទៅលើចំណុចនេះ។ ដើម្បីសន្និដ្ឋានបញ្ចប់ ជនជាប់ចោទរបស់យើងខ្ញុំ គឺ នួន ជា គឺគាត់នឹងមិនអាចលទ្ធភាពចូលរួមសវនាការដោយផ្ទាល់នៅក្នុងរសៀលថ្ងៃចន្ទនោះទេ។ គឺគាត់មិនមានសម្បទាគ្រប់គ្រាន់ចូលរួមក្នុងនីតិវិធីសវនាការ ជាពិសេសនៅពេល-- នៅក្រោយពេលដែលតុលាការសួរចម្លើយគាត់ នៅពេលព្រឹករួចហើយនោះ វានឹងឲ្យកូនក្តីរបស់ខ្ញុំមានការហត់នឿយ។ ហេតុដូច្នេះ គឺខ្ញុំសូមឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាទៅលើបញ្ហានេះ នៅពេលដែលកំណត់កាលវិភាគនៅសប្តាហ៍ក្រោយ។

[១១:០២:៥១]

ខ្ញុំគិតថា នឹងមានដំណោះស្រាយផ្សេងចំពោះបញ្ហានេះ។ ក៏ប៉ុន្តែខ្ញុំសូមស្នើថាយើងគួរស្តាប់សក្ខីកម្ម ឌុច នៅពេលព្រឹក ហើយបន្ទាប់ពីយើងបញ្ចប់សក្ខីកម្ម ឌុច នោះ គឺយើងបន្តស្តាប់ចម្លើយ-- សួរចម្លើយកូនក្តីរបស់យើងខ្ញុំ។ ការធ្វើដូច្នេះ គឺវាអាចធានាសិទ្ធិរបស់កូនក្តីរបស់ខ្ញុំចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ និងធានានូវសិទ្ធិតទល់របស់កូនក្តីរបស់យើងខ្ញុំផងដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមនិយាយសង្ខេបទៅនៅត្រង់ចំណុចនេះ។ ខ្ញុំជឿជាក់ខ្លួនឯងថា

ខ្ញុំឮសួរមេធាវីការពារក្តីថា ប៉ុន្មានថ្ងៃមុននេះ គាត់បានដឹងថា ឌុច នឹងត្រូវសួរចម្លើយនៅសប្តាហ៍ក្រោយនេះ។ អ្វីដែលគាត់លើកឡើងនោះ គឺមិនត្រឹម-- គឺកម្មវិធី គឺបានប្រកាសនៅមុនពេលសម្រាកឈប់សម្រាកពីរបីសប្តាហ៍មុននេះ ដោយមានការពន្យល់ថាសួរជនជាប់ចោទនៅព្រឹក និងសួរសាក្សីនៅពេលរសៀល ដែលចាប់ផ្តើមជាមួយនឹង ឌុច មុនគេ។

[១១:០៤:២៥]

ខ្ញុំមិនច្បាស់ទេ ហេតុអ្វីបានជាមេធាវីការពារក្តីនិយាយអំពីភាពពាក់ព័ន្ធរបស់ ឌុច នៅក្នុងរឿងក្តីនេះ។ ដោយសារសាក្សីនេះ គឺថាអាចនឹងមាននិយាយពាក់ព័ន្ធទៅនឹងប្រវត្តិសាវតារ ហើយពាក់ព័ន្ធទៅនឹងសវនាការបន្តបន្ទាប់។ មេធាវីការពារក្តីហាក់បីដូចជាមិនបានលើកឡើង ថាតើរដ្ឋាភិបាលបង្កើតឡើងដោយរចនាសម្ព័ន្ធ បង្កើតឡើងដោយរបៀបណា? អង្គការបង្កើតឡើងដោយរបៀបណា? ហើយនិងការប្រាស្រ័យទាក់ទងទំនាក់ទំនងនោះ គេធ្វើឡើងដោយរបៀបណា?

បញ្ហានេះ គឺមិនពាក់ព័ន្ធដោយផ្ទាល់នៅក្នុងពេលនេះនោះទេ ដោយសារថាបើមិនធ្វើ ដូចមេធាវីការពារក្តីលើកឡើង ថាបើសិនណាមិនធ្វើដូច្នេះនឹងរំលោភទៅដល់សិទ្ធិរបស់ជនជាប់ចោទ បើសិនសួរ ឌុច នៅពេលព្រឹកនោះទេ។ ដោយសារថា គាត់មាន ជនជាប់ចោទមានសិទ្ធិមានវត្តមាន និងមានសិទ្ធិសួរតទល់ជាមួយនឹងសាក្សី។

[១១:០៥:៤១]

គឺបញ្ហាហ្នឹង គឺថាតើ នួន ជា មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការនេះទាំងព្រឹកនិងល្ងាចបានឬទេ? ដោយសារថាយើងមានសវនាការទៅលើបញ្ហានេះកាលពីឆ្នាំមុន គឺសវនាការដ៏វែងអន្លាយ។ ហើយតុលាការបានស្នើសុំឱ្យអ្នកជំនាញធ្វើការវាយតម្លៃទៅលើសម្បទា នួន ជា អ្នកជំនាញថា នួន ជា មានសុខភាពអាចចូលរួមបាន មិនមានមូលដ្ឋានណាដែលបញ្ជាក់ថា នួន ជា មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុង-- មិនអាចចូលរួមនៅក្នុងសវនាការបាននោះទេ។ ដូចជាថ្ងៃនេះជាដើមបង្ហាញឱ្យឃើញថា គាត់មានសម្បទាគ្រប់គ្រាន់ចូលរួមនៅក្នុងសវនាការ។

ខ្ញុំគត់សម្គាល់ឃើញថា ជម្រើសគឺថាអាចនឹងមានសម្រាប់ជនជាប់ចោទ ដោយឱ្យជនជាប់ចោទចុះទៅបន្ទប់រង់ចាំខាងក្រោមតាមដានសវនាការពីទីនោះមក។ ហើយបើគាត់-- អាហ្នឹងបើគាត់ចង់តាមដានដំណើរការនីតិវិធី។ នេះក៏ជានីតិវិធីមួយដែលល្អដែរ។ ប៉ុន្តែនេះមិនមែនអ្វីដូចគ្នាទៅនឹងអ្វី ថាបើសិនណាជាជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់នោះទេ។

[១១:០៧:០០]

នួន ជា ពិតជាមានសម្បទាគ្រប់គ្រាន់ មិនមានកោសល្យវិច័យវេជ្ជសាស្ត្រណាមួយបញ្ជាក់ថា គាត់មិនមានសម្បទានោះទេ។ ជាតាមពិតហើយ គឺថាអង្គជំនុំជម្រះបានបើកសវនាការប៉ុន្មានថ្ងៃ ហើយ នៅពេលដែលជនជាប់ចោទមានវត្តមានទាំងព្រឹកទាំងល្ងាចនោះ។ នៅពេលមួយ គឺថាជនជាប់ចោទត្រូវ បានសួរចម្លើយទាំងព្រឹក និងទាំងរសៀល ហើយក្នុងពេលមួយនោះ គឺថាត្រូវបានសួរចម្លើយនៅពេល ព្រឹក គាត់ក៏មានវត្តមាននៅពេលរសៀលដើម្បីស្តាប់សាក្សីដែរ។ ដូច្នេះ និយាយឲ្យងាយស្រួលទៅ គឺថា មិនមានហេតុផលណានៅក្នុងពេលនេះ ដែលថាតុលាការត្រូវធ្វើការសម្រេចផ្សេងពីរនេះ ដែលថា នួន ជា មិនមានសម្បទាដើម្បីចូលរួមនៅក្នុងពេលរសៀលនោះទេ។

[១១:០៨:០២]

ប្រសិនណា បញ្ហានេះវាមានការប្រែប្រួល ជំហររបស់យើងខ្ញុំគឺថាយើងនឹងចាប់ផ្តើមរហូតដល់ ពេលយើងជួបប្រទះទៅនឹងបញ្ហានេះតែម្តង។ មានន័យថា ជនជាប់ចោទមានសុខភាពទ្រុឌទ្រោមមែន ទែន ឬក៏ឈឺធ្ងន់ ពេលនោះគឺថាយើងនឹងអាចមានការបត់បែនទៅតាមស្ថានភាពនេះ។ ប៉ុន្តែយើងត្រូវ ពេលនេះគឺយើងត្រូវធ្វើទៅតាមកាលវិភាគដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះ សម្រាប់ដំណើរការ នីតិវិធីនៅសប្តាហ៍ក្រោយ ដែលត្រូវសួរ នួន ជា នៅពេលព្រឹក និងសួរ-- ស្តាប់សក្ខីកម្ម ឌុច នៅពេល រសៀល។ រហូត និងលុះណាតែយើងជួបប្រទះបញ្ហា ដែលថាជនជាប់ចោទមិនអាចចូលរួមនៅក្នុង ដំណើរការនីតិវិធីបាន នេះក៏ត្រូវតែបញ្ជាក់ដោយគ្រូពេទ្យ។ នេះគឺជាបញ្ហាដែលយើងត្រូវធ្វើការកែប្រែ ទៅនឹងនាទីចុងក្រោយទៅនឹងអ្វីដែលតុលាការបានកំណត់រួចហើយ។

[១១:០៩:០០]

ដូច្នេះយោបល់យើងខ្ញុំ គឺថា យើងត្រូវធ្វើដំណើរការនីតិវិធីដូចដែលបានត្រៀមទុក ដើម្បីបន្ត និរន្តរភាពបែបនេះតទៅទៀត លុះណាតែជនជាប់ចោទមានបញ្ហាដល់នាទីចុងក្រោយដែលយើងជួប ប្រទះនោះ។

ទាក់ទងទៅនឹងបន្ទប់រង់ចាំបំពាក់ប្រព័ន្ធសោតទស្សន៍និវត្តនៅខាងក្រោមនេះ ប្រសិនណា នួន ជា គាត់ចង់ចូលរួមនៅក្នុងបន្ទប់សវនាការនេះតែម្តង គាត់មានសិទ្ធិធ្វើដូច្នេះបាន។ បើគាត់ចង់ទៅតាមដាន ដំណើរការនីតិវិធីនៅខាងក្រោម ក៏មាននីតិវិធីអនុញ្ញាតឲ្យគាត់ធ្វើដូច្នេះបាន និងបើសិនណាជាគាត់មិន មានលទ្ធភាពតាមដាននៅពេលរសៀលដោយផ្ទាល់ទីនេះ។ ប៉ុន្តែនេះជានីតិវិធីនៃការបោះបង់សិទ្ធិ គឺ នួន

ជា មានសិទ្ធិ គ្មានអ្នកណាមានសិទ្ធិឃាត់ នួន ជា មិនឲ្យមានវត្តមាននៅក្នុងបន្ទប់សវនាការនេះបានទេ។ ហើយលុះណាតែគ្រូពេទ្យបញ្ជាក់ថា គាត់មិនមានសុខភាពគ្រប់គ្រាន់ នោះទើបយើងធ្វើការកែប្រែទៅនឹងអ្វីដែលបានរៀបចំហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មេធាវីនាំមុខមានបញ្ហាអីទេ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ មេធាវីនាំមុខបានស្តាប់នូវការលើកឡើងរបស់មេធាវីរបស់ក្រុមការពារលោក នួន ជា ហើយនិងក៏បានស្តាប់នូវអ្វីដែលជាការលើកឡើងរបស់សហព្រះរាជអាជ្ញា យើងខ្ញុំយល់ថា យើងខ្ញុំយល់ថា យើងខ្ញុំគាំទ្រនូវអ្វីដែលខាងសហព្រះរាជអាជ្ញាបានលើកឡើងថាជាការសមហេតុផល។ សមហេតុផល ដោយសារថា ករណីលោក នួន ជា ត្រូវបានការកោសល្យវិច័យតាមលក្ខណៈវេជ្ជសាស្ត្របញ្ជាក់ថា គាត់មានសមត្ថភាពនៅក្នុងការចូលរួមរួមគ្រប់គ្រាន់រួចហើយ។ ហើយម្យ៉ាងទៀត ការមាន-- គាត់មានសិទ្ធិនៅក្នុងការចូលសវនាការនៅក្នុងបន្ទប់ខាងក្រោម ដែលជាវិធីមួយដែលមានអនុញ្ញាតដោយវិធានផ្ទៃក្នុង។ ហើយម្យ៉ាងទៀត ក៏មានទូរស័ព្ទទំនាក់ទំនងនៅក្នុងករណីដែលគាត់ត្រូវការទាក់ទងមកមេធាវីរបស់គាត់ គាត់អាចមានសិទ្ធិនៅក្នុងការទំនាក់ទំនងមកមេធាវីរបស់គាត់ ដើម្បីសួរឆ្លើយទៅលើលោក ឌុច ថែមទៀតផង។

[១១:១១:២៨]

ដូច្នេះ គាត់នៅតែមានសិទ្ធិនៅក្នុងការចូលរួមនៅក្នុងសវនាការដដែល គ្រាន់តែគាត់មានសិទ្ធិ-- អ៎ គាត់អាចចូលរួមពីបន្ទប់ខាងក្រោមតែប៉ុណ្ណោះ។ ហើយម្យ៉ាងទៀត ប្រសិនបើករណីដែលថា គាត់បានចូលរួមពីព្រឹកហើយ ហើយនៅពេលល្ងាចគាត់លើកថា គាត់មិនមានសុខភាពគ្រប់គ្រាន់ ឬក៏មិនមានលទ្ធភាពក្នុងការពិចារណា អ៎នៅក្នុងការប្រមូលអារម្មណ៍ដើម្បី តាមដានសក្ខីកម្មពេលល្ងាចឲ្យបានគ្រប់គ្រាន់ទេ សម្រាប់ករណីសវនាការពាក់ព័ន្ធនឹង ឌុច នេះ ដែលជាសាក្សីមួយរូប។ ចុះសម្រាប់ករណីផ្សេងៗទៀត ថាតើគាត់នឹងត្រូវប្រើសិទ្ធិ បើតុលាការអនុញ្ញាតឲ្យគាត់ពេលល្ងាច គាត់ត្រូវតែមានសវនាការតែកន្លះថ្ងៃដូចគ្នា ដែលគាត់ចូល អ៎ តម្រូវឲ្យស្តាប់នោះ គឺសម្រាប់សាក្សីផ្សេងៗទៀត គាត់នឹងទាមទារសិទ្ធិថា គាត់សុំឲ្យមានសវនាការតែកន្លះថ្ងៃ។ អ៊ីចឹងវានឹងធ្វើឲ្យសវនាការនេះនឹងពិបាក។ ដូច្នេះ ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំថា តុលាការបន្តនីតិវិធីដូចដែលតាមព្រាងទុក។

បាទ សូមអរគុណលោកប្រធាន។

[១១:១២:៤៤]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីនួន ជា ដើម្បីលើកឡើងបន្តជំទាស់ទៅនឹង ឬក៏មតិយោបល់ទៅលើអ្វីដែលលើកឡើងដោយសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!ថ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន! ខ្ញុំភ្លេចនិយាយអំពីដើមបណ្តឹងរដ្ឋប្បវេណី និយាយតែអំពីសហព្រះរាជអា្ញា។ ដើម្បីឲ្យច្បាស់ គឺថាយើងខ្ញុំមិនស្នើសុំឲ្យតុលា-- អង្គជំនុំជម្រះសាលាដំបូងប្រកាសថា កូនក្តីខ្ញុំមិនមានសម្បាទានោះទេ។ យើងខ្ញុំគ្រាន់តែស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាថា បើមានលទ្ធភាពណាមួយពិតប្រាកដដែលថា កូនក្តីរបស់យើងខ្ញុំគិតទៅតាមកម្លាំងប្រាជ្ញាស្មារតីនោះ មិនអាចមានលទ្ធភាពបន្តតាមដានដោយសកម្មនូវដំណើរការនីតិវិធីនៅពេលវសៀលបាន នៅក្នុងការស្តាប់សក្ខីកម្មសាក្សីដ៏សំខាន់នេះ នោះគឺថាអ្វីដែលខ្ញុំព្យាយាមចង់បាននោះគឺ គឺខ្ញុំចង់ជូនដំណឹងជាមុនទៅដល់ភាគីដទៃ យើងខ្ញុំមិនចង់ឲ្យមានការពន្យារទៅដល់ពេលវេលាដែលកំណត់កាលវិភាគដែលបានកំណត់ហើយនោះទេ។

[១១:១៤:១១]

ប៉ុន្តែក្នុងពេលនេះ ឬក៏នៅក្នុងពេលក្រោយដ៏ឆាប់ៗ ថាតើយើងនឹងអាចមានលទ្ធភាពណាដែលអាចសម្រេចថា បើសិនណាជាកូនក្តីរបស់យើងខ្ញុំគាត់មិនបោះបង់សិទ្ធិ គាត់មិនជំទាស់នោះទេ ប៉ុន្តែយើងការពារ ថាប្រសិនណាជាគាត់មិនមានវត្តមានហ្នឹង តើវាអាចនឹងវាយ៉ាងណានោះដែរ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីកាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម! ខ្ញុំក៏សូមចូលរួមលើកឡើងនូវបញ្ហានេះដែរ។ តាមការអនុវត្តជាក់ស្តែង ក្នុងពេលធ្វើសេចក្តីថ្លែងបើកប៉ុន្មានថ្ងៃមុននេះ យើងខ្ញុំបានបញ្ជាក់ថា លោក អៀង សារី មិនអាចមានលទ្ធភាពចូលរួមដូចទាំងនេះបានទេ។ គាត់បោះបង់សិទ្ធិហើយអង្គជំនុំជម្រះក៏បានថានៅក្នុងដំណើរការនីតិវិធី-- វគ្គពេលក្រោយ គឺថាគាត់ត្រូវតែមានវត្តមាន។ អ៊ីចឹងអង្គជំនុំ

ជម្រះបានទទួលស្គាល់ថា អាចនឹងមានករណី និងក៏មានភាពខុសគ្នារវាងវត្តមានចូលរួមដោយផ្ទាល់នៅទីនេះ និងវត្តមានចូលរួមតាមរយៈបន្ទប់រង់ចាំបំពាក់ប្រព័ន្ធសោតទស្សន៍នោះ។

ខ្ញុំបានគិតត្រឡប់ទៅដល់ពេលដែលធ្វើសេចក្ដីថ្លែងបើក ហើយចំណុចអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺថាគាត់អាចចូលរួមនៅខាងក្រោម។ លោក ខេលី គាត់បានបញ្ជាក់ថា តើនេះថាតើឈ្មោះ ហ្កាច នេះគាត់ទទួលសេចក្ដីណែនាំពីកូនក្ដីរបស់គាត់ដោយរបៀបណា បើគាត់នៅចាំនៅខាងក្រោមនោះ។ គាត់ត្រូវតែចូលរួមនៅក្នុងបន្ទប់សវនាការតែម្ដង។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីថាត្រូវតែមានវត្តមាននៅទីនេះ។

[១១:១៦:០៩]

ដោយសារតែគាត់មានកាយសម្បទា-- ឥឡូវនេះ ខ្ញុំសូមចូលទៅដល់យុត្តិសាស្ត្រដែលអង្គជំនុំជម្រះបានសម្រេចនៅក្នុងបរិបទផ្សេងគ្នា។ ប៉ុន្តែយ៉ាងណាក៏ដោយ ក៏វាជាប់ពាក់ព័ន្ធទៅនឹងបញ្ហានេះដែរ វាមានភាពខុសគ្នា ដែលថាការចូលរួម ដោយមានចូលរួមតែរូបកាយ ប៉ុន្តែបញ្ញាស្មារតីមិនមាននោះ គឺប្រាកដជាមានលក្ខណៈខុសគ្នាហើយ។ អ៊ីចឹងយើងអាចមានជនជាប់ចោទនៅទីនេះបាន ក៏ប៉ុន្តែបើគិតពីតាមបញ្ញាស្មារតី គាត់មិនអាចតាមដានដំណើរការនីតិវិធីបាន ដោយសារតែមានការឈឺចាប់ មានភាពទន់ខ្សោយ។ ដូច្នេះយើងខ្ញុំបានលើកឡើងកាលមុនមកហើយនៅក្នុងរឿងក្ដីរបស់ *ជីមែន* គឺរឿងក្ដីរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប មៀលគីវេ ជនជាតិអាល្លឺម៉ង់ គឺសេចក្ដីសម្រេច HR30047/96 ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៦។ រឿងក្ដីរវាងសហព្រះរាជអាជ្ញា តទល់ជាមួយ ស្ត្រូហ្កា គឺរឿង IT01-42-T ដែលបានសម្រេចអំពីដំណើរការនីតិវិធីចុះថ្ងៃទី២៦ ខែឧសភា ២០០៤។ គឺរឿងក្ដីមួយទៀត គឺរឿងក្ដីរវាងរដ្ឋអាជ្ញាតទល់ជាមួយនឹងចក្រភពអង់គ្លេស ដែលតុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្ដីលេខ 16757/90 ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៤។ តុលាការទាំងនេះ នេះជាយុត្តិសាស្ត្រមកពីតុលាការទាំងនេះ ដែលបានលើកឡើង ហើយចៅក្រមយើងបានចោទប្រកាន់ទៅលើ គឺថាសុំឲ្យ-- យើងក៏បានប្ដឹងជិតចិត្តទៅលើចៅក្រម ឡឺម៉ុងដ៍ ក្នុងរឿងនេះដែរ។ គឺថាភាគីទាំងអស់ រួមទាំងលោកចៅក្រម ឡឺម៉ុងដ៍ ផងនៅពេលគាត់លើកឡើងអំពីរឿងរបស់មេធាវី អាមីសុន។

នៅក្នុងរឿងក្ដី ស្ត្រូហ្កា នោះ តុលាការបានសម្រេចអំពីលក្ខខណ្ឌដែលត្រូវតែមានវត្តមានដោយផ្ទាល់ គឺដើម្បីធានាថា វត្តមានរបស់ជនជាប់ចោទអាចមានលទ្ធភាពជួយដល់អង្គជំនុំជម្រះនៅចំពោះមុខវត្តមានមេធាវីរបស់ខ្លួន។

[១១:១៩:១១]

យោងទៅតាមគណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុប គឺថាជនជាប់ចោទមិនអាចទទួលការសួរយោបល់ពីមេធាវីរបស់ក្តីបាន។ ប៉ុន្តែនៅក្នុងពេលនេះ គឺថាសហព្រះរាជអាជ្ញាអាចថា ធ្វើឲ្យអង្គជំនុំជម្រះមានការយល់ច្រឡំ ដោយសារថាមានសំណើសុំថាលោក នួន ជា។ សូមដកស្រង់៖ "គឺថាអាចមិនមានសម្បទាចូលរួម" ប៉ុន្តែចំពោះ ឌុច នោះ គិតពីអាយុរបស់គាត់សម្រាប់ពេលព្រឹកហ្នឹងគឺថា គាត់អាចចូលរួមនៅពេលព្រឹក ហើយគាត់ជនជាប់ចោទបែរជាមិនអាចចូលរួមនៅពេលរសៀលបាន។ នៅក្នុងរឿងរបស់ ស្តានីស៊ីក នោះ គាត់ជាប្រធានភ្នាក់ងារស៊ើបការណ៍សម្ងាត់នៅប្រទេស ស៊ើបបៀរ គាត់មានបញ្ហាសុខភាពរាងកាយនេះតែម្តង។ គេបានដាក់បំពាក់ប្រព័ន្ធវីដេអូពីបន្ទប់រង់ចាំខាងក្រោមដាក់ឲ្យគាត់។ នេះគឺជាយុត្តិសាស្ត្រ ដែលបែបនេះ គឺថាក៏វាមិនមានលក្ខណៈគ្រប់គ្រាន់ដែរ។ បើមិនមានការបែងចែកឲ្យខុសពីគ្នាទេ លោក លោកស្រីចៅក្រម រវាងវត្តមានទីនេះ និងវត្តមាននៅបន្ទប់រង់ចាំ។

[១១:២០:៤០]

អ៊ីចឹងហេតុអីក៏បានជាខ្ញុំស្នើសុំបែបនេះ? ហើយជនជាប់ចោទ ម៉េចក៏ចាំបាច់តម្រូវឲ្យមានការចុះហត្ថលេខានូវការលះបង់សិទ្ធិរបស់ខ្លួននេះ? ដូច្នេះជនជាប់ចោទអាចចូលទៅក្នុងបន្ទប់របស់គាត់តែម្តង ប៉ុន្តែនៅក្នុងបន្ទប់របស់គាត់អត់មានអីនោះទេ។ ឧបមាថាមិនមានរឿងខុសគ្នារវាងចំណុចពីរនេះទេ នោះទីមួយ នោះនឹងមិនមានជនជាប់ចោទ ជនជាប់ចោទណាក៏ដោយគឺត្រូវតែចាប់បង្ខំឲ្យមានការវត្តមាននៅទីនេះ ដើម្បីតាមដាន ហើយប៉ុន្តែជនជាប់ចោទមិនអាចមានលទ្ធភាពមកបានទៅតាមការចង់បាននោះ។ ហើយក៏ត្រូវលើកឡើងលះបង់សិទ្ធិរបស់ខ្លួន។ ការលះបង់សិទ្ធិនេះ គឺៗគាត់មានចេតនាចង់ឲ្យដំណើរការនីតិវិធីដំណើរការតទៅមុខតទៅទៀត ទោះណាជាគាត់មិនមានវត្តមាននៅទីនេះក្តី គាត់តាមដានបាន មិនបានក្តី គឺគាត់មានចេតនាចង់ឲ្យបន្តដំណើរការនីតិវិធីជាហូរហែ។

នេះជាសេចក្តីស្មោះត្រង់នៃការលះបង់សិទ្ធិរបស់ជនជាប់ចោទ។ ប៉ុន្តែបើគាត់មិនមានលទ្ធភាពដែលអាចស្នើសុំថា អ្នកឯងអាចបោះបង់សិទ្ធិនេះ ដោយមិនចូលរួមនៅក្នុងបន្ទប់សវនាការ នោះមិនមែនមានន័យថា គាត់ត្រូវតែនៅក្នុងបន្ទប់រង់ចាំខាងក្រោមទេ។ ប៉ុន្តែតាមការពិត ជនជាប់ចោទតែងតែចង់នៅទីនេះ ចង់ស្តាប់ចម្លើយសាក្សី ចង់មើលសាក្សី ចង់មើលឃើញថាសាក្សី មើលគាត់ទៅវិញដែរឬក៏អត់? នេះអាចនឹងមានការកើតឡើងនៅក្នុងឧទាហរណ៍មួយចំនួន ដែលជនជាប់ចោទមិនមានវត្តមាន។

[១១:២២:៣២]

ការសួរជនសាក្សី ហើយដោយឲ្យគាត់អស់កម្លាំង ហើយចាប់បង្ខំគាត់ឲ្យនៅទីនេះ។ អ្នកឯងអាចតាមដាននៅទីនេះត្រូវតែតាមដាន ឬក៏អ្នកឯងចាំបន្ទប់រង់ចាំខាងក្រោម ហើយប៉ុន្តែដោយសារតែអស់កម្លាំង គឺថាគាត់អាចអស់កម្លាំង អាចសម្រាន្តលក់ទៅ។

ដូច្នេះស្នើ ខ្ញុំស្នើសុំថា គឺដើម្បីសម្រាប់ស្ថាប័ននេះ ក៏-- ហើយក៏ដើម្បីសម្រាប់ជាកេរដំណែលរបស់តុលាការនេះផងដែរ។ អ្វីដែលនេះៗគឺថា មានជម្រើសណាស់ដែលអង្គជំនុំជម្រះអាចធ្វើទៅបានដែលអាចធានាទៅដល់យើង ការពារទៅដល់ផលប្រយោជន៍របស់មនុស្សម្នាក់ៗ ទាំងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញាក៏ដូចជាសិទ្ធិរបស់ជនជាប់ចោទ។

[១១:២៣:៣២]

ឌុច អាចសួរពេលព្រឹកក៏បាន ពេលថ្ងៃក៏បាន។ នួន ជា អត់បាននិយាយថា ខ្ញុំអាចស្តាប់គាត់នៅពេលរសៀលក៏បានដែរ។ គាត់អត់បាននិយាយអីចឹងទេ សិទ្ធិរបស់គាត់ៗអាចនិយាយដូច្នេះបាន។ ដូច្នេះរហូតទៅដល់ពេលចំណុច មកដល់ពេលនេះ នួន ជា អត់ទាន់បាននិយាយថា ខ្ញុំមិនមានលទ្ធភាពទេ ខ្ញុំសូមអធ្យាស្រ័យ សូមទោសដើម្បីផ្តល់ឱកាសមកឲ្យខ្ញុំ ដើម្បីឲ្យវត្តមានរបស់ខ្ញុំនេះនៅទីនេះ។ ខ្ញុំអាចតាមដាននីតិវិធី ខ្ញុំអាចទទួលសេចក្តីណែនាំពីអង្គជំនុំជម្រះ ហើយនៅពេលខ្លះ ខ្ញុំក៏ផ្តល់សារប្រយោជន៍ទៅដល់អង្គជំនុំជម្រះផងដែរ។ ចុះបើ នួន ជា គាត់សម្រាន្តនៅពេលរសៀលលក់ទៅ ហើយ ឌុច សួរចម្លើយ ឌុច នៅពេលរសៀល លុះណាតែផ្តល់ទៅគាត់ឲ្យគាត់អាននូវប្រតិចារឹក។ អីចឹងថាតើមានប្រយោជន៍អី ដែលគាត់ដែលត្រូវណែនាំទៅដល់កូនក្តីរបស់គាត់បែបនេះនោះ?

[១១:២៤:៤៣]

ដូចអ្វីដែលបានទទួលស្គាល់ដោយសហព្រះរាជអាជ្ញាថា រាល់បំណែកនៃព័ត៌មានទាំងអស់ គឺមានសារៈសំខាន់។

**ប្រធានអង្គជំនុំ៖**

ពីរដងហើយ ម្សិលមិញលោកនិយាយម្តងហើយ ឥឡូវនេះអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកនិយាយម្តងទៀត ប៉ុន្តែអង្គជំនុំជម្រះបានជម្រាបហើយគួរសន្សំសំចៃពេលវេលា ដោយសារយើងមានពីរប្រធានបទពីរទៀត ដែលត្រូវជជែកគ្នាក្នុងមួយភាគីមានរហូតដល់មួយម៉ោងកន្លះ។ ប្រសិនបើដល់ពេលរសៀលបីម៉ោងអាចត្រូវបានពន្យារពេលរហូតដល់ម៉ោងប្រាំ ឬក៏ម៉ោងបួនកន្លះ ឬក៏ម៉ោងប្រាំ។ អង្គជំនុំជម្រះនឹងសម្រេចចិត្តថា នៅរសៀលនេះដាច់ខាតត្រូវតែបញ្ចប់នូវប្រធានបទទាំងនេះ ទោះបីដល់ម៉ោង

ប្រាំ ឬក៏ម៉ោងប្រាំមួយក៏ដោយ។

**លោក ម៉ៃខល ការណាវ៉ាស៖**

សូមតែមួយនាទីទេ ខ្ញុំសូមអភ័យទោស។ សហព្រះរាជអាជ្ញាគាត់ទទួលស្គាល់ថា ឌុច គឺជាសាក្សីសំខាន់។ ខ្ញុំក៏មានការវង្វេងដែរ នៅពេលព្រលឹមដែលសហមេធាវីការពារក្ដីផ្សេងបានលើកឡើង គឺ ឌុច គឺជាសាក្សីសំខាន់ សហព្រះរាជអាជ្ញាបានបញ្ជាក់រួចមកហើយ។ ដូច្នេះហើយក៏ជាចម្លើយដូច្នេះដែរ ពីខាងដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើគាត់ជាសាក្សីសំខាន់ ហើយជនជាប់ចោទទាមទារវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ គឺជាសិទ្ធិរបស់ជនជាប់ចោទ។

[១១:២៦:០៩]

វាមិនមែនជាបញ្ហាដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ជនរងគ្រោះនោះទេ។ វាក៏មិនមែនពាក់ព័ន្ធទៅនឹងសហព្រះរាជអាជ្ញាផងដែរ គឺវាពាក់ព័ន្ធទៅនឹងបុគ្គលដែលទទួលសិទ្ធិជំនុំជម្រះដោយយុត្តិធម៌។ អង្គជំនុំជម្រះត្រូវតែពិចារណារឿងក្ដីនេះ ដូច្នេះហើយត្រូវពិចារណាអំពីសិទ្ធិរបស់ភាគី។ ដូច្នេះយើងខ្ញុំសូមបញ្ជាក់ថា សូមលើកឡើងថា មេធាវីការពារក្ដី នួន ជា ដែលបានលើកឡើងគឺជាវិធានការមួយសមស្របនិងត្រឹមត្រូវ វាមិនពន្យារនីតិវិធីនោះឡើយ។ ដូច្នេះហើយវាមិនមានការពន្យារនីតិវិធីរបស់យើងនៅថ្ងៃចន្ទនោះទេ។ ដូច្នេះយើងខ្ញុំស្នើថាគួរតែមានតែវិធីបត់បែន ហើយភាគីគួរតែជម្រាបអង្គជំនុំជម្រះជាមុន ៗឲ្យបានយូរបន្តិច ដើម្បីឲ្យអង្គជុំនុំជម្រះអាចសម្របសម្រួលថាតើសាក្សីណាមួយមានវត្តមានយកមកបញ្ចូលក្នុងចន្លោះពេលដែលយើងនៅសល់ក្នុងនីតិវិធីរបស់យើង។

[១១:២៧:១៤]

ខ្ញុំសូមអភ័យទោសចំពោះលោក លោកស្រីចៅក្រម ហើយសូមថ្លែងអំណរគុណដែលផ្ដល់ឱកាសឲ្យយើងខ្ញុំផ្ដល់វត្ត-- មានវត្តមានលើកឡើងនូវមតិយោបល់របស់យើងខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយសូមសហព្រះរាជអាជ្ញាខ្លីបានហើយ ពីព្រោះអង្គជំនុំជម្រះបានស្ដាប់ព័ត៌មានហ្នឹងដូចជាសព្វគ្រប់សមល្មមនឹងអាចយកទៅពិចារណាថ្លឹងថ្លែង ក្នុងការរៀបចំនៅលើកាលវិភាគសម្រាប់ដំណើរការសវនាការចាប់ពីថ្ងៃចន្ទក្រោយបានហើយ។

**លោក ឆេង លីសាក់៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងនិយាយដោយខ្លីបំផុត។ ខ្ញុំមិនដឹងថាតើមេធាវីការពារក្ដីគាត់មិន

យល់អ្វីដែលខ្ញុំលើកឡើង ឬក៏គាត់ព្យាយាមមិនអើពើ ប៉ុន្តែយើងនឹងឲ្យត្រូវតែច្បាស់ទាំងអស់គ្នា។ សេចក្តីសម្រេចត្រូវតែសម្រេចផ្អែកទៅលើភស្តុតាងចេញមកពីវេជ្ជបណ្ឌិត។ មេធាវីការពារក្តីចង់តវ៉ាអំពីការលើកឡើងរបស់ខាងសហព្រះរាជអាជ្ញា ឬក៏ភាគីមេធាវី គឺយើងត្រូវតែដឹងថាសេចក្តីសម្រេចត្រូវតែផ្អែកទៅលើភស្តុតាង ការលើកឡើងរបស់ខាងមេធាវីការពារក្តី នួន ជា ថាគាត់សម្រាន្តលក់មិនអាចតាមដាននីតិវិធីនោះ គឺយើងៗត្រូវពិចារណាទៅលើកោសល្យវិច័យវេជ្ជបណ្ឌិតវិញ។ ប្រសិនបើយើងមើលឯកសាររបស់-- ឯកសារមួយទៀត គឺ E62/3/13 ដោយសាស្ត្រាចារ្យ ខាំប៉ែល ដែលក្នុងនោះ គឺលោកសាស្ត្រាចារ្យបានបញ្ជាក់ថា នួន ជា បានមានពិន្ទុ៣០/៣០ លើការតេស្តស្ទង់សតិបញ្ញា។

ដូច្នេះហើយគឺវាមានកម្រិតសម្រាប់បុគ្គលអាយុ៨៥ឆ្នាំ។ ដូច្នេះស្ថានភាពស្មារតីរបស់លោក នួន ជា គឺវាមានកម្រិតខ្ពស់ណាស់លើកលែងតែវាមានហេតុផលវេជ្ជសាស្ត្រណាមួយផ្សេង ដែលយើងអាចយកមកធ្វើជាមូលដ្ឋានសម្រេចថា គាត់មិនអាចចូលរួមសវនាការពេលវេលានៅពេលថ្ងៃនោះ វាជាបញ្ហាមួយផ្សេង ក៏ប៉ុន្តែប្រសិនយើងសម្រេចលើចំណុចហ្នឹងដូច្នេះវាលឿនពេក។

[១១:២៩:២៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៦:៤៩]

**ប្រធានអង្គជំនុំ៖**

សូមប្រគល់ភារៈទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដើម្បីតាំងសំណួរមួយចំនួនជូនទៅខាងក្រុមមេធាវីការពារក្តី នួន ជា ដើម្បីបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់ អំពីកិច្ចដំណើរការប្រព្រឹត្តទៅនៅក្នុងការតាំងសួរដេញដោលនៅក្នុងសប្តាហ៍ក្រោយចំពោះជនជាប់ចោទ ក៏ដូចជាចំពោះ ស្តាប់សក្ខីកម្មសាក្សី នួន ជា អ៎! សាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងទើបតែបានពិភាក្សាអម្បាញ់មិញ មួយសន្ទុះខ្លីដែរ ទៅលើជម្រើសសំណើ ពាក់ព័ន្ធនឹងជម្រើសផ្សេង ដែលយើងខ្ញុំសូមឲ្យខាងភាគីទាំងឡាយផ្តល់ជាយោបល់ជាបន្ទាន់នាពេលនេះ។ គឺយើងដឹងហើយថាជាទូទៅជនជាប់ចោទត្រូវបានសួរចម្លើយជាមុន។ ដូច្នេះ យើងខ្ញុំសូមសួរយោបល់ទៅខាងក្រុម នួន ជា ដែលបានលើកឡើងថា សូមឲ្យស្តាប់សក្ខីកម្ម

ឌុច នៅពេលព្រឹកនិងពេលរសៀលឲ្យបានចប់សិន មុនពេលដែលយើងសួរចម្លើយជនជាប់ចោទ នួន ជា។ បញ្ហាទីពីរដែលយើងចង់សុំឲ្យផ្តល់ជាការលើកឡើងភ្លាមៗមកដែរ ថាតើវាអាចជួយយើងទាំងអស់គ្នាបានដែរឬទេ ថានៅក្នុងពេលការសួរចម្លើយ នួន ជា ហើយគឺគាត់មិនស្នើសុំសម្រាកខ្លីៗច្រើនដង។ គឺថាតើយើងអាចឲ្យគាត់នេះស្នើមានការសម្រាកខ្លីៗឲ្យបានច្រើនដើម្បីឲ្យគាត់សម្រាកបានច្រើន។ ដូច្នេះមិនមែន ថាយើងស្នើសុំឲ្យមិនមានការសម្រាកអាហារថ្ងៃត្រង់នោះទេ ក៏ប៉ុន្តែយើងខ្ញុំចង់សួរអំពីការឈប់សម្រាកពីខាងជនជាប់ចោទ។ មានបញ្ហាពីរដែលវាពាក់ព័ន្ធនៅក្នុងចំណុចនេះ ដែលលោកប្រធានស្នើសុំឲ្យភាគីផ្តល់ជាយោបល់ឲ្យភ្លាមៗនៅពេលនេះ។

ជាដំបូងសូមខាង នួន ជា!

[១១:៣៩:៣០]

**លោក ម៉ៃខល ផេសមិន៖**

បញ្ហាដែលសួរឡើងនោះ គឺថាវាអាចជួយការងាររបស់យើងដែរឬទេ ប្រសិនបើយើងស្តាប់សក្ខីកម្មរបស់ ឌុច ពេលព្រឹក បន្ទាប់មកនៅពេលរសៀល។ ដូច្នេះហើយវាអាចឲ្យកូនក្តីរបស់ខ្ញុំមានការសម្រាកច្រើន។ ហើយខ្ញុំគិតថាបញ្ហានេះវាអាចចំណាយពេលយើងពេញមួយថ្ងៃ វាជាចំណុចមួយដែលអាចជួយការងាររបស់យើងបាន។ បញ្ហាទីពីរ ដែលយើងខ្ញុំសូមពិភាក្សាជាមួយនឹងកូនក្តីរបស់ខ្ញុំផងដែរ ខ្ញុំអាចជម្រាបអង្គជំនុំជម្រះនៅពេលរសៀលក្រោយពេលអាហារថ្ងៃត្រង់។ ខ្ញុំនឹងធ្វើការស្វែងរកដំណោះស្រាយទៅលើបញ្ហានេះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៏៖**

យើងមិនចង់ឲ្យមានការលើកឡើងសេចក្តីសន្និដ្ឋានវែងនោះទេ ទៅលើបញ្ហានេះ ហើយយើងគ្រាន់តែចង់សួរថាតើយល់ព្រម ឬក៏មិនយល់ព្រមនៅពេលរសៀល? យើងមិនចង់ឲ្យមានការឆ្លើយវែងទេ ទៅលើចំណុចហ្នឹង។

អង្គជំនុំជម្រះបានបញ្ជាក់ហើយថា យើងខ្ញុំនឹងត្រៀមខ្លួនពិចារណាទៅលើពាក្យសុំណាមួយដែលបានលើកឡើងដោយផ្អែកទៅលើមូលដ្ឋានដែលបានបញ្ជាក់នៅក្នុងសំណើសុំទាំងអស់នោះ។

ចុះចំណែកក្រុមមេធាវីការពារក្តី អៀង សារី វិញយ៉ាងម៉េចដែរ? ចង់ផ្តល់យោបល់ដែរឬទេ?

[១១:៤០:៥២]

**លោក ម៉ៃខល កាណាវ៉ាស៖**

លោក លោកស្រីចៅក្រមបានបញ្ជាក់អំពីភាពពាក់ព័ន្ធរួចមកហើយ ដូច្នេះហើយវាគ្រប់គ្រាន់ហើយដែលខ្ញុំសូមឯកភាពដែល ទៅនឹងអ្វីដែលក្រុមមេធាវីការពារក្តី នួន ជា បានបញ្ជាក់អម្បាញ់មិញ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ចុះខាងសហព្រះរាជអាជ្ញាវិញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកស្រីចៅក្រម! ជំហររបស់យើងខ្ញុំ គឺ ឌុច ផ្តល់សក្ខីកម្មនៅពេលព្រឹក នៅពេលរសៀលនោះ គឺវាអាចសមស្របសម្រាប់ក្រុមមេធាវីការពារក្តី នួន ជា ដែលគាត់ស្នើសុំថាឲ្យស្តាប់សក្ខីកម្ម ឌុច នៅពេលព្រឹក និងសាក្សីផ្សេងនៅពេលរសៀល។

ដូច្នេះហើយ យើងក៏មិនអាចជំទាស់ដែលទៅនឹងការស្នើសុំឲ្យ ឌុច ផ្តល់សក្ខីកម្មនៅពេលព្រឹក និងពេលរសៀល។

[១១:៤១:៤៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤២:២១]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះ យើងមានព័ត៌មានសមល្មមហើយលើបញ្ហានៃការរៀបចំកាលវិភាគសម្រាប់ពិភាក្សាដេញដោលសម្រាប់សប្តាហ៍ក្រោយ ដោយមានការបត់បែនដើម្បីធ្វើយ៉ាងណាឲ្យកិច្ចដំណើរការប្រព្រឹត្តទៅបាន។

ហើយជាកិច្ចបន្ត គឺរបៀបវារៈមួយទៀតដែលមានពីរដោយបញ្ហានេះគឺជាប់គ្នា។ ទីមួយ គឺសំណើសុំរបស់សហព្រះរាជអាជ្ញាសុំឲ្យស្តាប់សក្ខីកម្មអ្នកជំនាញ ឈ្មោះ ប៉ែន យៀរនិន តាមរយៈប្រព័ន្ធសោតទស្សន៍នៅក្នុងអំឡុងពេលសវនាការខាងមុខ និងមួយទៀត គឺការជំទាស់របស់ក្រុមមេធាវីការពារក្តីក្នុងការស្តាប់សក្ខីកម្ម។ សំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ស្នើសុំយកឯកសារបន្ថែមពីអ្នកជំនាញជាមុន មុនពេលអ្នកជំនាញផ្តល់សក្ខីកម្ម។ នេះជាបញ្ហាដែលត្រូវជជែកពិភាក្សា ហើយរួមគ្នាតែម្តង យើងមិនបាច់បំបែកចេញពីគ្នាទេ ដោយធ្វើដាច់ពីគ្នារវាងសំណើសុំរបស់សហព្រះរាជអាជ្ញា ហើយនិងមួយទៀតគឺសំណើសុំរបស់លោក អៀង សារី ដោយនៅក្នុងដំណាក់កាល

ដំបូងនេះ គឺអង្គជំនុំជម្រះប្រគល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីលើកឡើងអំពីបញ្ហានេះ ហើយលើកឡើងអំពីការជំទាស់ ទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តីស្នើសុំយកឯកសារបន្ថែម ពីអ្នកជំនាញជាមុន មុនអ្នកជំនាញផ្តល់សក្ខីកម្ម។

[១១:៤៣:៥៧]

ហើយទន្ទឹមនឹងនេះក៏មាននូវពេលវេលាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ដែលភាគីទាំងពីរ មានរយៈពេល៩០នាទី ហើយពេលវេលាអាស្រ័យលើភាគីទាំងពីរបែងចែក។

មុននឹងប្រគល់វេទិកា អង្គជំនុំជម្រះសួរទៅតំណាងសហព្រះរាជអាជ្ញា ថាតើបានបែងចែកពេល វេលាគ្នាហើយ ឬនៅវាងតំណាងសហព្រះរាជអាជ្ញាជាមួយនឹងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្ប វេណីអំពីប្រធានបទទាំងពីរនេះ។

[១១:៤៤:៣៤]

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន សូមគោរពអង្គជំនុំជម្រះ សូមគោរពអង្គសវនាការទាំងមូល។នៅពេលនេះ ខ្ញុំសូមអនុញ្ញាតលើកឡើងទាក់ទិននឹងការយល់ឃើញ របស់សហព្រះរាជអាជ្ញា ចំពោះការប្រើប្រាស់បច្ចេកវិទ្យាសោតទស្សន៍ក្នុងការស្តាប់សក្ខីកម្មរបស់អ្នក ជំនាញដែលមានរហស្សនាម TCW-38។

[១១:៤៥:០២]

**ប្រធានអង្គជំនុំ៖**

ការបែងចែកពេលវេលាយ៉ាងម៉េចទៅ ឥឡូវឲ្យ៩០នាទី ណ៎ា ឬបើតិចជាងហ្នឹងល្អហើយណ៎ា។ ពីព្រោះឥឡូវពេលវេលាគឺពេលនេះរហូតដល់រសៀលនេះ យើងមានបំណងបញ្ចប់នូវបញ្ហាការជជែក ពិភាក្សានៅក្នុងបញ្ហាទាំងឡាយដែលបានកំណត់សម្រាប់ធ្វើសវនាការនេះ។

**លោក ច័ន្ទ តារាស្មី៖**

ខាងសហព្រះរាជអាជ្ញា លោកប្រធាន មានពេល៦០នាទី ហើយជូនខាងមេធាវីនាំមុខចំនួន ៣០នាទី បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ហើយអង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យលោកបន្តត្រឹមម៉ោង១២:១៥នាទី។

[១១:៤៥:៤៣]

**លោក ច័ន្ទ តាវារស្មី៖**

បាទ ខ្ញុំសូមអនុញ្ញាតលើកឡើងទាក់ទិនទៅនឹងការយល់ឃើញរបស់សហព្រះរាជអាជ្ញា ចំពោះការប្រើប្រាស់បច្ចេកវិទ្យាសោតទស្សន៍ក្នុងការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញ ដែលមានរហស្សនាម TCE-38។ ដូចលោក លោកស្រីចៅក្រមជ្រាបស្រាប់ហើយ នៅក្នុងអនុស្សរណៈចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១២ យោងឯកសារលេខ E172/5 ត្រង់កថាខណ្ឌប្រាំមួយ។ លោកប្រធានអង្គជំនុំជម្រះបានបង្គាប់ថា ភាគីអាចដាក់អំណះអំណាងដោយផ្ទាល់មាត់បាន ពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យាសោតទស្សន៍ក្នុងការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញ ដែលកោះហៅដោយអង្គជំនុំជម្រះសាលាដំបូងដែលមានរហស្សនាម TCE-38។ និងដើម្បីឆ្លើយតបទៅនឹងការជំទាស់ដែលមានលើកឡើងដោយមេធាវីការពារក្ដី។ រួមជាមួយសហសេវិករបស់ខ្ញុំ គឺលោក វ៉ាំងសង់ ភាគីសហព្រះរាជអាជ្ញាមានយោបល់ប្រហែលជា៦០នាទីយ៉ាងច្រើន ហើយទុកពេលសល់ពេលនេះ ទុកពេលជូនសហមេធាវីនាំមុខចំនួន៣០នាទី ដើម្បីលើកឡើងអំពីការយល់ឃើញរបស់ខ្លួន។

[១១:៤៦:៤៩]

លោក លោកស្រីចៅក្រម ចាប់តាំងពីពេលចាប់ផ្ដើមមក វាជាការសំខាន់ណាស់ក្នុងការបញ្ជាក់ជាថ្មីឡើងវិញនូវមូលដ្ឋានច្បាប់ ដែលសហព្រះរាជអាជ្ញាយកមកសំអាងដើម្បីទាក់ទងជាមួយអ្នកជំនាញដែលរហស្សនាម TCE-38 និងបានដាក់ជូនរបាយការណ៍របស់ខ្លួនដល់អង្គជំនុំជម្រះ និងភាគីនានាស្ដីពីវត្តមាន និងអនុសាសន៍នានាសម្រាប់ការកំណត់ពេលវេលា និងវិធីសាស្ត្រនៃការបង្ហាញខ្លួនរបស់គាត់។ យោងឯកសារលេខ E166/1។ នៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក វាជាគោលការណ៍មូលដ្ឋានដែលថា សាក្សីទាំងអស់ជាសក្សីរបស់អង្គជំនុំជម្រះ ពុំមែនជាសាក្សីដែលកោះហៅដោយភាគី ឬរបស់ភាគីណាមួយនៃកិច្ចដំណើរការនីតិវិធីទេ។ តាមរយៈអនុសាសន៍ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១២ យោងឯកសារលេខ E166 អង្គជំនុំជម្រះបានបញ្ជាក់ពីចេតនារបស់ខ្លួនក្នុងការកោះហៅអ្នកជំនាញ ដែលមានរហស្សនាម TCE-38 នៅដំណាក់កាលសវនាការ និងបានបង្គាប់ឲ្យសហព្រះរាជអាជ្ញាទាក់ទងជាមួយអ្នកជំនាញដែលមានរហស្សនាម TCE-38 ក្នុងគោលបំណងតិចតួច គឺសម្រេចពីវត្តមាន និងជួយដល់អង្គជំនុំជម្រះក្នុងការរៀបចំផែនការ និងកំណត់កាលបរិច្ឆេទផ្ដល់សក្ខីកម្មតែប៉ុណ្ណោះ។

[១១:៤៨:១៤]

ក្នុងការបំពេញការងារដែលប្រគល់សិទ្ធិដោយអង្គជំនុំជម្រះនោះ សហព្រះរាជអាជ្ញាបានទាក់ទងជាមួយអ្នកជំនាញដែលមានរហស្សនាម TCE-38 និងមានបញ្ចូលរាល់លិខិតទាក់ទងទាំងអស់ជាមួយអ្នកជំនាញរូបនេះ នៅក្នុងសំណុំឯកសារជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញទៅតាមការបង្គាប់របស់អង្គជំនុំជម្រះរួចហើយ។

ដោយសារអ្នកជំនាញដែលមានរហស្សនាម TCE-38 ជាសាក្សីរបស់អង្គជំនុំជម្រះ បញ្ហាដែលនៅចំពោះមុខលោក លោកស្រីចៅក្រមនាថ្ងៃនោះ-- នាថ្ងៃនេះ គឺថា តើអង្គជំនុំជម្រះគួរតែអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដូចមានចែងក្នុងវិធាន២៦ ចំណុច១ នៃវិធានផ្ទៃក្នុង ដើម្បីអនុញ្ញាតឲ្យសាក្សីដែលមានរហស្សនាម TCE-38 ផ្តល់សក្ខីកម្មតាមរយៈសោតទស្សន៍ជំនួសឲ្យបានបង្ហាញខ្លួនដោយផ្ទាល់បានដែរឬយ៉ាងណានោះ?

[១១:៤៩:០៩]

អនុលោកតាមបទប្បញ្ញត្តិនេះ អង្គជំនុំជម្រះសាលាដំបូងអាចអនុញ្ញាតឲ្យប្រើប្រាស់បច្ចេកវិទ្យាសោតទស្សន៍ ក្នុងករណីដែលសាក្សីមិនអាចផ្តល់សក្ខីកម្មដោយផ្ទាល់បាន។ ក្នុងការអនុវត្តឆន្ទានុសិទ្ធិនេះ អង្គជំនុំជម្រះត្រូវធានាថា សោតទស្សន៍អាចអនុញ្ញាតឲ្យសាក្សីផ្តល់សក្ខីកម្មស្របពេលជាមួយគ្នានោះដោយអង្គជំនុំជម្រះក្តី និងដោយភាគីនានាក្តី ហើយការប្រើប្រាស់សោតទស្សន៍នឹងមិនត្រូវធ្វើឲ្យអន្តរាយធ្ងន់ធ្ងរ ឬមិនស្របទៅនឹងសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទឡើយ។

ដូចភាគីទាំងអស់ដែលថា គឺសហព្រះរាជអាជ្ញាចង់ស្តាប់សក្ខីកម្មពីអ្នកជំនាញ ដែលមានរហស្សនាម TCE-38 ដោយផ្ទាល់ជាងការមិនផ្ទាល់។ ទោះជាយ៉ាងណាក្តី ព័ត៌មានដែលទទួលបានពីអ្នកជំនាញដែលមានរហស្សនាម TCE-38 និងដែលបានបញ្ចូលក្នុងសេចក្តីជូនដំណឹង ជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាចំពោះភាគី យោងតាមឯកសារ E166/1 បង្ហាញថា គាត់មានការមមាញឹកក្នុងអាជីពពុំអាចមានវត្តមានដោយផ្ទាល់នាឆ្នាំនេះបានទេ។ ហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យអ្នកជំនាញដែលមានរហស្សនាម TEC-38 បញ្ជាក់ឲ្យបានច្បាស់ពីវិសាលភាពនៃភាពមមាញឹកក្នុងអាជីពការងាររបស់ខ្លួនគាត់។

បន្ទាប់ពីពន្យារពេលមួយរយៈ អ្នកជំនាញដែលមានរហស្សនាមTEC-38 បានផ្តល់ព័ត៌មានពិស្តារពីការស្រាវជ្រាវ ពីការបង្រៀន និងកិច្ចការងាររដ្ឋបាលដទៃទៀត។ ហើយសហព្រះរាជអាជ្ញាបានដាក់ជូនឯកសារពាក់ព័ន្ធទាំងនេះទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញតាមការបង្គាប់រួចរាល់អស់ហើយ។

[១១:៥០:៥៧]

ទំនងជាថាមានតែតាមរយៈសោតទស្សន៍ទេ អាចជាមធ្យោបាយងាយស្រួលតែមួយគត់សម្រាប់ស្តាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-38 ក្នុងសវនាការដំណាក់កាលនេះ។ ហេតុនេះហើយបានជានៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់ខ្លួន ផ្ញើជូនអង្គជំនុំជម្រះ និងភាគីនានាសហព្រះរាជអាជ្ញាជូនយោបល់ថា គួរប្រើមធ្យោបាយសោតទស្សន៍វិញជាការប្រសើរជាង។

នៅក្នុងការពិចារណាថា តើគួរអនុញ្ញាតឲ្យអ្នកជំនាញដែលមានរហស្សនាម TEC-38 មានវត្តមានតាមរយៈសោតទស្សន៍ឬយ៉ាងណានោះ? អង្គជំនុំជម្រះត្រូវវាយតម្លៃថា តើវាស្របទៅនឹងធាតុផ្សំនានានៃវិធានផ្ទៃក្នុងពោលគឺវិធាន២៦(១) ឬទេ? ក្នុងន័យនេះនាថ្ងៃនេះ សហព្រះរាជអាជ្ញាសូមលើកឡើងនូវអំណះអំណាងចំនួនបីជូនលោក លោកស្រីចៅក្រមដើម្បីជ្រាបដូចតទៅៈ

ទីមួយ យោងវិធាន២៦(១) មិនបានដាក់បន្ទុកដល់សហព្រះរាជអាជ្ញាក្នុងការបង្ហាញថា សាក្សីណាម្នាក់មិនអាចផ្តល់សក្ខីកម្មដោយផ្ទាល់បានទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះដែលជាស្ថាប័នតុលាការត្រូវកោះហៅសាក្សីនោះ ត្រូវធានាថា តើវាស្របទៅនឹងធាតុផ្សំនានានៃវិធានផ្ទៃក្នុង វិធានលេខ២៦(១) ឬទេ?

ទីពីរ ការប្រើប្រាស់បច្ចេកវិទ្យាសោតទស្សន៍ នឹងអនុញ្ញាតឲ្យសាកសួរសំណួរបន្តផ្ទាល់ ឬស្របពេលជាមួយគ្នាដល់សាក្សីដែលបានស្នើសុំដោយភាគី និងដោយអង្គជំនុំជម្រះផ្ទាល់តែម្តង។

[១១:៥២:២៦]

ចំណុចទីបី ការប្រើប្រាស់បច្ចេកវិទ្យាសោតទស្សន៍ពុំរំលោភសិទ្ធិជនជាប់ចោទទាល់តែសោះ។ លោក លោកស្រីចៅក្រម មុនពេលឆ្លើយតបទៅនឹងអំណះអំណាងទាំងអស់នេះ ខ្ញុំសូមធ្វើការសង្កេតបឋមខ្លះៗទៅលើច្បាប់ជាធរមាន ពោលគឺវិធាន២៦(១) នៃវិធានផ្ទៃក្នុង និងវិធាននីតិវិធី និងទម្លាប់អនុវត្តនៅក្នុងយុត្តាធិការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ដោយអនុលោមតាមមាត្រា៣៣ នៃច្បាប់នៃការបង្កើត អ.វ.ត.ក។

ការសង្កេតបឋមទៅលើច្បាប់ជាធរមាន ទាក់ទិននឹងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក។ ដូចលោក លោកស្រីចៅក្រមជ្រាបស្រាប់ហើយ ខ្ញុំបាទសូមជម្រាបនៅក្នុងសេចក្តីផ្នែកផ្តើមរួចមកហើយថា គឺការប្រើប្រាស់បច្ចេកវិទ្យាសោតទស្សន៍សម្រាប់គោលបំណងនៃការផ្តល់សក្ខីកម្មនៅ អ.វ.ត.ក ត្រូវបានកំណត់នៅក្នុងវិធាន២៦(១) នៃវិធានផ្ទៃក្នុង។ វិធាន២៦(១) បានផ្តល់ឆន្ទានុសិទ្ធិដល់អង្គជំនុំជម្រះសាលា

ដំបូង ដើម្បីអនុញ្ញាតឲ្យប្រើប្រាស់បច្ចេកវិទ្យាវីដេអូ ដែលត្រូវឲ្យស្របទៅតាមធាតុផ្សំចំនួនបីសំខាន់ដូចខាងក្រោម៖

[១១:៥៣:៣២]

ទីមួយ សាក្សីនោះមិនអាចផ្ដល់សក្ខីកម្មដោយផ្ទាល់បាន។ ទីពីរ សោតទស្សន៍អាចឲ្យអង្គជំនុំជម្រះ និងភាគីសាកសួរសាក្សីបាននៅពេលដែលសាក្សីត្រូវផ្ដល់សក្ខីកម្ម និយាយម៉្យាងទៀត គឺមានន័យថាការសាកសួរបន្តផ្ទាល់ ឬស្របពេលជាមួយគ្នា។ និងទីបី គឺការប្រើប្រាស់បច្ចេកវិទ្យាវីដេអូមិនមានអន្តរាយធ្ងន់ធ្ងរ ឬមិនផ្ទុយពីសិទ្ធិការពារខ្លួននៅក្នុងករណីនេះ គឺសិទ្ធិរបស់ជនជាប់ចោទនោះទេ។

គោលជំហរនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត៖ ស្រដៀងគ្នានឹង អ.វ.ត.ក ដែរ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតមានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាតឲ្យសាក្សីផ្ដល់សក្ខីកម្មតាមរយៈសោតទស្សន៍បាន។ សំណើសុំបែបនេះពុំមានជារឿងចម្លែកនោះទេ ហើយដោយឡែក ចំណែកឯតុលាការ អាយ.ស៊ី.ធី.វ៉ាយ គឺមានច្បាប់យុត្តិសាស្ត្រជាច្រើនដែរពាក់ព័ន្ធនឹងបញ្ហានេះ។

[១១:៥៤:២៨]

នៅក្នុងអំណះអំណាងរបស់យើងខ្ញុំគោលជំហរដែលតុលាការទាំងនេះប្រកាន់យកនៅពេលដែលឆ្លើយតបទៅនឹងសំណើសុំប្រើប្រាស់សោតទស្សន៍ អាចជាជំនួយខ្លះដល់អង្គជំនុំជម្រះក្នុងការសម្រេចបញ្ហាដែលមាននៅចំពោះមុខលោក លោកស្រីចៅក្រមនាថ្ងៃនេះ។

អាស្រ័យហេតុនេះ មុនពេលនិយាយពីធាតុផ្សំសំខាន់ៗ នៅក្នុងអំណះអំណាងរបស់យើងខ្ញុំ ប្រសិនបើលោក លោកស្រីចៅក្រមអនុញ្ញាតនាពេលនេះ ខ្ញុំសូមធ្វើការពន្យល់ដោយសង្ខេបនូវវិធីសាស្ត្រដែលបានប្រើប្រាស់រួចមកហើយនៅឯតុលាការ អាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ធី.អ័រ និង អាយ.ស៊ី.ស៊ី។

ចំពោះតុលាការមិនអចិន្ត្រៃយ៍ តុលាការ អាយ.ស៊ី.ធី.អ័រ និងតុលាការ អាយ.ស៊ី.ធី.វ៉ាយ អនុញ្ញាតឲ្យប្រើប្រាស់សក្ខីកម្ម តាមរយៈសោតទស្សន៍នៅពេលដែលសាក្សីមិនអាច ឬមានហេតុផលសមរម្យដែលបង្ហាញថា ខ្លួនមិនអាចផ្ដល់សក្ខីកម្មដោយផ្ទាល់បាន និងសក្ខីកម្មរបស់សាក្សីនោះ ពិតជាមានសារៈសំខាន់ ដែលអាចនឹងបណ្ដាលឲ្យមានភាពអយុត្តិធម៌ដល់ភាគី ដែលបានស្នើសុំ។ ប្រសិនបើអង្គជំនុំជម្រះដំណើរការដោយពុំមានសក្ខីកម្មរបស់សាក្សីរូបនោះទេ។ ភាគីដែលបានស្នើសុំប្រើប្រាស់បច្ចេកវិទ្យាវីដេអូ ត្រូវធានាជូនអង្គជំនុំជម្រះសាលាដំបូងថា គឺត្រូវតែស្របទៅតាមធាតុផ្សំទាំងអស់នេះ។

[១១:៥៥:៥០]

ទោះបីតុលាការមិនអចិន្ត្រៃយ៍ចំនួនពីរ គឺតុលាការ អាយ.ស៊ី.ធី.អ័រ និងតុលាការ អាយ.ស៊ី.ធី.វ៉ាយ ជាអ្នកបានបង្កើតលក្ខខណ្ឌស្រដៀងៗគ្នាសម្រាប់គោលបំណងនៃការសម្រេចថា តើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍អាចអនុញ្ញាតបានដែរឬទេ ឬក៏យ៉ាងណា? ក៏តុលាការទាំងពីរនេះ បានប្រកាន់យកវិធីសាស្ត្រខុសគ្នាច្រើនក្នុងការប្រើប្រាស់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ដែរ។ សហព្រះរាជអាជ្ញាមិនឯកភាពទៅនឹងការលើកឡើងរបស់មេធាវីការពារជនជាប់ចោទ អៀង សារី ចំពោះបញ្ហានេះឡើយ។ ហើយសុំអង្គជំនុំជម្រះ សូមអង្គសវនាការពិនិត្យមើលឯកសារយោង E166/1/1 ត្រង់កថាខណ្ឌ១៩។

[១១:៥៦:៣៥]

តុលាការ អាយ.ស៊ី.ធី.អ័រ តែងតែធ្លាប់បានសម្រេចថា ការប្រើប្រាស់បច្ចេកវិទ្យាវីដេអូ គឺជាវិធានការពិសេស ដែលអាចត្រូវបានអនុញ្ញាតនៅពេលមានហេតុផលត្រឹមត្រូវតាមច្បាប់ លើកចំពោះអង្គជំនុំជម្រះ ដោយមានឯកសារសំអាងយ៉ាងត្រឹមត្រូវ។ តាមរយៈការប្រៀបធៀបយើងឃើញថា ក្នុងការទទួលស្គាល់អំពីតម្រូវការពន្លឿនកិច្ចដំណើរការនីតិវិធី ជំនុំជម្រះតុលាការ អាយ.ស៊ី.ធី.វ៉ាយ បានអនុវត្តវិធីសាស្ត្របត់បែនជាងនេះជាបណ្តើរៗ។ លក្ខខណ្ឌតម្រូវដើមដែលថា បច្ចេកវិទ្យាសោតទស្សន៍នឹងត្រូវបានអនុញ្ញាតតែនៅក្នុងកាលៈទេសៈពិសេស ត្រូវបានបោះបង់ចោល។

វិធានថ្មីមួយត្រូវបានបង្កើតឡើងដែលអាស្រ័យទៅលើការបំពេញលក្ខខណ្ឌខាងលើ អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង-- អនុញ្ញាតឱ្យមានការប្រើប្រាស់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ នៅពេលណាផលប្រយោជន៍នៃយុត្តិធម៌ តម្រូវឱ្យធ្វើយ៉ាងដូច្នេះជាចាំបាច់។

[១១:៥៧:៣០]

ជាងនេះទៅទៀត តុលាការ អាយ.ស៊ី.ធី.វ៉ាយ ៗ ក៏បានបញ្ជាក់អំពីតម្លៃជាភស្តុតាងនៃសក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ហើយវិធានដើមដែលបានបង្កើតឡើងនៅក្នុងសំណុំរឿងរដ្ឋអាជ្ញាទល់នឹង *តាឌិក* ដែលមេធាវីការពារជនជាប់ចោទ អៀង សារី បានលើកត្រង់កថាខណ្ឌ២០ នៃអំណះអំណាងរបស់ខ្លួនយោងតាមឯកសារ E166/1/1 ដែលបានចែងថា ភស្តុតាងដែលផ្តល់តាមរយៈ--

**អ្នកបកប្រែ៖**

លោកចៅក្រមប្រធាន សូមអនុញ្ញាតឱ្យលោកព្រះរាជអាជ្ញា *ស្មួដោន* បន្តិចទាន។

**លោក ច័ន្ទ តាភារស្មី៖**

ជាងនេះទៅទៀតតុលាការ អាយ.ស៊ី.ធី.វ៉ាយ ក៏បានបញ្ជាក់អំពីតម្លៃជាភស្តុតាងនៃសក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍។

[១១:៥៨:១៣]

វិធានដើមដែលបានបង្កើតឡើងនៅក្នុងសំណុំរឿងរដ្ឋអាជ្ញាទល់នឹង *តាឌិក* ដែលមេធាវីការពារជនជាប់ចោទ អៀង សារី បានលើកឡើងត្រង់កថាខណ្ឌ២០ នៃអំណះអំណាងរបស់ខ្លួនយោងតាមឯកសារ E166/1/1 ដែលបានចែងថា ភស្តុតាងដែលផ្តល់តាមរយៈប្រព័ន្ធសោតទស្សន៍ពុំសូវមានទម្ងន់ដូចភស្តុតាងដែលផ្តល់ផ្ទាល់នៅសវនាការឡើយ។ ជំហររបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ បានប្រែប្រួលគួរឲ្យកត់សម្គាល់ចាប់ពីពេលនោះមក។ នៅក្នុងច្បាប់យុត្តិសាស្ត្ររបស់ខ្លួននាពេលទើបកន្លងផុតទៅថ្មីៗនេះរួមទាំងសេចក្តីសម្រេចនៅក្នុងសំណុំរឿង *ហាកហ្ស៊ីហាសាណូវិច (Hadzihasanovic)* ចាប់ពីឆ្នាំ២០០៤ និងនៅក្នុងសំណុំរឿង *លុគិច (Lukic)* ពីឆ្នាំ២០០៩ តុលាការ អាយ.ស៊ី.ធី.វ៉ាយ បានរក្សាជំហរថា ភស្តុតាងដែលផ្តល់តាមប្រព័ន្ធសោតទស្សន៍មានតម្លៃជាភស្តុតាងខ្ពស់ ដូចភស្តុតាងដែលផ្តល់ឲ្យដោយផ្ទាល់ដែរ។ សូម្បីតែនៅមុនពេលសេចក្តីសម្រេចទាំងនេះ ចៅក្រម វីឆាត មេយ៍ និងចៅក្រម ម៉ារីកតា វីដា ដែលជាអ្នកជំនាញច្បាប់ស្តីពីភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ បានសង្កេតឃើញថា នៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ ឧស្សាហ៍មានសក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ច្រើនគួរសមដែរ។

[១១:៥៩:៤៧]

ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ខ្ញុំសូមលើកឡើងដូចតទៅ៖

បើងាកមកតុលាការព្រហ្មទណ្ឌអន្តរជាតិបើយោងតាមមាត្រា៦៩ ចំណុច២ នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម បានចែងថា ទោះបីសាក្សីត្រូវផ្តល់សក្ខីកម្ម ដោយផ្ទាល់ក្តី ក៏អង្គជំនុំជម្រះសាលាដំបូងអាចអនុញ្ញាតឲ្យមានការប្រើប្រាស់សក្ខីកម្ម តាមប្រព័ន្ធសោតទស្សន៍ផងដែរ។ បើអនុលោមតាមបញ្ញត្តិនៃលក្ខន្តិកៈនេះ និងវិធាន នៃនីតិវិធី និងភស្តុតាង ក៏បានបញ្ជាក់យ៉ាងដូច្នេះដែរ។ ម៉្យាងទៀតនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង ចាំបាច់ត្រឹមតែជឿជាក់ថា សិទ្ធិរបស់ជនជាប់ចោទ ក្នុងការសួរដេញដោលសាក្សីដាក់បន្ទុកត្រូវបានគោរព និងការប្រើប្រាស់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ នឹងធ្វើឲ្យសាក្សីមានលទ្ធភាពទទួលបានការសួរដេញដោល ដោយភាគី ព្រះរាជអាជ្ញា មេធាវី

ការពារក្តី និងអង្គជំនុំជម្រះ ពោលគឺនៅពេលដែលសាក្សីផ្តល់សក្ខីកម្ម។ យោងតាមវិធាន៦៧ នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[១២:០១:00]

លោក លោកស្រីចៅក្រមជាទីគោរព! នៅចុងក្រោយនេះ ខ្ញុំសូមបង្ហាញជូននូវការយល់ឃើញជាចុងក្រោយថា ការបង្កើតវិធាននៃតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺស្រដៀងគ្នាខ្លាំងទៅនឹងវិធាន២៦/១ នៃវិធានផ្ទៃក្នុងដែលសបញ្ជាក់បន្ថែមទៀត អំពីទំនោរទៅរកវិធីសាស្ត្របត់បែន និងត្រូវបានកំណត់យកធ្វើគោលការណ៍ ក្នុងការប្រើប្រាស់បច្ចេកវិជ្ជាប្រព័ន្ធសោតទស្សន៍នៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។

នាទីបញ្ចប់ ខ្ញុំសូមអស់លោក លោកស្រីចៅក្រម មេត្តាពិនិត្យពិចារណាទៅលើវិធាន២៦.២ នៃវិធានផ្ទៃក្នុងទៅលើសក្ខីកម្មរបស់អ្នកជំនាញ ដែលមានរហស្សនាម TC-38 ព្រោះវិធាន២៦.១ គឺវិធានដែលមានសារៈសំខាន់បំផុត ហើយអ្វីដែលខ្ញុំលើកឡើងនេះ គឺជាការយល់ឃើញរបស់សហព្រះរាជអាជ្ញា ហើយសូមឲ្យអង្គជំនុំជម្រះមេត្តាពិនិត្យ និងពិចារណាទៅតាមគតិច្បាប់។ សូមអរគុណបាទ។

ខ្ញុំសូមបញ្ចប់ការយល់ឃើញរបស់ខ្ញុំតែប៉ុណ្ណេះ ហើយសូមបញ្ចប់។ សូមអរគុណលោកប្រធាន។

[១២:០២:០៥]

**ប្រធានអង្គជំនុំ៖**

បញ្ហាទីពីរគឺ ជំទាស់ទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលស្នើសុំយកឯកសារបន្ថែមពីអ្នកជំនាញមុន មុនពេលអ្នកជំនាញផ្តល់សក្ខីកម្ម។ តើខាងសហព្រះរាជអាជ្ញាមានត្រូវលើកឡើងបញ្ហានេះដែរឬទេ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សហសេវិករបស់ខ្ញុំ គាត់បានបញ្ចប់ផ្នែករបស់គាត់ ហើយខ្ញុំនិយាយអំពីផ្នែករបស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងបញ្ហាសោតទស្សន៍ដដែល។ ដោយខ្ញុំគិតថា នៅពេលនេះគឺពេលថ្ងៃត្រង់ហើយ ដូច្នេះតើអង្គជំនុំជម្រះសម្រេចយ៉ាងណា ពាក់ព័ន្ធនឹងពេលវេលា តើយើងអាចសម្រាកសិនឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបហើយថាលោក មានពេល១៥នាទី គឺរហូតដល់ពីម៉ោងដប់ពីរដប់ប្រាំនាទី ក្នុងការបង្ហាញនេះ ដើម្បីអង្គជំនុំជម្រះ លៃពេលវេលាឲ្យបានចប់នៅរសៀលនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ថា យើងនឹងមិននិយាយវែងទេទៅលើសំណើរបស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងការស្នើសុំឯកសារបន្ថែមនោះ។ ជាដំបូង ខ្ញុំសូមបញ្ចប់នូវផ្នែកពាក់ព័ន្ធទៅនឹងប្រព័ន្ធសោតទស្សន៍សិន ដោយសារតែយើងមានសិទ្ធិក្នុងការឆ្លើយតបនោះ យើងចង់ស្តាប់នូវសម្តីរបស់មេធាវីការពារក្តីសិន ពាក់ព័ន្ធទៅនឹងសំណើរបស់គាត់អំពីព័ត៌មានបន្ថែម សូមឯកសារបន្ថែមដែលត្រូវផ្តល់ដោយអ្នកជំនាញ ប៉ែន យៀវនិន ហើយបន្ទាប់មកបានយើងខ្ញុំឆ្លើយតប។ ដូច្នេះរហូតដល់ម៉ោងដប់ពីរដប់ប្រាំនាទីនេះ ខ្ញុំនឹងបន្ត និយាយអំពីបញ្ហាការធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍សិន។ ខ្ញុំនឹងពង្រីកបន្ថែមអ្វីដែលបាននិយាយ បើតាមយើងសហព្រះរាជអាជ្ញានៅចំពោះមុខ អ.វ.ត.ក មិនមានបន្ទុកក្នុងការបង្ហាញថា មិនអាចសម្រាប់សាក្សី ឬក៏អ្នកជំនាញក្នុងការបង្ហាញខ្លួនដោយផ្ទាល់ពីព្រោះថា យើងមិនមែនស្ថិតនៅក្នុងប្រព័ន្ធខំមិនឡូទេ ហើយយើងក៏មិនមែនជាអ្វីដែលគេយើងហៅ នៅចំពោះមុខតុលាការយូហ្គោស្លាវី ថាជាភាគីស្នើសុំ ឬក៏ជាអ្នកស្នើសុំឲ្យមានការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍ សម្រាប់សាក្សីអ្នកជំនាញរបស់អង្គជំនុំជម្រះនោះដែរ។ គឺយើងគិតថា អង្គជំនុំជម្រះ ជាអ្នកពិនិត្យមើលទៅលើព័ត៌មានទាំងអស់ ដែលអង្គជំនុំជម្រះមាន ក៏ដូចជាព័ត៌មានដែលផ្តល់ជូនដោយសហព្រះរាជអាជ្ញា ទៅតាមសំណើរបស់អង្គជំនុំជម្រះ ដើម្បីអនុវត្តនូវអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនពាក់ព័ន្ធទៅនឹងវិធាន២៦ អនុវិធាន១។ ក្នុងការអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះជាដំបូងត្រូវពិនិត្យមើលថា តើការស្តាប់សក្ខីកម្មអ្នកជំនាញការនោះ អាចធ្វើបានទៅរួចដោយផ្ទាល់ដែរឬទេ? មេធាវីការពារក្តី អៀង សារី បានបកស្រាយលក្ខណៈវិនិច្ឆ័យនេះទូលំទូលាយពេក ហើយអះអាងថា គឺសហ-ព្រះរាជអាជ្ញាដែលត្រូវបានតម្រូវដោយវិធាន២៦ អនុវិធាន១ ក្នុងការបង្ហាញថា មិនអាចស្តាប់សក្ខីកម្មអ្នកជំនាញ ប៉ែន យៀវនិន ដោយផ្ទាល់នោះទេ។ គឺ កថាខណ្ឌ១៦ នៃឯកសារ E166/1/1។ យើងខ្ញុំសូមជំទាស់ទៅនឹងការបកស្រាយនេះ ហើយយើងយល់ឃើញថា គ្មានអ្វីនៅក្នុងវិធាន២៦ ដែលអះអាងថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការបង្ហាញអំពីអលទ្ធភាពនោះទេ។ យើងបាននិយាយរួចហើយនៅចំពោះមុខតុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ គឺភាគីស្នើសុំដែលជាអ្នកចង់ប្រើប្រាស់មធ្យោបាយសោតទស្សន៍ ហើយដែលមានបន្ទុកក្នុងការបង្ហាញភស្តុតាងថា សាក្សី ឬអ្នកជំនាញមិនមានលទ្ធភាពក្នុងការបង្ហាញ ឬក៏មានមូលហេតុ មានសុពលភាពណាមួយក្នុងការបដិសេធមិនមកបង្ហាញខ្លួន។

[១២:០៦:៣៣]

បន្ទុកនេះមិនអាចត្រូវបានអនុវត្តចំពោះសហព្រះរាជអាជ្ញានៅចំពោះមុខ អ.វ.ត.ក ទេ។ នៅទីនេះ សហព្រះរាជអាជ្ញាគ្រាន់តែចេញ-- ផ្តល់ជាអនុសាសន៍ទៅតាមការណែនាំផ្ទាល់របស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងបែបបទនៃការស្តាប់សក្ខីកម្មសាក្សីជំនាញរូបនេះ។

ចំពោះបញ្ហានេះ សូមផ្តល់នូវការបញ្ជាក់ពាក់ព័ន្ធទៅនឹងបញ្ហាខ្លឹមសារ ដែលមានសារៈសំខាន់ណាស់។ នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះលេខ E172/5 ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១២ ហើយដែលបានកែប្រែជាភាសាបារាំង។ នៅក្នុងកថាខណ្ឌ៦ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះទទួលសំណើរបស់សហព្រះរាជអាជ្ញាសំដៅឲ្យសាក្សី TCE-38 ធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតាមរយៈប្រព័ន្ធសោតទស្សន៍។ ហើយនៅក្នុងភាសាអង់គ្លេសមានប្រើពាក្យថា សំណើពីសហព្រះរាជអាជ្ញា។ ខ្ញុំមិនមែនមានភាពតឹងតែងនោះទេ ក៏ប៉ុន្តែពាក្យថា សំណើ ដែលប្រើប្រាស់នៅទីនេះ ដោយអង្គជំនុំជម្រះនោះ ហាក់ដូចជាមិនបង្ហាញ ឬក៏ឆ្លុះបញ្ចាំងអំពីអាណត្តិ ដែលអង្គជំនុំជម្រះខ្លួនឯងផ្ទាល់ បានផ្តល់ជូនសហព្រះរាជអាជ្ញា នៅក្នុងអនុស្សរណៈ E166 ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ ដែលបាននិយាយថា ផ្តល់ក្នុងរយៈពេលបីសប្តាហ៍នូវអនុសាសន៍ ពាក់ព័ន្ធទៅនឹងការបង្កើតកាលវិភាគ និងបែបបទនៃស្តាប់សក្ខីកម្មរបស់បុគ្គលនេះ។ ហើយដើម្បីធ្វើការកិច្ចនេះ គឺអនុញ្ញាតឲ្យយើងខ្ញុំទំនាក់ទំនងជាមួយនឹងបុគ្គលនេះ ក្នុងគោលដៅតែមួយគត់ ដើម្បីពិនិត្យមើលថា តើសាក្សី អ្នកជំនាញនេះ មានពេលវេលាគ្រប់គ្រាន់ ឬក៏អត់? ហើយដើម្បីជួយឲ្យអង្គជំនុំជម្រះ ក្នុងការត្រៀមរៀបចំកម្មវិធីកាលវិភាគសម្រាប់ធ្វើសក្ខីកម្មក្នុងឋានៈជាសាក្សីអ្នកជំនាញ។

[១២:០៨:២៩]

យើងខ្ញុំបានគោរពទៅតាមអាណត្តិនេះទាំងស្រុង ហើយដោយធ្វើអនុសាសន៍ដែលយើងបានដាក់ចំណងជើងថា “សេចក្តីជូនដំណឹង” ទៅដល់អង្គជំនុំជម្រះ និងភាគី ពាក់ព័ន្ធទៅនឹងការមកធ្វើសក្ខីកម្មរបស់អ្នកជំនាញរូបនេះ ហើយនៅក្នុងឯកសាររបស់យើង គឺលេខ E166/1។ អង្គជំនុំជម្រះបានឃើញថា យើងមិនបានធ្វើជាសំណើនោះទេ គឺនៅគ្រប់កថាខណ្ឌ ឬក៏គ្រប់ឃ្លាទាំងអស់ យើងប្រើពាក្យថា អនុសាសន៍។ យើងមិនមែនជាភាគីស្នើសុំនោះទេ យើងគ្រាន់តែដើរតួនាទីជាអន្តរការីដែលបានផ្តល់តួនាទីឲ្យយើង រវាងអង្គជំនុំជម្រះ និងអ្នកជំនាញ។ តួនាទីរបស់យើងគឺជាអ្នកទទួលអាណត្តិក្នុងការធ្វើរបាយការណ៍ជូនអង្គជំនុំជម្រះដែលបានផ្តល់អាណត្តិមកឲ្យយើង ហើយនិងធ្វើរបាយការណ៍ជូនភាគីអំពីបេសកកម្មដែលអង្គជំនុំជម្រះបានប្រគល់ជូន។

យើងខ្ញុំនិយាយជាថ្មីម្តងទៀត ពីព្រោះថាវាមានសារៈសំខាន់ណាស់ ក៏ដូចជាខាងមេធាវីការពារក្តីដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងអង្គជំនុំជម្រះដែរថា លោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន គឺត្រូវចង់ឲ្យគាត់នេះ មកផ្តល់សក្ខីកម្មដោយផ្ទាល់ ជាជាងការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍។ ក៏ប៉ុន្តែគឺអង្គជំនុំជម្រះជាអ្នកសម្រេច ជាអ្នកជ្រើសរើសអំពីសាក្សីដែលខ្លួនចង់ស្តាប់សក្ខីកម្ម ដើម្បីចូលរួមចំណែកនៅក្នុងការស្វែងរកការពិត ហើយនិងទៅតាមបែបបទ ដែលអង្គជំនុំជម្រះយល់ឃើញថា សមស្របបំផុតនោះ។

[១២:០៩:៥៩]

សាក្សី និងអ្នកជំនាញគឺមិនស្ថិតនៅក្រោមចំណុះរបស់ភាគីទេ គឺស្ថិតនៅក្រោមចំណុះរបស់អង្គជំនុំជម្រះ។ ដូច្នេះ មិនមែនជាសាក្សី ឬជាអ្នកជំនាញរបស់ភាគីនោះទេ ទោះបីជាអ្នកណាជាអ្នកស្នើក៏ដោយនោះ គឺអង្គជំនុំជម្រះជាអ្នកសម្រេច ហើយសុទ្ធសឹងតែជាសាក្សី និងអ្នកជំនាញរបស់អង្គជំនុំជម្រះ។ នេះគឺជាភាពខុសគ្នាជាមូលដ្ឋានពាក់ព័ន្ធលើបញ្ហានីតិវិធី។

ដូច្នេះ ខ្ញុំយល់ឃើញថា អង្គជំនុំជម្រះមានលក្ខណៈ-- ចរិតលក្ខណៈដូចគ្នា ដោយសារតែសាក្សី ហើយនិងអ្នកជំនាញនោះគឺសុទ្ធសឹងតែជាអ្នកសាក្សី និងអ្នកជំនាញរបស់អង្គជំនុំជម្រះ។ ហើយតុលាការនេះគឺមិនមានលក្ខណៈដូចគ្នាទៅនឹងតុលាការមិនអន្តរជាតិអចិន្ត្រៃយ៍នោះទេ។ អាស្រ័យហេតុនេះ វិធាន២៦(១) នេះ មិនបានតម្រូវឲ្យសហព្រះរាជអាជ្ញាផ្តល់-- តម្រូវសហព្រះរាជអាជ្ញាបញ្ជាក់ថាខ្លួនគឺសាក្សី TC-38 នេះមិនអាចមកបង្ហាញខ្លួនដោយផ្ទាល់នោះទេ ផ្ទុយទៅវិញគឺអង្គជំនុំជម្រះជាអ្នកសម្រេចថា តើខ្លួនប្រើប្រាស់មធ្យោបាយសោតទស្សន៍នេះក៏អត់? ហើយវាជា ហើយទៅតាមការសម្រេចរបស់អង្គជំនុំជម្រះទៅលើមូលហេតុដែលផ្តល់ជូនទៅលើសាក្សីអ្នកជំនាញ ពាក់ព័ន្ធទៅនឹងអលទ្ធភាពរបស់គាត់ក្នុងការមកធ្វើសក្ខីកម្មដោយផ្ទាល់នេះ។ សាស្ត្រាចារ្យសាកលវិទ្យាល័យយែល ប៉ែន ឃៀរនិន បានជម្រាបជូនអង្គជំនុំជម្រះតាមរយៈលិខិតឆ្លើយឆ្លង ដែលបានទាក់ទងគ្នាជាមួយនឹងសហព្រះរាជអាជ្ញា ហើយនិងត្រូវបានផ្ញើជូនទៅអង្គភាពគាំទ្រសាក្សី និងជំនាញនោះ ដែលខ្ញុំហៅថា *វេ.ស៊ូ* (WESU) ដូចតាមការតម្រូវរបស់អង្គជំនុំជម្រះ ដើម្បីធ្វើយ៉ាងម៉េចឲ្យមានតម្លាភាពនោះ គឺគាត់បានជម្រាបថា ដោយសារតែគាត់មានកាតព្វកិច្ចវិជ្ជាជីវៈនោះ គាត់មិនអាចមកធ្វើសក្ខីកម្មដោយផ្ទាល់នៅប្រទេសកម្ពុជានៅឆ្នាំ២០១២បានទេ។ ប៉ុន្តែគាត់ទំនងជានឹងអាចមកបង្ហាញខ្លួនបាននៅឆ្នាំ២០១៣។

[១២:១២:០៧]

សហព្រះរាជអាជ្ញាបានស្នើសុំយ៉ាងទទូច ឲ្យអ្នកជំនាញផ្តល់ជូនអង្គជំនុំជម្រះជាលាយលក្ខណ៍

នូវមូលហេតុដែលបញ្ជាក់អំពីអលទ្ធភាពរបស់គាត់ ក្នុងការមកបង្ហាញខ្លួនដោយផ្ទាល់នៅឆ្នាំ២០១២។ មួយរយៈពេលក្រោយមក គាត់ពិតជាបានផ្តល់នូវបញ្ជីមួយ គឺផ្តល់របាយការណ៍មួយ គឺនៅថ្ងៃទី៧ មីនា ឆ្នាំ២០១២ គឺគាត់បញ្ជាក់លម្អិតអំពីភាពមមាញឹកក្នុងអាជីពរបស់គាត់នៅក្នុងសាកលវិទ្យាល័យយែល ហើយយើងក៏បានផ្តល់ជូនទៅខាង វេ.ស៊ូ ផងដែរ។ យើងមិនចង់ក្បត់ទៅនឹងភារកិច្ចដែលបានផ្តល់ជូនយើងនោះទេ។

ដូច្នេះ គឺអង្គជំនុំជម្រះមិនមែនជាសហព្រះរាជអាជ្ញានោះទេ ក្នុងការសម្រេចថា តើខ្លួនចង់អាននូវបញ្ជីភាពមមារ-- អានអំពីមូលដ្ឋានដែលបានផ្តល់ជូនដោយសាស្ត្រាចារ្យ ប៊ែន យៀរនិន នៅក្នុងសវនាការនេះ ឬក៏អត់នោះ? ប្រសិនបើជាករណីមែននោះ យើងអាចធ្វើការអាននេះបាន។

[១២:១៣:១៤]

លោក ប៊ែន យៀរនិន ក៏បានជូនដំណឹងដល់សហព្រះរាជអាជ្ញាផងដែរថា ខ្លួនប្រហែលជាអ្នកមានភាពទំនេរដើម្បីផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅចុងខែមីនា ឬក៏ដើមខែមេសា ឬក៏ពាក់កណ្តាលខែមេសា ហើយបន្ទាប់មកទៀត គាត់បានបញ្ជាក់ថា គាត់អាចមានភាពទំនេរនៅខែឧសភា ឆ្នាំ ២០១២។

យោងតាមព័ត៌មានដែលបានផ្តល់ជូនថ្មីៗនេះដោយលោកអ្នកជំនាញ ប៊ែន យៀរនិន ក៏ដូចជាការផ្លាស់ប្តូរយោបល់គ្នាកាលពីមុនជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ និងអ្នកជំនាញ (សូមទោស) អង្គភាពគាំពារសាក្សី និងអ្នកជំនាញ គឺអង្គជំនុំជម្រះជាអ្នកពិនិត្យមើលទៅលើការមកបង្ហាញខ្លួនដោយផ្ទាល់របស់សាក្សី TCE-38 ហើយបើសិនបើមែននោះ ថាតើនៅពេលណា? ក៏ប៉ុន្តែការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍នេះ គឺនៅពេលនេះ គឺជាមធ្យោបាយតែមួយគត់ដែលអាចធ្វើទៅបានដើម្បីធានានូវការផ្តល់សក្ខីកម្មនៅក្នុងរយៈពេលសមស្រប។

[១២:១៤:១៣]

ហេតុនេះហើយ បានជាយើងបានធ្វើអនុសាសន៍បន្ទាប់ពីខាង វេ.ស៊ូ បានព្យាយាមដោយឥតលទ្ធផលក្នុងការធានាអំពីភាពទំនេររបស់សាក្សីរូបនេះ ក្នុងការមកបង្ហាញខ្លួនដោយផ្ទាល់។

ដូច្នេះ បើតាមការពិតមែននោះ បើយើងពិនិត្យមើលតាមការពិតទៅ គឺគ្មានមធ្យោបាយអ្វីក្រៅពីតែធ្វើការស្តាប់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍នោះទេ។

ខ្ញុំនឹងនិយាយអំពីចំណុចមួយទៀត។ ហើយនៅពេលនេះម៉ោងដប់ពីដប់ប្រាំនាទីរួចហើយ។ តើខ្ញុំ

បន្តទៀត ឬក៏ខ្ញុំផ្អាកត្រឹមនេះសិន លោកប្រធាន?

[១២:១៤:៥៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលម៉ោងកំណត់ដែលត្រូវសម្រាកហើយ ហើយលើសរហូតដល់១៥នាទីឯណោះ។ អ៊ីចឹង ម្យ៉ាងទៀត ក៏បញ្ហាស៊ីឌី ក៏អស់ហើយដែរ។ អ៊ីចឹងសវនាការនេះគឺផ្អាកត្រឹមនេះដើម្បីពិសាអាហារថ្ងៃត្រង់ ហើយសវនាការនឹងបន្តធ្វើនៅរសៀលនេះ ចាប់ពីម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមលើកឡើងដោយខ្លី ប្រហែលជាមានការចាប់អារម្មណ៍ ដោយអង្គជំនុំជម្រះថាព័ត៌មានរបស់សហព្រះរាជអាជ្ញា ពីសហព្រះរាជអាជ្ញា ព័ត៌មានដែលថាសហព្រះរាជអាជ្ញាធ្វើទំនាក់ទំនងជាមួយនឹងលោក ប៉ែន យៀវនិន នោះ គឺយើងមិនដែលទទួលលិខិតទំនាក់ទំនងនោះទេ។ នៅថ្ងៃទី៩ យើងបានបញ្ជូនសារណារបស់យើង ហើយបញ្ជូនលិខិតទៅដល់មន្ត្រីច្បាប់ដោយសុំអង្គជំនុំជម្រះបង្គាប់ទៅសហព្រះរាជអាជ្ញាផ្ដល់ជូនលិខិតឆ្លើយឆ្លងនោះមកឲ្យយើងខ្ញុំផង។

[១២:១៦:០៦]

យើងបានថតចម្លងលិខិតនេះ ប៉ុន្តែមកពេល មកទល់ពេលនេះយើងមិនបានទទួលការឆ្លើយតបពីមន្ត្រីច្បាប់នោះទេ។ ដូច្នេះប្រសិនបើខ្ញុំសូមលើកឡើងនេះ ដោយសារតែពួកគាត់លើកឡើងអំពីបញ្ហាតម្លាភាព យើងខ្ញុំនេះ គួរតែទទួលបានលិខិតឆ្លើយឆ្លងរវាងសហព្រះរាជអាជ្ញា និង ប៉ែន យៀវនិន ថាតើហេតុអ្វីបានជាគាត់មិនមានលទ្ធភាពមកផ្ដល់សក្ខីកម្មក្នុងឆ្នាំ២០១២ ហើយអាចផ្ដល់សក្ខីកម្មមកឆ្នាំ នៅឆ្នាំ២០១៣វិញ។ ដូច្នេះហើយក្នុងពេលអាហារថ្ងៃត្រង់នេះ អង្គជំនុំជម្រះអាចបង្គាប់ឲ្យមានការបញ្ជូនលិខិតឆ្លើយឆ្លងទាំងអស់នេះឲ្យយើងខ្ញុំបានទទួល និងបានដឹងផង ដើម្បីឲ្យយើងទទួលនូវសិទ្ធិសមភាពរវាងភាគី រវាងគូភាគីក្ដី។

ដូច្នេះហើយវាអាចជាព័ត៌មានមួយសម្រាប់យើងខ្ញុំ។ យើងខ្ញុំសូមបញ្ជាក់ឡើងវិញថា ព័ត៌មាននៃការឆ្លើយឆ្លងរវាងសហព្រះរាជអាជ្ញា និង ប៉ែន យៀវនិន នោះមិនបានចែកជូនឲ្យខាងសហមេធាវីការពារក្ដីបានដឹងនោះឡើយ។ សូមអរគុណ។

[១២:១៧:១១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំក្នុងនាម តាំងនាមឱ្យកូនក្តីរបស់ខ្ញុំនេះ គឺថាគាត់ស្នើសុំឱ្យគាត់ហ្នឹងទៅតាមដាននីតិវិធីសវនាការនៅពេលរសៀលក្រោយពេលសម្រាកនេះនៅបន្ទប់រង់ចាំខាងក្រោយ។ ខ្ញុំមានលិខិតនេះជាលាយលក្ខណ៍អក្សរហើយ ហើយខ្ញុំនឹងបញ្ជូនទៅអង្គជំនុំជម្រះនាពេលបន្តិចទៀតនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ គឺគាត់សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម បន្ទប់សវនាការនេះតាមរយៈប្រព័ន្ធសោតទស្សន៍ ដោយលះបង់សិទ្ធិមិនចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃក្នុងបន្ទប់សវនាការនេះ។

[១២:១៨:០០]

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំនេះ។ ហើយឱ្យក្រុមមេធាវីការពារក្តីជនជាប់ចោទប្រគល់មកឱ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ដោយមានចុះហត្ថលេខា និងស្នាម ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទផង ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់កិច្ចដំណើរការសវនាការនៅរសៀលនេះ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបទៅកាន់បន្ទប់រង់ចាំ ហើយនៅរសៀលនេះ បង្គាប់ឱ្យនាំខ្លួនតែជនជាប់ចោទ ខៀវ សំផន មកកាន់បន្ទប់សវនាការឱ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:១៨នាទី ដល់ម៉ោង ១៣:៤២នាទី)*

[១៣:៤២:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការបង្ហាញនូវឯកសារភស្តុតាងលើសំណើសុំរបស់ខ្លួន។ ហើយសូមបញ្ជាក់ថា ដោយពេលវេលាដែលក្រុមសហព្រះរាជអាជ្ញាបានធ្វើនេះ គឺរក្សាសិទ្ធិនៅក្នុងការឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តី អៀង សារី លើការសុំយកឯកសារបន្ថែមពីអ្នកជំនាញមុនពេលអ្នកជំនាញផ្តល់សក្ខីកម្ម ក្រោយពេលមេធាវីការពារក្តីលើកទឡ្ហីករណ៍បង្ហាញពីបញ្ហានេះ នោះពេលវេលាដែលបានផ្តល់ឲ្យត្រូវកាត់បន្ថយ១៥នាទី ដើម្បីទុកពេលវេលាដើម្បីឆ្លើយតបនៅពេលក្រោយ។ ហើយដូចគ្នា គឺក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺផ្តល់តែ២០នាទីទេ ទុក១០នាទី សម្រាប់ឆ្លើយតបនៅពេលក្រោយ។

សូមអញ្ជើញ!

[១៣:៤៤:២២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

ឥឡូវនេះ ខ្ញុំសូមចូលទៅចំណុចទីពីរ គឺនិយាយអំពីសារៈសំខាន់នៃសក្ខីកម្មរបស់អ្នកជំនាញ ប៉ែន ឃៀរនិន។ លោក ប៉ែន ឃៀរនិន ត្រូវបានស្នើដោយសហព្រះរាជអាជ្ញានៅ-- ចេញពីបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបាន-- ដែលធ្វើឡើងយោងតាមវិធាន៨០ គឺឯកសារ E9/4.2 ហើយយើងបានបញ្ជាក់អំពីមូលហេតុជាក់លាក់ នៃសារៈសំខាន់នៃសក្ខីកម្មរបស់គាត់នៅលើឯកសារបីទំព័រ ដែលមានលេខ E9/13.1 នៅក្នុងផ្នែក "ការប្រព្រឹត្តទៅលើក្រុមជាក់លាក់" ហើយស្ថិតនៅក្នុងលេខរៀង P250។ អ្នកជំនាញនេះ គឺជាអ្នកចេះដឹងខាងផ្នែកសាកលវិទ្យាល័យដែលបានសិក្សា ហើយនិងបោះពុម្ពផ្សាយអំពីប្រវត្តិកម្ពុជា ហើយជាពិសេសអំពីសម័យកម្ពុជាប្រជាធិបតេយ្យ ហើយយើងបានលើកឡើងអំពីសារៈសំខាន់នៃអត្ថបទសំណេររបស់គាត់ ហើយនិងសៀវភៅបីសំខាន់ៗរបស់គាត់។ យើងក៏បានលើកឡើងអំពីតួនាទីដ៏សំខាន់របស់គាត់នៅក្នុងការប្រមូលឯកសារច្បាប់ដើម ដែលក្នុងនោះមានកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ឬក៏ឯកសារស្រុកត្រាំកក់ជាដើម។

[១៣:៤៥:៥១]

នៅក្នុងសវនាការវគ្គដំបូង អ្នកជំនាញអាចផ្តល់នូវការបំភ្លឺទៅលើកថាខណ្ឌពាក់ព័ន្ធទាំងមូល នៃដីកាដំណោះស្រាយ។ ខ្ញុំសូមនិយាយអំពីចំណុចមួយទៀត អ្នកជំនាញនេះត្រូវបានកំណត់ថាជាអ្នកជំនាញ

គន្លឹះដោយសហជនជាប់ចោទពីររូប បន្ថែមពីលើសហព្រះរាជអាជ្ញា។ ខាងមេធាវី នួន ជា បានចាត់ទុកអ្នកជំនាញនេះ ជាអ្នកជំនាញដែលមានសារៈសំខាន់សម្រាប់សំណុំរឿងនៃកូនក្ដីរបស់ខ្លួន។ សូមយោងទៅលើឯកសារលេខ E93/9 ក្នុងកថាខណ្ឌ៧ ដែលយើងត្រូវអានរួមគ្នាជាមួយនឹងឧបសម្ព័ន្ធ E93/9.1 ដែលមានលេខកូដ A23។ មេធាវីការពារក្ដី នួន ជា បានបញ្ជាក់យ៉ាងច្បាស់អំពីចេតនារបស់ខ្លួនក្នុងការដាក់ឯកសារជូនអង្គជំនុំជម្រះតាមរយៈអ្នកជំនាញនេះ។ សូមមើលប្រតិចារឹកជាភាសាអង់គ្លេសនៅថ្ងៃទី១៦ មករា ឆ្នាំ២០១២ នៅទំព័រ៣៨ បន្ទាត់១៨ ដល់២២។

[១៣:៤៧:១០]

ជាភាសាបារាំង ERN 00770239 ហើយជាភាសាខ្មែរ 00768553 ហើយគឺមានឯកសារលេខ E131/1/12 ផងដែរ នៅកថខណ្ឌ៥។ មេធាវីការពារក្ដី ខៀវ សំផន បានចាត់ទុកលោក ប៉ែន យៀវនិន ជាជនដែលជាប់ពាក់ព័ន្ធទៅក្នុងការទទួលឯកសារដោយ ឌី.ស៊ី.ខេម ហើយបានប្រកាសនៅក្នុងសវនាការថា ចាំបាច់បំផុតត្រូវតែកោះហៅបុគ្គលបានចូលរួមនៅក្នុងការទទួលឯកសារទាំងអស់នេះ ហើយត្រូវតែឲ្យពួកគាត់មកធ្វើសក្ខីកម្ម គឺសូមមើលប្រតិចារឹកថ្ងៃទី១៦ មករា ឆ្នាំ២០១២ ទំព័រ១២៣ ជាភាសាអង់គ្លេស។ ១២៣ជាភាសាបារាំង ហើយនិងជាភាសាខ្មែរ 00768614។ យើងគិតថា មិនមែនតែសហព្រះរាជអាជ្ញាទេ ដែលបានស្នើសុំឲ្យអ្នកជំនាញនេះមកផ្ដល់សក្ខីកម្មនោះ។

ចំណុចបន្ទាប់នេះ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍ៗ ដែលអនុញ្ញាតឲ្យមានការសួរជនជាប់--(សូមទោស)សួរអ្នកជំនាញដោយផ្ទាល់ ហើយនិងបំពេញទៅនឹងលក្ខខណ្ឌនៃវិធាន២៦(១)។

[១៣:៤៨:៤៤]

ប្រព័ន្ធសោតទស្សន៍នោះនឹងអនុញ្ញាតឲ្យតុលាការ និងភាគីចោទសួរសំណួរដែលខ្លួនចង់ទៅកាន់អ្នកជំនាញ ហើយនិងទទួលបាននូវសក្ខីកម្មជាលក្ខណៈផ្ទាល់។ ដូចសហសេវិករបស់ខ្ញុំបានបញ្ជាក់ ហើយនេះមិនមែនជាការអនុវត្តចម្លែកនៅក្នុងតុលាការមិនអចិន្ត្រៃយ៍នោះទេ គឺតុលាការមានកាតព្វកិច្ចរួមគ្នាពាក់ព័ន្ធទៅនឹងការសួរសំណួរសាក្សីក្នុងពេលដំណាលគ្នា។

យើងខ្ញុំទទួលស្គាល់ថា កាលពី២០ឆ្នាំមុននោះ ការរៀបចំប្រព័ន្ធសោតទស្សន៍បែបនេះ គឺថាចោទជាបញ្ហាប្រឈមមួយចំនួនខាងផ្នែកបច្ចេកទេស និងផ្នែកភស្តុភារ ក៏ប៉ុន្តែបញ្ហានេះគឺបានថយចុះហើយក្នុងរយៈពេលជាច្រើនឆ្នាំហើយ។ ឥឡូវនេះយើងមកដល់សករាជនៃបច្ចេកវិទ្យាព័ត៌មានហើយ ដូច្នេះការរៀបចំប្រព័ន្ធរបៀបនេះគឺមានលក្ខណៈជាធម្មតាទេ ហើយថែមទាំងមានគុណភាពនៃសំឡេងបានល្អ

ហើយមានរូបភាពភ្លឺច្បាស់ថែមទៀតផង។

[១៣:៤៩:៣៩]

មេធាវីការពារក្ដី អៀង សារី បានអះអាងថា ប្រភេទនៃការសក្ខីកម្មតាមប្រព័ន្ធវីដេអូ នេះមិនធ្វើទៅបានទេ ហើយនិងធ្វើឲ្យខាតបង់ពេលវេលាសវនាការទៀតផង គឺនៅក្នុងកថាខណ្ឌ៣០ នៃចម្លើយតបរបស់ខ្លួនចំពោះសេចក្ដីជូនដំណឹងរបស់យើង។

អង្គជំនុំជម្រះអាចនឹងពិគ្រោះយោបល់ជាមួយនឹងផ្នែកសោតទស្សន៍បាន ក៏ប៉ុន្ដែការបង្កើតប្រព័ន្ធបែបនេះនៅក្នុងទីក្រុងធំនៅប្រទេសអាមេរិកនោះ គឺថាមានលក្ខណៈងាយស្រួលណាស់ ហើយនិងមានបញ្ហាបច្ចេកទេសតិចតួចជាងការតភ្ជាប់ប្រព័ន្ធវីដេអូ ទៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា ដូចជានៅប៉ៃលិន ដូចជាក្នុងករណីការផ្ដល់សក្ខីកម្មដោយសាក្សី ឡុង នរិន្ទ ជាដើម។

[១៣:៥០:២៣]

នៅក្នុងសំណុំរឿង០០១ យើងបានឃើញថា ការតភ្ជាប់ប្រព័ន្ធវីដេអូជាមួយប្រទេសបារាំង ឬសហរដ្ឋអាមេរិកនេះ គឺមានគុណភាពល្អ ហើយអាចឲ្យយើងស្ដាប់ចម្លើយអ្នកជំនាញ ហើយនិងភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានភ្លាមៗដោយគ្មានការលំបាកអ្វីទាំងអស់។ ចំណុចបន្ដទៅទៀតនេះគឺថា ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ គឺថាមិនរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទ ឬក៏សិទ្ធិរបស់លោក អៀង សារី នោះទេ។ វិធាន២៦(១) ហាមឃាត់នូវការប្រើប្រាស់បច្ចេកវិទ្យានេះ ប្រសិនបើធ្វើឲ្យអន្ដរាយធ្ងន់ធ្ងរ ឬក៏មិនស្របទៅនឹងសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ។ យើងមើលឃើញថា សិទ្ធិតែមួយគត់ដែលប៉ះពាល់ដោយវិធាន ឬក៏បទប្បញ្ញត្តិនេះគឺថា ជនជាប់ចោទគាត់អាចតទល់ជាមួយនឹងសាក្សី ឬក៏អ្នកជំនាញ ហើយនិងអាចសួរ និងដេញដោលពួកគាត់បាន។ នៅក្នុង អ.វ.ត.ក សិទ្ធិនេះគឺត្រូវបានធានាដោយមាត្រា១៣ នៃកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ហើយនិងមាត្រា៣៨ថ្មី នៃច្បាប់ ស្ដីពី អ.វ.ត.ក។

[១៣:៥១:៣៣]

មេធាវីការពារក្ដី អៀង សារី បានលើកឡើងអំពីកថាខណ្ឌ២៥ នៅក្នុងចម្លើយតបរបស់ខ្លួន គឺថាការអនុញ្ញាតឲ្យអ្នកជំនាញផ្ដល់សក្ខីកម្ម តាមរយៈប្រព័ន្ធវីដេអូនេះ គឺថានឹងប៉ះពាល់ទៅដល់សិទ្ធិរបស់កូនក្ដីរបស់ខ្លួនក្នុងការតទល់ទៅនឹងអ្នកជំនាញ ប៊ែន ឃៀរនិន ហើយយោងទៅតាមសេចក្ដីសម្រេចដែលបានចេញដោយតុលាការអាមេរិក នៅឆ្នាំ១៩៩២ ពួកគេបានអះអាងថា "បច្ចេកវិទ្យាសោតទស្សន៍

មិនអាចជំនួសការសួរដេញដោលដោយផ្ទាល់បាននោះទេ។ ការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ពុំអនុញ្ញាតឲ្យអង្គជំនុំជម្រះ ឬភាគីមានឱកាសសង្កេត និងវាយតម្លៃអំពីភិនភាគ បុគ្គលិកលក្ខណៈ អត្តចរិត និងឥរិយាបថរបស់សាក្សី ឲ្យបានដូចជាការផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការផ្ទាល់នោះឡើយ"។ សូមបញ្ចប់ការដកស្រង់។

[១៣:៥២:២៤]

ខ្ញុំមានការកត់សម្គាល់ជាច្រើនដែលត្រូវលើកឡើង។ ទីមួយ គឺសេចក្តីសម្រេចដែលលើក-- ដែលដកស្រង់បានដោយមេធាវីការពារក្តី ដែលដកចេញមកពីយុត្តាធិការជាតិ នៅក្នុងបរិបទជាក់លាក់បំផុត គឺបរិបទសហរដ្ឋអាមេរិក។ ទីពីរ គឺសេចក្តីសម្រេចឆ្នាំ៩២ ហើយនិងបច្ចេកវិទ្យានៃការប្រើប្រាស់ប្រព័ន្ធវីដេអូ ដែលថានៅសម័យនោះ គឺមិនមានការលំបាកអីទេ។ ឥឡូវនេះ គុណភាពនៃរូបភាពមានការកែលម្អ ហើយដោយសារតែមានការកែលម្អរូបភាព និងសំឡេងនេះ យើងអាចមើលឃើញអ្នកជំនាញផ្តល់សក្ខីកម្ម យើងអាចមើលឃើញនូវទឹកមុខរបស់គាត់ កាយវិការរបស់គាត់ ហើយអ្នកជំនាញនោះ ក៏អាចមើលឃើញផងដែរនៅសាលសវនាការ មើលឃើញនៅភាគីផ្សេងៗ នៅក្នុងលក្ខខណ្ឌល្អប្រសើរ។

[១៣:៥៣:២១]

យើងក៏អាចមើលឃើញថា អ្នកជំនាញគាត់មើលកំណត់ត្រារបស់គាត់ ហើយនៅក្នុងករណីនោះ យើងអាចស្នើសុំឲ្យគាត់ផ្តល់នូវកំណត់ត្រារបស់គាត់បាន។ ហើយចំណុចទីបី ទោះបីជាច្បាប់អាមេរិកាំងដែលហាក់ដូចជាអនុគ្រោះដល់ការតទល់ជាមួយសាក្សី ដោយផ្ទាល់ដែលមានវត្តមានជនជាប់ចោទផ្ទាល់ក៏ដោយ ក៏យើងយល់ឃើញថា នេះមិនមែនជាជំហររបស់អង្គជំនុំជម្រះនោះដែរ។ ហើយក៏នេះមិនមែនជាលក្ខខណ្ឌតម្រូវនៃវិធាននីតិវិធី នៃនីតិអន្តរជាតិនោះដែរ។

លោក លោកស្រីបាននឹកឃើញហើយថា អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមានការប្រើប្រាស់វីដេអូនេះ នៅក្នុងរយៈជាច្រើនលើកច្រើនសានៅអំឡុងសំណុំរឿង០០១ ជាពិសេសគឺការស្តាប់សក្ខីកម្មសាក្សីដែលមានលំនៅដ្ឋាននៅប្រទេសបារាំង ឬក៏នៅសហរដ្ឋអាមេរិក ដូចជាអ្នកជំនាញ វីឆាត ហ្គោលស្តូន និង ស្តេហ្វិន ហាស្ទែល ហើយក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ សាវរិត ជាដើម។

[១៣:៥៤:១៣]

ដូច្នេះ យើងមើលឃើញអំពីកាតព្វកិច្ចវិជ្ជាជីវៈ ហើយនិងភាពទំនេររបស់ពួកគាត់ទាំងអស់គ្នា។ ការធ្វើតាមវីដេអូនេះ គឺថាមានលក្ខណៈល្អប្រសើរ ហើយក៏មិនមានការពន្យារពេលដែរ នៅក្នុងសំណុំ

រឿង០០១នោះ។ ហើយយើងឃើញថា អង្គជំនុំជម្រះបានបដិសេធនូវសំណើរបស់មេធាវីការពារក្តី ដែលឲ្យទៅសហរដ្ឋអាមេរិក ឬនៅបារាំង ដើម្បីនៅជិតនឹងពួកគេនោះ ដើម្បីនឹងពិនិត្យមើលពួកគេនៅពេលដែលពួកគេធ្វើសក្ខីកម្មតាមរយៈវីដេអូ។ យើងអាចឃើញសេចក្តីសម្រេចនេះ នៅក្នុងប្រតិចារឹកនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ នៅទំព័រទី៧ ជាភាសាអង់គ្លេស ហើយជាភាសាបារាំង ERN 00345776។ ជាភាសាខ្មែរ 00347835 ទៅដល់លេខ ERN36។ ហើយនៅក្នុងសវនាការនោះ គឺយើងបានស្តាប់សក្ខីកម្ម ឡុង នរិន្ទ តាមរយៈប្រព័ន្ធសោតទស្សន៍នោះ។ ទោះបីជាមានការតភ្ជាប់នោះ មិនល្អប្រសើរបំផុតនោះក៏ដោយ ក៏ប៉ុន្តែផ្ទុយពីអ្វីដែលលោក អៀង សារី បានលើកឡើង គឺថាដោយសារតែសុខភាពរបស់គាត់នោះទេ ឬក៏ភាពអល់អែកស្ទាក់ស្ទើររបស់គាត់ក្នុងការសក្ខីកម្មនោះទេ ដែលបានធ្វើឲ្យមានការពន្យារពេលដល់សវនាការនោះ។ នៅក្នុងករណីការតភ្ជាប់ដោយប្រព័ន្ធវីដេអូនេះ គឺថាតាមពិតទៅគឺមិនមានព្យសនកម្មនោះទេ គឺវាមាន-- តាមពិតទៅ គឺវាមានជាលក្ខណៈអផាសុខភាពសម្រាប់ភាគីហើយនិងសម្រាប់អ្នកជំនាញទៅវិញទេ។ ជាពិសេស គឺជាបុគ្គលដែលចូលរួមនៅក្នុងសវនាការ។ ហើយភាគីការពារក្តី ហើយនិងភាគីផ្សេងទៀតនោះ គឺថាមានសមភាពស្មើគ្នាដាច់ខាត។

[១៣:៥៦:០៨]

យើងពិនិត្យមើលទៅលើយុត្តិសាស្ត្រតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី និងតុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលបានបញ្ជាក់ថា ការប្រើប្រាស់បច្ចេកវិទ្យាវីដេអូនេះ សម្រាប់ការស្តាប់សក្ខីកម្មសាក្សីនោះ គឺជានីតិវិធីស្របច្បាប់ទាំងស្រុង ហើយនិងមិនរំលោភទៅនឹងសិទ្ធិរបស់ជនជាប់ចោទនោះទេ។

ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការយូហ្គោស្លាវីបានសម្រេចទៅលើលទ្ធភាពនៅក្នុងការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ដោយគោរពទៅនឹងសិទ្ធិរបស់-- សិទ្ធិការពារខ្លួន ហើយខ្ញុំសូមដកស្រង់៖ “ប្រព័ន្ធសោតទស្សន៍នោះ គ្រាន់ជាការពន្លាតការយុត្តាធិការរបស់សាលាដំបូងទៅដល់កន្លែងដែលសាក្សីរស់នៅប៉ុណ្ណោះ។ ដូច្នេះ មធ្យោបាយនេះមិនបានដកហូតនូវសិទ្ធិរបស់ជនជាប់ចោទ ក្នុងការតទល់ជាមួយនឹងសាក្សីនោះទេ ហើយនិងមិនធ្វើឲ្យការបាត់បង់នូវខ្លឹមសារសំខាន់ដោយសារតែអវត្តមានរបស់ជននោះទេ”។

ជាចុងក្រោយ យើងមិនអាចគាំទ្រថា ការផ្តល់សក្ខីកម្មតាមវីដេអូប៉ះពាល់ទៅដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការតទល់នឹងសាក្សីនោះទេ។ មាត្រា២១(៤)(ង) មិនត្រូវបានរំលោភនោះទេ។ នេះគឺជា

សេចក្ដីសម្រេចនៅក្នុងសំណុំរឿង ឌីឡាលិក ដែលមានលេខ ET-96-21 ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ៩៧ នៃកថាខណ្ឌ១៥។ ហើយកថាខណ្ឌមួយទៀត នៅក្នុងរឿងក្ដីមួយផ្សេងទៀត ខ្ញុំសូមដកស្រង់៖ "ប្រព័ន្ធវីដេអូ គឺស្របទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោល ហើយនិងតទល់គ្នាជាមួយនឹងសាក្សីដាក់បន្ទុក ដោយពិនិត្យទៅមើលឥរិយាបថរបស់គាត់ ហើយនិងអនុញ្ញាតឲ្យអង្គជំនុំជម្រះវាយតម្លៃទៅលើជឿជាក់ និងភាពអាចទុកចិត្តបាននៃសក្ខីកម្ម ដូចគ្នាចំពោះសាក្សីធ្វើសក្ខីកម្មនៅក្នុងសាលសវនាការដូចគ្នានោះដែរ"។ នេះជារឿងក្ដីរវាងសហព្រះរាជអាជ្ញា និងហ្កោតូវីណា ដែលមានសំណុំរឿង ET-06-90T ចុះថ្ងៃទី២៦ ខែកុម្ភៈ ២០០៩ នៅកថាខណ្ឌ១៨។

[១៣:៥៨:១១]

ដូច្នេះ មេធាវីការពារក្ដីមិនអាចធ្វើពុតជាមិនដឹងមិនឮ អំពីយុត្តិសាស្ត្រនេះឡើយ។ ហើយនៅក្នុងសេចក្ដីសម្រេចទាំងអស់នេះ អស់លោកកំណត់សម្គាល់ឃើញថា នេះទាំងអស់នេះគឺជាសាក្សីរបស់សហព្រះរាជអាជ្ញាដែលត្រូវអនុញ្ញាតឲ្យស្ដាប់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។ ដូច្នេះ មិនមែនជានៅទីនេះមិនមែនជាអ្នកជំនាញនោះទេ។ ហើយយើងស្ថិតនៅក្នុងបរិបទមួយផ្សេងទៀត វាមិនមែនជាសាក្សី-- វាមិនមែនជាអ្នកជំនាញរបស់សហព្រះរាជអាជ្ញាទេ គឺជាអ្នកជំនាញរបស់អង្គជំនុំជម្រះ។

ដូច្នេះ ទឡ្ហីករណ៍របស់មេធាវីការពារក្ដី អៀង សារី ដែលថាការផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ នឹងប៉ះពាល់ទៅដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោល ឬក៏តទល់ជាមួយនឹងអ្នកជំនាញនោះ គ្មានមូលដ្ឋានច្បាប់ទាល់តែសោះ មិនមានអន្តរាយ ហើយក៏មិនមានព្យសនកម្មធ្ងន់ធ្ងរ ឬក៏ភាពមិនស្រប ដូចដែលខាងមេធាវីការពារក្ដីបានលើកឡើងដែរ ហើយក៏មានការកែតម្រូវដោយវិធាន ២៦(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ផងដែរ។ ហើយការលើកឡើងនេះ គឺថាដើម្បីតែបដិសេធចោលនូវប្រើប្រាស់ប្រព័ន្ធសោតទស្សន៍តែប៉ុណ្ណោះ។

[១៣:៥៩:២៦]

តុលាការសិទ្ធិមនុស្សអឺរ៉ុបបានប្រកាន់យកសំអាងហេតុដូចគ្នានោះ ពាក់ព័ន្ធទៅនឹងការរំលោភដោយសន្មតទៅលើសិទ្ធិក្នុងការសួរដេញដោលសាក្សី ដែលសិទ្ធិនេះត្រូវបានធានាដោយមាត្រា៦(៣)(ឃ) នៃអនុសញ្ញាសិទ្ធិស្ដី-- នៃអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស។ ខ្ញុំសូមដកស្រង់៖ "ទោះបីជាតុលាការបានវិនិច្ឆ័យថា ជាគោលការណ៍ធាតុផ្សំត្រូវតែដាក់ដោយចំពោះមុខអវត្តមានជនជាប់ចោទ។ សិទ្ធិក្នុងការសួរដេញដោលសាក្សី មិនត្រូវបានបកស្រាយថាជាការធានាទៅដល់ជនជាប់ចោទឲ្យមានវត្តមាននៅក្នុង

កន្លែងតែមួយជាមួយនឹងសាក្សីនោះដែរ”។ យោងតាមអនុសញ្ញានេះ សារៈសំខាន់គឺថាជនជាប់ចោទគាត់ទទួលបាននូវលទ្ធភាពសមស្រប និងគ្រប់គ្រាន់ក្នុងការជំទាស់តវ៉ាទៅនឹងសក្ខីកម្មដាក់បន្ទុក ហើយនិងសួរអ្នកនិពន្ធដើម្បីដេញដោល។

តុលាការបានទទួលស្គាល់យ៉ាងច្បាស់ថា សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍មិនផ្ទុយទៅនឹងមាត្រា៦នោះទេ។ ការអះអាងថា ការបង្ហាញខ្លួនតាមរយៈប្រព័ន្ធសោតទស្សន៍ និងរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោលសាក្សី ឬក៏សិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមាននៅក្នុងសវនាការនោះ គឺជាការបកស្រាយច្បាប់ដោយភ័ន្តច្រឡំ។

[១៤:០០:៥៥]

ជនជាប់ចោទ និងមេធាវីរបស់ខ្លួនមិនមានលទ្ធភាពគ្រប់គ្រាន់ និងសមស្របក្នុងការជំទាស់ទៅនឹងសក្ខីកម្ម ហើយនិងការសួរអ្នកជំនាញ ប៉ែន យៀរនិន ស្របទៅតាមសិទ្ធិរបស់ខ្លួន។ បច្ចេកវិទ្យាប្រព័ន្ធសោតទស្សន៍នោះអនុញ្ញាតឱ្យមានការប្រឈមមុខគ្នារវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួនរបស់ខ្លួនហើយនិងអ្នកជំនាញ បើទោះបីជាអ្នកជំនាញការមិនស្ថិតនៅក្នុងបន្ទប់តែមួយជាមួយនឹងជនជាប់ចោទក៏ដោយ។

ចំណុចព្រួយបារម្ភចុងក្រោយដែលលើកឡើងដោយមេធាវីការពារក្តី អៀង សារី នៅក្នុងសំណើរបស់ខ្លួននៅក្នុងកថាខណ្ឌ២៩ នោះ គឺថាសក្ខីកម្មតាមរយៈប្រព័ន្ធវីដេអូពីតតិយរដ្ឋមួយនោះ គឺហួសពីយុត្តាធិការលើដែនដីរបស់អង្គជំនុំជម្រះ។ ដូចដែលយើងបានបញ្ជាក់រួចមកហើយ សក្ខីកម្មតាមរយៈប្រព័ន្ធវីដេអូត្រូវបានធ្វើតាំងពីប្រទេសអាមេរិក ហើយនិងប្រទេសបារាំងនៅក្នុងសំណុំរឿង០០១។ ដូច្នេះអង្គភាពគាំពារជនរងគ្រោះ-- អង្គភាពគាំពារសាក្សីនិងអ្នកជំនាញនោះ គឺបានស្នើសុំឱ្យប្រទេស ឬក៏រដ្ឋពាក់ព័ន្ធ ហើយបានសួរថាតើសំណើសុំជំនួយខាងផ្លូវច្បាប់នេះមានភាពចាំបាច់នោះដែរឬទេ? ដូចនៅក្នុងសំណុំរឿងនេះ យើងខ្ញុំគិតទុកជាមុនថានឹងមិនមានបញ្ហាលំបាកអ្វីទេពីសំណាក់អាជ្ញាធររដ្ឋអាមេរិកនោះ ហើយយើងក៏ជឿជាក់ទៅលើសមត្ថភាពរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងអង្គជំនុំជម្រះក្នុងការធានាឱ្យមានការរៀបចំប្រព័ន្ធវីដេអូនេះពីសហរដ្ឋអាមេរិកមក ដើម្បីឱ្យមាន ត្រូវបានរៀបចំឡើងបានល្អ ហើយមាននីតិវិធីបែបបទអាចទទួលយកបាន និងមានតម្លាភាពសម្រាប់ភាគីទាំងអស់ ជាពិសេសគឺមានរួមទាំងការស្បថ ហើយនិងទីកន្លែងដែលប្រព្រឹត្តទៅនៃការផ្សាយវីដេអូនោះ។

[១៤:០២:៤៧]

ជាចុងក្រោយ យើងកត់សម្គាល់ឃើញថា ទោះបីជា ប៉ែន យៀរនិន មិនមាន មិនអាចមានភាពទំនេរក្នុងការធ្វើដំណើរដោយផ្ទាល់មកធ្វើ-- មកផ្តល់សក្ខីកម្មក៏ដោយ ក៏ប៉ុន្តែគឺច្បាប់ជាធរមានអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាមូលហេតុដែលផ្តល់ជូនដោយអ្នកជំនាញនោះមានលក្ខណៈគ្រប់គ្រាន់ គឺអាចអនុញ្ញាតឲ្យប្រើប្រាស់ប្រព័ន្ធវីដេអូបានសម្រាប់ស្តាប់សក្ខីកម្មរបស់គាត់។

ដោយសារតែពេលវេលាកាន់តែខិតជិតទៅហើយ ខ្ញុំសូមសំណើឲ្យអង្គជំនុំជម្រះ ប្រសិនបើអង្គជំនុំជម្រះចង់ស្តាប់សក្ខីកម្មរបស់គាត់នៅដើមខែមេសានេះ គឺថាសូមមេត្តាចេញសេចក្តីសម្រេចឲ្យបានលឿន ដើម្បីឲ្យភាគី និងអ្នកជំនាញត្រៀមខ្លួន ហើយនិងរៀបចំខ្លួនឲ្យបានល្អទៅតាមនោះ។

អង្គជំនុំជម្រះអាចស្នើសុំឲ្យភាគីផ្តល់នូវបញ្ជីនៃប្រធានបទដែលខ្លួនចង់សួរទៅកាន់អ្នកជំនាញ ហើយនិងផ្តល់ជូនប្រធានបទទាំងអស់នេះទៅដល់អ្នកជំនាញ ហើយនិងទៅដល់ភាគីទាំងអស់ ទោះបីជាក្នុងលក្ខណៈបណ្តោះអាសន្នសិនក៏ដោយ យ៉ាងហោចណាស់ គឺផ្ញើនូវបញ្ជីនៃឯកសារសំខាន់ៗដែលខ្លួនចង់ពិភាក្សានៅពេលធ្វើសក្ខីកម្មរបស់អ្នកជំនាញនេះ។ ហើយអ្នកជំនាញនេះ បានសរសេរឯកសារជាច្រើន។ ដូច្នេះការត្រៀមខ្លួនជាមុននោះ គឺជាការល្អប្រសើរណាស់ដើម្បីឲ្យគាត់ដឹងថា តើប្រធានបទអីខ្លះដែលត្រូវផ្តល់ពិភាក្សានៅក្នុងអង្គសវនាការនោះ។

[១៤:០៤:១៨]

ជាចុងក្រោយ យើងក៏ចង់ស្នើផងដែរថា ចាប់ពីពេលដែលមានចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមក គឺមានបញ្ជាក់ថាតើពេលណាដែលការិយាល័យសហព្រះរាជអាជ្ញាបានរួចផុតពីភារកិច្ចដែលបានប្រគល់ជូនខ្លួននោះក្នុងការទាក់ទងអ្នកជំនាញ។

ក្នុងរយៈពេលខ្លីទេ ខ្ញុំនឹងចង់និយាយអំពីចម្លើយរបស់យើងខ្ញុំទៅនឹងសំណើរបស់ភាពគីបដិបក្ខពាក់ព័ន្ធទៅនឹងឯកសារដែលនឹងត្រូវផ្តល់ជូនដោយអ្នកជំនាញ។ យើងគិតថា យើងបានបញ្ជាក់ជូនយ៉ាងពេញលេញទៅហើយ នៅក្នុងអនុស្សរណៈលេខ E172/3 ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ ពាក់ព័ន្ធទៅនឹងចម្លើយដែលត្រូវផ្តល់ជូនទៅនឹងការ-- ទៅនឹងសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលមាន ដែលចង់ឲ្យមានការផ្តល់ឯកសារដោយសាស្ត្រាចារ្យ ប៉ែន យៀរនិន។ ជាក់ស្តែងគឺថាខាងភាគីនេះបានស្នើសុំឯកសារនេះច្រើនណាស់មុននឹងគាត់មកធ្វើសក្ខីកម្មនោះ។ ហើយក្នុងចំណោមឯកសារទាំងអស់នោះមានឯកសារបោះពុម្ពផ្សាយ១០ ហើយបើតាមមេធាវីការពារក្តី ឯកសារសរសេរដោយ

សាស្ត្រាចារ្យ ប៉ែន ឃៀរនិន ទាំងអស់ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ ត្រូវតែផ្ដល់ជូន។ ហើយឯកសារទាំងអស់នេះមិនទាន់បានផ្ញើមកទេ រួមទាំងកំណត់សម្គាល់សរសេរដៃ ឬក៏ឯកសារខ្សែអាត់សំឡេងជាដើម។

[១៤:០៥:៤៤]

ទោះជាយ៉ាងក៏ដោយ ខ្ញុំ យើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះបដិសេធចោលនូវសំណើនេះ ពីព្រោះថាមិនមានសំអាងហេតុគ្រប់គ្រាន់នោះទេ ហើយសំណើនេះមានលក្ខណៈហួសហេតុ មិនមានភាពច្បាស់លាស់ ហើយយុត្តិសាស្ត្រអន្តរជាតិនោះ ក៏មិនបានគាំទ្រទៅដល់សំណើតាមរបៀបនេះដែរ។ ខាងមេធាវីការពារក្ដីមិនបានពន្យល់ថា ហេតុអីបានជាឯកសារដែលគាត់ចង់បាននោះមានភាពពាក់ព័ន្ធនោះទេ? តើហេតុអីជាមានភាពចាំបាច់ចំពោះជនជាប់ចោទ ហើយមិនបានបញ្ជាក់ទេ ហេតុអីបានថាអ្នកជំនាញបានសរសេរសៀវភៅជាច្រើនអំពីរបបខ្មែរក្រហម។ ហើយគាត់ទាមទារនូវឯកសារទាំងអស់នេះហើយព្រមទាំងទាមទារនូវកំណត់សម្គាលសរសេរដៃទៅទៀត។

[១៤:០៦:៣៥]

យុត្តិសាស្ត្រតុលាការអន្តរជាតិនោះ គឺថាមិនបានគាំទ្រទៅលើការស្នើសុំបែបនោះទេ។ ដូច្នេះអ្នកជំនាញមិនចាំបាច់ដែលត្រូវធ្វើការសិក្សាទៅលើជនជាប់ចោទ ហើយផ្ដល់អ្វីទាំងអស់នោះទៅឲ្យជនជាប់-- ទៅឲ្យអង្គជំនុំជម្រះនោះទេ។ ក្នុងករណីរបស់លោក ប៉ែន ឃៀរនិន គឺជារឿងផ្សេងមួយទៀត។ ប្រសិនបើជាអ្នកជំនាញរបស់តុលាការនោះ គឺអង្គ-- ខាងមេធាវីការពារក្ដីអាចលើកសំអាងថា ទាមទារឯកសារពីគាត់បាន។ គឺទាមទារឲ្យ ប៉ែន ឃៀរនិន ធ្វើរបាយការណ៍ឲ្យជូនគាត់បាន។ ក៏ប៉ុន្តែនៅទីនេះលោក ប៉ែន ឃៀរនិន ក្នុងករណីនេះ គឺគាត់ជាអ្នកត្រូវបានគេដឹងថាគាត់ជាអ្នកជំនាញ ពីព្រោះគាត់សរសេរសៀវភៅជាច្រើន អត្ថបទជាច្រើនអំពីប្រទេសកម្ពុជា។

[១៤:០៧:២៩]

ដូច្នេះ គាត់មិនទទួលបន្ទុកអំពីតុលាការដើម្បីសរសេររបាយការណ៍ថ្មីនោះទេ។ ដូច្នេះ មិនមានសេចក្ដីសម្រេចណាមួយដែលតម្រូវឲ្យបុគ្គលបែបនេះក្នុងការផ្ដល់នូវឯកសារទាំងអស់របស់ខ្លួន ឬក៏កំណត់សម្គាល់សរសេរដោយដៃរបស់ខ្លួន ឬក៏ឯកសារសម្ភាសទាំងអស់របស់ខ្លួន ឬក៏អ្វីដែលខ្លួនបានបោះពុម្ពផ្សាយក្នុងក្របខ័ណ្ឌសាកលវិទ្យាល័យដែលត្រូវបានធ្វើឡើងមុនពេលដែលគាត់បានមកផ្ដល់សក្ខីកម្មនោះទេ។

នេះគឺជាបញ្ហាពាក់ព័ន្ធទៅនឹងខាងផ្នែកសម្ភារៈ និងផ្នែកភស្តុភារ ហើយយើងក៏មិនដឹងដែរថា តើសាក្សីអ្នកជំនាញរូបនេះគាត់នៅតែរក្សាទុកឯកសារទាំងអស់ ដែលគាត់បានសរសេរពីមុនមក ហើយគាត់មានលទ្ធភាពអាចផ្តល់ជូនអង្គជំនុំជម្រះនោះទេ។ ហើយមេធាវីការពារក្តីបានដឹងតាំងពីខែតុលា ឆ្នាំ ២០១១ មកម្ល៉េះ គឺបើតាមអនុស្សរណៈមួយនោះ គឺថា អង្គជំនុំជម្រះចង់ស្តាប់សក្ខីកម្មរបស់អ្នកជំនាញរូបនេះ។ ហើយទើបតែពេលនេះ មេធាវីការពារក្តីទាមទារលិខិតពីអង្គជំនុំជម្រះឲ្យបានឆាប់បំផុត។ ហើយឲ្យគេឆ្លើយតបឲ្យបានជាបន្ទាប់ទៅនឹងសំណើរបស់ខ្លួន។

[១៤:០៨:៣៨]

ដូច្នេះ សំណើនេះត្រូវបានធ្វើឡើងក្នុងរយៈពេលខ្លីណាស់ មុនពេលដែលនឹងអ្នកជំនាញមកធ្វើសក្ខីកម្មនោះ។ ការតម្រូវទាមទារឲ្យមានការផ្តល់ឯកសារទាំងអស់របស់ ប៉ែន យៀរនិន តាំងពី៤០ឆ្នាំនោះ វាមិនត្រឹមត្រូវនោះទេ ហើយវាក៏មិនសមហេតុផលនោះដែរ។ ហើយគួរឲ្យភ្ញាក់ផ្អើលណាស់ថា យើងមានឯកសារច្រើនណាស់នៅក្នុងសំណុំរឿងមេធាវីការពារក្តីបានលើកឡើងដូច្នេះ ប៉ុន្តែគាត់ទាមទារឲ្យមានឯកសារច្រើនលើសពីហ្នឹងទៅទៀតដាក់នៅក្នុងសំណុំរឿង។ ដូច្នេះ មេធាវីការពារក្តីមិនបានបញ្ជាក់ឲ្យច្បាស់លាស់ទេនៅក្នុងសំណើរបស់ខ្លួន ថាតើមានប្រធានបទអីខ្លះដែលខ្លួនចាប់អារម្មណ៍ចំពោះឯកសាររបស់លោក ប៉ែន យៀរនិន នោះ ហើយមិនដឹងថាធ្វើ មិនដឹងថាប្រធានបទណាមួយដែលត្រូវតម្រូវឲ្យលោក ប៉ែន យៀរនិន ធ្វើការស្រាវជ្រាវឯកសាររបស់គាត់នោះ។

ដូច្នេះ សូមឲ្យអង្គជំនុំជម្រះបដិសេធចោលនូវសំណើរបស់មេធាវីការពារក្តី ពីព្រោះថាមិនមានសំអាងហេតុគ្រប់គ្រាន់នោះទេ។ ដូច្នេះ អ្វីដែលបានលើកឡើងដោយមេធាវីការពារក្តីនោះ គឺថាមិនអាចទទួលយកបាននោះទេ។

ខ្ញុំសូមអរគុណគុណលោកប្រធាន លោក លោកស្រីចៅក្រមចំពោះការចាប់អារម្មណ៍នូវការឡើងថ្លែងរបស់ខ្ញុំនេះ ហើយខ្ញុំសូមផ្តល់វេទិកានេះជូនសហមេធាវីនាំមុខ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តសូមផ្តល់វេទិកាទៅសហមេធាវីនាំមុខ ឥឡូវហ្នឹងសហព្រះរាជអាជ្ញាបានផ្តួបនូវបញ្ហាទាំងពីរហើយ ដូច្នេះសហមេធាវីនាំមុខគប្បីធ្វើដូចគ្នាតែម្តង ដើម្បីឲ្យបញ្ហានេះឆាប់ចប់។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមជាទីគោរព!

ខ្ញុំគ្រាន់តែលើកការកត់សម្គាល់ខ្លីៗនោះទេ ហើយប្រើពេលមិនអស់នោះទេលើបញ្ហាពីរដែលខ្ញុំនិយាយជាបន្តបន្ទាប់ទាក់ទងទៅនឹងអ្នកជំនាញដែលៗលោកសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញនេះនោះគឺថាគាត់មិនមែនជាអ្នកជំនាញរបស់សហព្រះរាជអាជ្ញាទេ ក៏ប៉ុន្តែជាអ្នកជំនាញរបស់អង្គជំនុំជម្រះ។

[១៤:១១:០០]

ការកត់ទីមួយរបស់ខ្ញុំ គឺជាការកត់សម្គាល់ទាក់ទងនឹងការប្រើពាក្យពេចន៍ ទាក់ទងនឹងវិធាន ២៦(១)។ វិធាននេះមិនបានលើកឡើងថា ការស្តាប់សក្ខីកម្មរបស់អ្នកជំនាញនៅសវនាការត្រូវតែធ្វើថាដោយវត្តមានផ្ទាល់នោះទេ បើសិនជាមានលទ្ធភាពធ្វើយ៉ាងដូច្នេះ គឺយើងត្រូវអញ្ជើញគាត់មកផ្ទាល់បើមិនដូច្នេះទេ តាមរយៈសោតទស្សន៍ ហើយនេះជាភាសាបារាំង ភាសាអង់គ្លេសក៏ដូចគ្នាដែរ។ ហើយវិធាន២៦(១) បានលើកឡើងថាសក្ខីកម្មរបស់សាក្សី ឬក៏អ្នកជំនាញនៅក្នុងអំឡុងពេលស៊ើបសួរ ឬក៏ក្នុងជំនុំជម្រះដោយធ្វើឡើងដោយមានវត្តមានបុគ្គលនេះផ្ទាល់នៅពេលណាដែលអាចធ្វើទៅបាន។

ហើយនេះជាវិធានច្បាប់ដែលមានលក្ខណៈច្បាស់លាស់ នេះគឺជាការចង់និយាយថាមានលក្ខខណ្ឌតម្រូវដ៏តឹងរ៉ឹង ដែលក្នុងការស្តាប់បុគ្គលនេះ អ្នកជំនាញនេះ តាម-- ដែលថាត្រូវស្តាប់គាត់ដោយផ្ទាល់នោះទេ។ ខ្ញុំគិតថា វិធាននេះគឺហាក់ដូចជាផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះធ្វើការវាយតម្លៃទៅលើស្ថានភាពគឺថាក្នុងការស្តាប់ចម្លើយរបស់អ្នកជំនាញដោយផ្ទាល់។

[១៤:១២:៣៣]

ការកត់សម្គាល់ទីពីររបស់ខ្ញុំគឺថា វាហាក់ដូចជាមានការចាំបាច់ក្នុងការស្តាប់បុគ្គលនេះទៅធ្វើការ -- មានការចាំបាច់ក្នុងការបែងចែករវាងពាក្យហៅថា “សាក្សី” ហើយនិង “អ្នកជំនាញ”។ អ្នកជំនាញមិនមែនជាសាក្សីទេ គឺថាគាត់ជាអ្នកទ្រឹស្តី មានអាជីពក្នុងការពិនិត្យប្រធានបទមួយចំនួនជាក់លាក់មួយចំនួនដូចជា មុខរបបគាត់ជាអ្នកជ្រើសរើសនោះ គឺថាទៅធ្វើឲ្យគាត់មានការពិចារណាច្បាស់លាស់លើប្រធានបទដែលគាត់សិក្សា ហើយនិងមានសមត្ថភាពវិភាគ។ ដូច្នេះគឺជារឿងពីរដែលថា ស្របគ្នាជាមួយនឹងការធ្វើការសួរសំណួរគាត់តាមរយៈប្រព័ន្ធវីដេអូ ដូច្នេះគឺថាជាការដែលមិន-- ជាអ្វីដែលថាយើងមិនចាំបាច់តម្រូវដូចគ្នាទៅនឹងសាក្សីនោះទេ។ គឺថាវត្តមានសាក្សីវាសំខាន់ជាងនៅក្នុងបន្ទប់សវនាការយើងនេះ ពីព្រោះថាការចោទសំណួរទៅគាត់ វាមានការពាក់ព័ន្ធទៅនឹងអង្គហេតុ ហើយនិងមនោសញ្ចេតនាជាង ហើយវាខុសពីការចោទសំណួរទៅនឹងអ្នកជំនាញ ដែលថាមិនសូវមានលក្ខណៈមនោ-

សញ្ញានានោះទេ។

[១៤:១៣:៥៥]

អ្វីដែលខ្ញុំចង់លើកសម្គាល់នោះបន្តទៀតនោះគឺថា បន្ទាប់ពីអាចសារណាឯកសារជាច្រើនដែលភាគីការពារក្ដីរបស់លោក អៀង សារី បានលើកឡើងនោះ ខ្ញុំគ្រាន់តែថាអានច្បោះៗនោះទេមិនបានវិភាគឲ្យលម្អិតនោះទេ ក៏ប៉ុន្តែខ្ញុំយល់ឃើញហាក់ដូចជាមានបញ្ហាទាក់ទងនឹងការប្រើពាក្យ "សាក្សី" តែមិនមែនពាក្យថា "អ្នកជំនាញ" ទេ។ ហើយអ៊ីចឹង ខ្ញុំសូមឲ្យបែងចែកពាក្យទាំងពីរនេះថាសូមឲ្យអង្គជំនុំជម្រះធ្វើការវាយតម្លៃទៅលើវិធាន២៦(១) នេះឡើងវិញ។ ខ្ញុំចង់ធ្វើការបែងចែករវាងពាក្យ "សាក្សី" ហើយនិង "អ្នកជំនាញ"។

[១៤:១៤:៣៦]

យើងត្រូវតែ-- ក្នុងឋានៈជាអ្នកច្បាប់ យើងត្រូវតែបែងចែកឲ្យច្បាស់ពាក្យពីរនេះ នៅពេលដែលយើងនឹងនិយាយអំពីលទ្ធភាពនៅក្នុងការបង្ហាញខ្លួននៅទីនេះរបស់អ្នកជំនាញ ឬក៏របស់សាក្សី។ ខ្ញុំនិយាយម្ដងទៀត គឺថាវិធាន២៦(១) នេះមិនបានដាក់លក្ខខណ្ឌតម្រូវលើអលទ្ធភាពនៃការបង្ហាញខ្លួនអ្នកជំនាញនោះទេ។ លោកបាន ប៊ែន ឃៀរនិន បានឲ្យហេតុផលហើយថាគាត់មិនអាចមកប្រទេសកម្ពុជាបាននោះទេ។ ហើយខ្ញុំគិតថា ដោយសារមូលហេតុមុខអាជីពរបស់គាត់នេះ គឺថាយើងត្រូវតែចាត់ទុកថានេះជាមូលហេតុយកជាការបាន ហើយខ្ញុំមិនយល់ថា ហេតុអ្វីបានថា យើងមិនចាត់ទុកថានេះជាហេតុផលដែលមានលក្ខណៈហ្មត់ចត់នោះទេ។ ហើយទាក់ទងទៅនឹងលក្ខខណ្ឌដែលតម្រូវដោយវិធាន២៦(១) នេះ គឺថាការស្ដាប់តាមប្រព័ន្ធសោតទស្សន៍នោះ មិនអាចធ្វើបានទៀតទេ បើសិនជាប៉ះពាល់ទៅដល់សិទ្ធិការពារ ឬក៏វាមិនស្របទៅនឹងសិទ្ធិរបស់ភាគីការពារក្ដី។

[១៤:១៥:៥៩]

ក៏ប៉ុន្តែនេះជាការងាររបស់ភាគីការពារក្ដីដែលត្រូវបង្ហាញភស្តុតាង ថាមានប៉ះពាល់ធ្ងន់ធ្ងររបៀបណា ឬក៏មិនស្របទៅនឹងសិទ្ធិរបស់ខ្លួនរបៀបណា? អ៊ីចឹងប្រព័ន្ធវីដេអូនេះអាចអនុញ្ញាតឲ្យមានវត្តមានបុគ្គលណាម្នាក់ហើយក្នុងពេលដែលសួរចម្លើយគាត់ ឬក៏បង្កើតឲ្យមានការសួរដេញដោល។ ដូច្នេះភាគីការពារក្ដីត្រូវតែបង្ហាញមូលហេតុនៃការប៉ះពាល់ធ្ងន់ធ្ងរអន្តរាយដ៏ធ្ងន់ធ្ងរនេះ។ ក៏ប៉ុន្តែខ្ញុំមិនដែល-- មិនបានអាន មិនឃើញមាននៅក្នុងអនុស្សរណៈរបស់ក្រុម អៀង សារី នោះទេ។ ខ្ញុំសូមរំឭកផងដែរ ថាលោក ឡុង នរិន្ទ ពេលដែលគាត់បាន-- ត្រូវបានសួរចម្លើយនេះក៏ពុំមានអ្នកណាលើកឡើងអំពីបញ្ហា

អន្តរាយធ្ងន់ធ្ងរ ឬក៏ភាពមិនសមស្របទៅនឹងសិទ្ធិការពារខ្លួននោះដែរ។

[១៤:១៧:០១]

ក៏ប៉ុន្តែទាក់ទងទៅនឹងការស្តាប់ចម្លើយរបស់លោក ប៉ែន ឃៀរនិន ខ្ញុំសូមគាំទ្រ មតិយោបល់របស់សហព្រះរាជអាជ្ញា។ ខ្ញុំគិតថាជាការសំខាន់ក្នុងការស្តាប់គាត់តាមរយៈប្រព័ន្ធវីដេអូ ឬក៏ផ្ទាល់ខ្លួន។ គាត់ជាបុគ្គល អ្នកស្រាវជ្រាវដ៏សំខាន់ដែលបានពិចារណាលើករបបកម្ពុជា ហើយនិងស្រាវជ្រាវលើប្រទេសកម្ពុជា។ គឺជាអ្នកជំនាញដែលធ្វើការស្រាវជ្រាវជាច្រើននៅក្នុងរយៈពេលដ៏យូរឆ្នាំ ហើយនិងវិភាគរបបខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យយើងនេះ។ ហើយបានធ្វើការស្រាវជ្រាវជាក់លាក់លើក្រុមប្រជាជនជាក់លាក់ ហើយតាមរយៈការស្រាវជ្រាវលើក្រុមប្រជាជននេះ គឺគាត់បានពិចារណាជាពិសេសលើអ្វីដែលពាក់ព័ន្ធនឹងការពិចារណានៅក្នុងក្របខ័ណ្ឌជំនុំជម្រះវគ្គទីមួយយើងនេះ។ ភាគីការពារក្តីបានសង្កត់ធ្ងន់ទៅលើភាពចាំបាច់នៃការសួរលោក ប៉ែន ឃៀរនិន នេះ។

[១៤:១៨:១១]

លោក ប៉ែន ឃៀរនិន យើងមិនអាចជំនួសគាត់ដោយអ្នកជំនាញការផ្សេងណាផ្សេងទេ ដូច្នេះយើងត្រូវតែស្តាប់ចម្លើយគាត់។ នៅទីបញ្ចប់ទាក់ទងនឹងឯកសារដែលភាគីរបស់លោក អៀង សារី បានសុំនោះ ហើយដែលត្រូវថា ត្រូវតែនាំយកមកដើម្បីបន្ថែមទៅលើស្នាដៃរបស់លោក ប៉ែន ឃៀរនិន នោះខ្ញុំសូមធ្វើការកត់សម្គាល់មួយលើចំណុចនេះ។ ខ្ញុំមិនជឿថា អង្គជំនុំជម្រះមិនបង្ខំឲ្យគាត់ហ្នឹងបង្ហាញសៀវភៅរបស់គាត់នោះទេ ឬក៏ថាដាក់លក្ខខណ្ឌថា គាត់អាចមកបង្ហាញខ្លួនទាល់តែគាត់បង្ហាញស្នាដៃគាត់នោះទេ។ ដូច្នេះ ខ្ញុំសូមឲ្យគិតអំពីស្ថានភាពនេះផង ហើយខ្ញុំសូមបញ្ចប់ដោយធ្វើការកត់សម្គាល់សាមញ្ញមួយ។

ខ្ញុំមានការភ្ញាក់ផ្អើលនៅពេលដែលមេធាវីលោក អៀង សារី បានសុំឲ្យលោក ប៉ែន ឃៀរនិន សូមផ្តល់ព័ត៌មានថែមទាំងសៀវភៅសរសេរអក្សរដៃតាំងពីដប់ម្ភៃសាមសិបឆ្នាំមកហើយនោះ។ ហើយនេះម្យ៉ាង ហើយម្យ៉ាងទៀតខាងភាគីការពារក្តីមួយក្រុម ឬក៏ច្រើនក្រុមកាលពីថ្ងៃមុននេះ បានជំទាស់ឯកសារទាំងដប់របស់យើង។ គឺថាក្នុងនោះមានសៀវភៅពីរក្បាល ដែលថាមានលេខយោងច្បាស់លាស់របស់លោក ប៉ែន ឃៀរនិន ផ្ទាល់តែម្តង គឺថាដូចឆ្ងល់ដែរ ម្ខាងគឺថាចង់បានសៀវភៅរបស់អ្នកជំនាញនឹងដដែល ហើយម្ខាងទៀតថាសុំតាំងពីសៀវភៅសរសេរដៃដោយលោក ប៉ែន ឃៀរនិន ហ្នឹងដដែល។

អ៊ីចឹងខ្ញុំគិតថាហាក់ដូចជាគ្មានមូលដ្ឋានអីទេ រឿងការជំទាស់ទាំងអស់នេះ ហើយនិងការ

សំណួមពរទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្ទះម្ភៃនាទី ចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

*(សវនាការសម្រាកពីម៉ោង ១៤:២០ នាទី ដល់ម៉ោង ១៤:៤៨ នាទី)*

[១៤:៤៨:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសូមជម្រាបអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទៅលើការកែប្រែកាលវិភាគសម្រាប់ធ្វើសវនាការសម្រាប់សប្តាហ៍ក្រោយ។ ដោយក្រោយពីបានស្តាប់នូវសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា ហើយនិងស្តាប់នូវមតិយោបល់ពីក្រុមភាគីនៃរឿងក្តីដទៃទៀត អង្គជំនុំជម្រះបានពិភាក្សាគ្នាហើយសម្រេចកំណត់កាលវិភាគសម្រាប់ធ្វើសវនាការសម្រាប់សប្តាហ៍ក្រោយដូចខាងក្រោមនេះ៖

នៅព្រឹកថ្ងៃចន្ទ សួរជនជាប់ចោទ នួន ជា។ នៅរសៀល អង្គជំនុំជម្រះនឹងមិនធ្វើសវនាការទេ។

ថ្ងៃអង្គារ ស្តាប់សក្ខីកម្មសាក្សី ឌុច ពេញមួយថ្ងៃ ទាំងព្រឹក ទាំងល្ងាច។

ព្រឹកថ្ងៃពុធ សួរជនជាប់ចោទ នួន ជា។ នៅរសៀលមិនធ្វើសវនាការទេ។

នៅថ្ងៃព្រហស្បតិ៍ សួរ-- ស្តាប់សក្ខីកម្មរបស់សាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ពេញមួយថ្ងៃទាំងព្រឹកទាំងល្ងាច។

[១៤:៥០:០៧]

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនផងដែរ ថាកាលវិភាគសវនាការនេះ មានលក្ខណៈបត់បែនហើយសម្រាប់តែកិច្ចដំណើរការសវនាការសម្រាប់សប្តាហ៍ក្រោយប៉ុណ្ណោះ មិនមែនជាការសម្រាប់អនុវត្តនៅពេលខាងមុខទៀតទេ។ ហើយបញ្ហាមួយទៀត អង្គជំនុំជម្រះសូមដល់ភាគីនូវរឿងក្តីថា ក្នុង

ករណីខ្លួនបានកត់សម្គាល់ឃើញថា មានបញ្ហាស្រដៀងគ្នា ឬក៏ដូចគ្នានេះ នៅពេលក្រោយនេះ សូមផ្តល់ព័ត៌មាន ឬក៏ធ្វើសំណើសុំឱ្យបានឆាប់មកអង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យអង្គជំនុំជម្រះមានលទ្ធភាពដាក់ពិភាក្សា ឬពិចារណាសម្រេចរៀបចំនូវកាលវិភាគសវនាការ ឱ្យធ្វើយ៉ាងណាឱ្យប្រព្រឹត្តទៅបានឆាប់រហ័ស និងមានប្រសិទ្ធភាព។ បញ្ហាទីពីរ គឺនៅរសៀលនេះ ទំនងជាអាចត្រូវពន្យារពេលសវនាការម្តែទៅសាមសិបនាទី ដោយសារតាមកាលវិភាគ យើងឃើញថានៅភាគីនៃរឿងក្តីក្រុមមេធាវីការពារក្តីមានពេលវេលាមួយម៉ោងសាមសិបនាទី។ ហើយបញ្ហានេះ វាអាស្រ័យការលើកឡើងការរបស់ភាគីវែងឬក៏ខ្លីប៉ុណ្ណោះ។ តែទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសូមជម្រាបថា បញ្ហានេះ យើងខ្ញុំបានសម្របសម្រួលជាមួយនឹងខាងអង្គភាពដឹកជញ្ជូននៃ អ.វ.ត.ក រួចហើយ ដើម្បីរៀបចំសម្រួលនូវការធ្វើដំណើរត្រឡប់ទៅវិញរបស់ភាគី ហើយនិងមន្ត្រីបុគ្គលិកដែលរបស់ អ.វ.ត.ក។

[១៤:៥១:៣៨]

បញ្ហាមួយទៀត គឺដើម្បីបញ្ជាក់ឱ្យបានតែច្បាស់លាស់ថែមទៀត ដោយសារមានការកត់សម្គាល់លើបញ្ហាមួយចំនួននៅក្នុងការប្រើប្រាស់ពាក្យពេចន៍នៅក្នុងកិច្ចដំណើរការនេះ អាចធ្វើឱ្យមានការភ័ន្តច្រឡំ យើងខ្ញុំសូមប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ដើម្បីជម្រាបជូនភាគី។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងបានមានយោបល់ទៅលើចំណុចដទៃទៀត។ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីក្រុម នួន ជា បានប្រើប្រាស់ពាក្យថា *"មីនីត្រាយល"* សវនាការខ្នាតតូច ឬពាក្យការប្រើពាក្យនេះមិនសម-- មិនត្រឹមត្រូវទេ នៅក្នុងបន្ទប់សវនាការនេះ។ វាជាពាក្យមួយដែលធ្វើឱ្យមានប៉ះពាល់ដល់អារម្មណ៍ភាគីដទៃ ហើយសម្រាប់សេចក្តីថ្លៃថ្នូរនៃដំណើរការនីតិវិធីនេះផងដែរ។ ពាក្យដែលត្រឹមត្រូវ បើសិនជាអាចមានន័យទៅដល់ការវាយតម្លៃ អំពីរយៈពេលនៃសំណុំរឿង០០២/០១។ ហើយក៏មានការស្នើសុំឱ្យប្រើប្រាស់ឱ្យបានត្រឹមត្រូវ ថាការចោទប្រកាន់មកលើជនជាប់ចោទ និងផលប៉ះពាល់នៃបទល្មើសដែលបានចោទប្រកាន់ ថាបានប្រព្រឹត្តមកលើជនរងគ្រោះនោះ បើប្រើពាក្យនេះ ហាក់ដូចជាមិនធ្ងន់ធ្ងរ។ ដូច្នេះ សូមអរគុណលោកប្រធាន។ សូមប្រើពាក្យពេចន៍ឱ្យបានត្រឹមត្រូវ។

[១៤:៥៣:៣៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។

ជាបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីទាំងបីក្រុមដើម្បីមានឱកាសនៅក្នុងការលើកឡើង ទៅនឹងការជំទាស់នឹងការស្តាប់សក្ខីកម្មរបស់អ្នកជំនាញ ប៉ែន ឃៀរនិន តាមរយៈប្រព័ន្ធសោតទស្សន៍ ហើយនិងលើកទឡ្ហីករណ៍សុំឯកសារបន្ថែមពីអ្នកជំនាញ ប៉ែន ឃៀរនិន ឲ្យបានមុនពេលគាត់មកផ្តល់សក្ខីកម្ម។ ហើយអង្គជំនុំជម្រះសូមជម្រាបថា ក្រុមមេធាវីទាំងបីក្រុម គឺមានពេលមួយម៉ោងកន្លះ ហើយការបែងចែកពេលវេលាអាស្រ័យទៅលើក្រុមមេធាវីទាំងបីក្រុម។ ក្នុងករណីមិនមានការបែងចែកពេលវេលាទេនោះ គឺមួយក្រុមមានពេលវេលា ៣០នាទី។ ហើយដោយឡែក ដោយសារបញ្ហានេះ ជាការលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី។ ដូច្នេះ អង្គជំនុំជម្រះសូមផ្តល់ជូនវេទិកាទៅក្រុមមេធាវីការពារក្តី អៀង សារី មុន ក្រុមមេធាវីការពារក្តីដទៃទៀត។

សូមអញ្ជើញ!

[១៤:៥៤:៤៦]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក លោកស្រីចៅក្រម។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា ទាំងនៅក្នុងបន្ទប់សវនាការ ខាងក្រៅបន្ទប់សវនាការ។ ខ្ញុំបាននិយាយជាមួយសហការីរបស់ខ្ញុំហើយ។ ខ្ញុំនឹងប្រើប្រាស់ពេលវេលាដែលបានចែងចែកគ្នា ហើយខ្ញុំជឿជាក់ថា ប្រហែលជាយើងខ្ញុំអាចបញ្ចប់ ប្រហែលជានៅត្រឹមម៉ោងបួនល្ងាចនេះ។

ខ្ញុំបានកត់សម្គាល់ឃើញថា ខ្ញុំបាន មុន ប៉ុន្មាននាទីមុននេះ បានផ្តល់ឯកសារដើម្បីទៅចែករំលែកគ្នាជាមួយនឹងសហព្រះរាជអាជ្ញានៅក្នុងរឿងរបស់លោក ប៉ែន ឃៀរនិន នេះ។ ដូច្នេះ ខ្ញុំនឹងលើកឡើងកត់សម្គាល់នៅក្នុងបទបង្ហាញរបស់ខ្ញុំនេះ។ ហើយនិងពិនិត្យមើលទៅលើឯកសារនេះតែម្តង លើកលែងតែទឡ្ហីករណ៍របស់ខ្ញុំនោះវាមានហេតុផលមួយផ្សេង។ ប៉ុន្តែ ចាំមើលថាតើនឹងប្រព្រឹត្តទៅដោយរបៀបណានោះ។

[១៤:៥៥:៥៣]

ទីមួយ ចំណុចចុងក្រោយទាក់ទងទៅនឹងព័ត៌មានបន្ថែម ខ្ញុំអាចលើកឡើងបញ្ហានេះប្រហែលជាប្រាំនាទី ឬក៏តិចជាងនេះ។ ក្នុងការរៀបចំទៅពាក់ព័ន្ធទៅនឹងនឹងសាស្ត្រាចារ្យ ប៉ែន ឃៀរនិន នេះដូច

ខ្ញុំបានលើកឡើងនេះ គឺថាគាត់បានសរសេរសៀវភៅយ៉ាងច្រើន។ ហើយចំពោះអ្នកដទៃទៀតដែលបានដឹងអំពីព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងពេលនោះផងដែរ ប្រហែលជានឹង យើងខ្ញុំនឹងត្រូវការព័ត៌មានបន្ថែមទៀត។ ឯកសារខ្លះដែលយើងខ្ញុំបានស្នើសុំនោះ យើងខ្ញុំបានឮ ខ្ញុំអាចប្រើពាក្យនេះទៅចុះ។ ខ្ញុំបានឮថា នៅពេលវេលា គឺឮនៅពេលដែលខ្ញុំបានធ្វើសំណើសុំនោះ។ ដូចដែលយើងខ្ញុំបានស្នើសុំនេះក៏សុំស្នើសុំផ្នែកខ្លះនៃឯកសារនេះ ដោយសារតែពេលដែលខ្ញុំពិនិត្យសៀវភៅរបស់គាត់ទៅ គឺថាច្បាស់ណាស់នៅក្នុងសេចក្តីថ្លែងការណ៍ខ្លះដែលបានធ្វើ ក៏សេចក្តីសន្និដ្ឋានដែលគាត់បានធ្វើ ហើយវាមិនមានលើកឡើងអំពីសាក្សី មិនមានលើកឡើងអំពីប្រភពណា ហើយសំណេរដោយដៃនោះ គឺដូចសហព្រះរាជអាជ្ញាបានលើកឡើងដែរ គឺថាមានអ្នកកាសែតម្នាក់គឺថានឹងត្រូវកោះហៅមកឆ្លើយ គឺគាត់បានរក្សានូវកំណត់ត្រាសរសេរដោយដៃនេះ។

[១៤:៥៧:៣៧]

យើងខ្ញុំបានស្នើសុំថា ជាសំណើសុំមួយប្រកបដោយភាពស្មោះត្រង់ទេ វាអាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេចពាក់ព័ន្ធទៅនឹងលោក ប៉ែន យៀរនិន នេះ ថាតើអ្វីដែលវាមានការពាក់ព័ន្ធដែលអាចយកមកប្រើប្រាស់នៅក្នុងតុលាការនេះ។ អ្វីដែលធ្វើឲ្យខ្ញុំមានការភ្ញាក់ផ្អើលនោះ វន្ធត់នោះ គឺមិនគិតថាតើសហព្រះរាជអាជ្ញានិយាយថាម៉េច? ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថាម៉េចនោះទេ? យើងមិនបាច់គិតដល់ចំណុចនេះទេ។ វាមានប្រតិកម្មភ្លាមៗដែលអាចនឹងមើលឃើញតែម្តង គឺគាត់ធ្វើការដោះស្រាយជំនួសលោក ប៉ែន យៀរនិន ទៅវិញ។

[១៤:៥៨:២៧]

ដូច្នេះ យើងខ្ញុំសូមស្នើសុំដល់អង្គជំនុំជម្រះថា វាមិនមានព្យសនកម្មអីទៅដល់លោក ប៉ែន យៀរនិន ទេ។ ឧទាហរណ៍អត្ថបទសិក្សាស្រាវជ្រាវជាន់ខ្ពស់របស់គាត់ គឺថាត្រូវចែករំលែកគ្នា។ តើតុលាការអាចបង្ខំគាត់បានទេ? មិនអាចបង្ខំបានទេ។ តើយើងកំពុងតែសុំឲ្យតុលាការបង្ខំគាត់ ឲ្យគាត់ឆ្លើយ ឬយ៉ាងម៉េច? គឺយើងធ្វើសំណើ។ សំណើនេះគឺថាអាចបញ្ជូនទៅលើ ប៉ែន យៀរនិន ថាតើគាត់នឹងមានឆន្ទៈចែករំលែកព័ត៌មានទាំងអស់នេះជាមួយយើងទាំងអស់ដែរឬក៏អត់ ដើម្បីធ្វើការសួរទៅដល់គាត់នោះ? តើវាយឺតពេកឬយ៉ាងម៉េច? វាអាចថាយឺតក៏ថាបាន ប៉ុន្តែយើងពិចារណាថា នៅក្នុងសំណុំរឿងនេះ ក៏ដូចជានូវអ្វីដែលយើងធ្វើទាំងអស់គ្នា។ ហើយណាមួយពេលនេះ គឺពេលនេះជាពេលកំពុងតែបើកសវនាការផង។ យើងត្រូវរៀបចំសម្រាប់សាក្សីនូវឯកសារទាំងអស់ដោយផ្តោតទៅលើសាក្សីពាក់ព័ន្ធទៅនឹងគំនិត

យោបល់ដែលយើងត្រូវរៀបចំឡើង។ ហើយលោក លោកស្រីចៅក្រម ក៏ប្រហែលនឹងអាចត្រូវការព័ត៌មានបន្ថែមដែរ។ ខ្ញុំមកពីយុត្តាធិការដែលថា ការស្នើសុំនោះវាគ្មានអ្វីដែលខាតបង់ វាគ្មានអ្វីដែលគួរប៉ះពាល់អីទេ។ ការដែលគ្រាន់តែស្នើសុំ គឺមិនប៉ះពាល់អីទេ ពេលនោះគាត់ជាអ្នកសម្រេចទៅវិញទេ។

អ៊ីចឹងយើងត្រូវ ដូច្នេះយើងខ្ញុំសូមប្រគល់នាទីនេះជូនឆន្ទានុសិទ្ធិរបស់លោកអង្គជំនុំជម្រះ ថាតើយើងត្រូវស្នើសុំគាត់ ហើយគាត់មានឆន្ទៈនឹងផ្តល់ជូនឬក៏អត់? អង្គជំនុំជម្រះ គឺថាអាចនឹងធ្វើការស្នើសុំ ហើយរង់ចាំចម្លើយរបស់គាត់ ថាតើយើងនឹងខិតខំប្រឹងប្រែងឲ្យវាអស់ពីលទ្ធភាព ឬក៏យ៉ាងណា? ដោយសារតែគាត់បានសរសេរសៀវភៅជាច្រើន ហើយគាត់ជាអ្នកជំនាញ។ នេះគឺជាអ្វីដែលខ្ញុំនិយាយទាក់ទងទៅនឹងលោក ប៉ែន ឃៀវនិន។ ឥឡូវនេះខ្ញុំសូមផ្តោតការយកចិត្តដែលថា ហេតុអ្វី ថាតើហេតុអ្វីបានជាយើងគិតថាឲ្យគាត់ឆ្លើយតាមប្រព័ន្ធសោតទស្សន៍? ឥឡូវខ្ញុំនិយាយពីប្រព័ន្ធវីដេអូនេះវិញម្តង។

[១៥:០១:១២]

ជាងមួយខែកន្លងមកនេះ លោកបណ្ឌិត ប៉ែន ឃៀវនិន គឺថាត្រូវមានគេទាក់ទងទៅគាត់ ដោយអនុលោមទៅតាមសេចក្តីណែនាំរបស់តុលាការ តាមរយៈលោក ខេលី មានការផ្លាស់ប្តូរយោបល់គ្នាមិនមែនតែត្រឹមតាមរយៈអ៊ីម៉ែលទេ គឺមានការឆ្លើយឆ្លងតាមទូរស័ព្ទដែលមានការបញ្ជូនសារនេះទៅឲ្យលោក ប៉ែន ឃៀវនិន ដើម្បីឲ្យឃើញថា តើមានការយល់ព្រមគ្នា ហើយបាននិយាយគ្នាអំពីអ្វីខ្លះ? នេះគឺជាឯកសារ ខ្ញុំបានទទួលក្នុងថ្ងៃនេះតែម្តង។ ហើយយ៉ាងហោចណាស់ការទាក់ទងនេះ ក្នុងខែកុម្ភៈ នោះលោក ខេលី ក្នុងលិខិតរបស់គាត់នោះ ក្នុងលិខិតដែលគាត់ផ្ញើជូនសាស្ត្រាចារ្យ ប៉ែន ឃៀវនិន គឺខែកុម្ភៈ ថ្ងៃទី១៣ ខែកុម្ភៈ ដែលជាលិខិតដែលផ្ញើជូនពីអង្គភាពគាំពារសាក្សី។ គាត់ថា គាត់មិនអាចមានពេលមកប្រទេសកម្ពុជាក្នុងឆ្នាំ២០១២ នេះទេ ប៉ុន្តែគាត់អាចផ្តល់ចម្លើយតាមរយៈ ផ្តល់សក្ខីកម្មនេះតាមរយៈប្រព័ន្ធវីដេអូនេះ។ ហើយនៅក្នុងកថាខណ្ឌ៤នៃលិខិតនេះ គឺលោក ខេលី បញ្ជាក់ថា ខ្ញុំគិតថាប្រហែលជាមានសារប្រយោជន៍ណាស់បើសិនណាជាយើងអាចធ្វើតាមរយៈប្រព័ន្ធសោតទស្សន៍នេះ។ ហើយនៅត្រង់ចំណុចខ្លះនោះនៃលិខិតនេះ មួយខែក្រោយមក ខ្ញុំជឿថាគឺនៅក្នុង នៅថ្ងៃទី៨ ខែមីនា គឺគេបានទទួលព័ត៌មានខ្លះពីសាស្ត្រាចារ្យ ប៉ែន ឃៀវនិន គាត់ថា និយាយអំពីសកម្មភាព និងមុខងារដែលគាត់កំពុងតែធ្វើនេះ។ ថាតើខ្ញុំបាន បើសិនណាជាខ្ញុំបានទទួលព័ត៌មាននេះតាំងពីដើមទី ខ្ញុំនឹងៗបញ្ជូនមនុស្សម្នាក់ទៅសាកលវិទ្យាល័យយែល បញ្ជូនមនុស្សពីសហរដ្ឋអាមេរិកជាដើម ដើម្បីសួរថាតើព័ត៌មាននេះវាពិតប៉ុនណា ត្រឹមត្រូវប៉ុនណា?

[១៥:០៣:៣៣]

ខ្ញុំមិនចង់ថាដោយសារថាឈ្មោះគាត់ យៀវនិន ប៉ុណ្ណោះទេ ខ្ញុំមិនលើកឈ្មោះទៅសាក្សីអ្នកដទៃចំណ្ណោះនោះទេ។ ហើយខ្ញុំគត់សម្គាល់ឃើញយ៉ាងដូច្នេះ ហើយខ្ញុំក៏បានដឹងពីលោកនោះ គឺថាគាត់កំពុងតែបង្រៀននៅសាកលវិទ្យាល័យយែល។ ការសង្រៀនសម្រាប់រដូវក្ដៅនេះ គឺកំពុងតែបន្តហើយ ហើយបណ្ឌិត យៀវនិន ហាក់បីដូចជាគាត់មិនមានកាតព្វកិច្ចដែលត្រូវបង្រៀនក្នុងអំឡុងពេលនេះទេ ប៉ុន្តែយើងខ្ញុំដឹងថា សាស្ត្រាចារ្យរូបនេះ គឺគាត់មានកាតព្វកិច្ចទូទៅមួយទៀតក្រៅពីការបោះពុម្ពផ្សាយសៀវភៅនិងគ្រប់គ្រងទៅលើគណៈកម្មាធិការមួយនោះ។

ដូច្នេះយើងខ្ញុំយល់ឃើញថា គាត់រវល់ណាស់ ប៉ុន្តែយើងក៏កត់សម្គាល់ឃើញថា មិនមែនមិនមានថាថ្ងៃណាមួយ ថាតើព្រឹត្តិការណ៍នេះវាកើតឡើងពេលណា ហើយគាត់ ថាតើគាត់នឹងមិនមានពេលក្នុងឆ្នាំ២០១២ នេះទាំងមូលឬក៏យ៉ាងណា? ការដែលមានសន្ទនាគ្នារវាងសហព្រះរាជអាជ្ញាជាមួយនឹង ប៉ែន យៀវនិន នេះ គឺថាខ្ញុំប្រាកដជានឹងសួរថា លោកអាចអង្កន់ពេលវេលាប្រាប់ខ្ញុំបានទេ? លោកសម្រាកនៅពេលណា? ពេលសម្រាកលោកធ្វើអី? ដើម្បីចង់បានគំនិតយោបល់ខ្លះ។ នេះគ្រាន់ហាក់បីដូចជាបញ្ជីមួយ ដែលគាត់មានជំនួយការរបស់គាត់ បង្រៀនជំនួសគាត់ ចូលបង្រៀនជំនួសគាត់នៅក្នុងថ្នាក់នោះ។ អ្នកដែលរៀនដើម្បីយកសញ្ញាបត្របណ្ឌិតនេះ គឺថាមិនមានការគ្រប់គ្រងអីទេ ដោយសារគេត្រូវសិក្សាស្រាវជ្រាវ ដើម្បីសរសេរនិក្ខេបទរបស់គេ។ យ៉ាងហោចណាស់ការសរសេរបែបនេះនៅសហរដ្ឋអាមេរិកមានជំនួយការសាស្ត្រាចារ្យដើម្បីជួយ។ ដូច្នេះ សាស្ត្រាចារ្យម្នាក់អាចអនុវត្តមានពីគណៈកម្មាធិការនោះបាន ដោយធ្វើដំណើរទៅកាន់ប្រទេស បរទេសណាមួយ។ ដូច្នេះការទាក់ទងគាត់តាម ស្កាយ ឬក៏ពីទូរស័ព្ទនេះគឺអាចធ្វើទៅបានហើយ។ អ៊ីចឹង យើងពិនិត្យមើលថាតើគាត់អាចរវល់ទាំងស្រុងតែម្ដង ឬក៏យ៉ាងម៉េច? សូមចងចាំថា យើងបានជូននូវ-- យើងខ្ញុំទទួលបានដំណឹងនៅខែតុលា ឆ្នាំ២០១១ ថាគាត់អាចចូលខ្លួនមកតុលាការបាន ដែលគាត់ជាសាក្សីខាងសហព្រះរាជអាជ្ញា។ ឥឡូវនេះ គាត់គឺថាគេប្រើពាក្យថា “គាត់ជាអ្នកផ្ដល់ប្រឹក្សា ផ្ដល់យោបល់ទៅដល់ខាងផ្នែកជនរងគ្រោះ ក៏ដូចជាផ្នែកខាងសហព្រះរាជអាជ្ញា”។

[១៥:០៦:២៤]

នៅក្នុងអំឡុងនៃកិច្ចស៊ើបសួរ មុនពេលបញ្ហានេះបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត គឺថាមានបុគ្គលិកដែលធ្វើការនៅសហព្រះរាជអាជ្ញាមានទំនាក់ទំនង ឬក៏មានទំនាក់យ៉ាងប្រសើរ និងជិតជិតជាមួយ

នឹងបណ្ឌិត ប៉ែន យៀវនិន នេះ។ ជាពិសេសេ ខ្ញុំសំដៅទៅលើលោក ក្រេក អេតធេសាន់ នេះតែម្តង។ គាត់ធ្វើការជាមួយនិងលោក ប៉ែន យៀវនិន ហើយគាត់ក៏ធ្លាប់ធ្វើការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ ដូច្នេះបញ្ជាក់ឲ្យឃើញថាគាត់អាចគ្រាន់តែជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ គឺមិនមែនជាសាក្សីទេ ដូច្នេះ មិនមានអ្វីគួរឲ្យព្រួយបារម្ភទេ។ គាត់ជាសាក្សីរបស់ការិយាល័យសព្រះរាជអាជ្ញា។ ពួកគេអាច-- គេអាចនិយាយថា មិនមែនអ្វីប៉ះពាល់ទៅដល់សិទ្ធិជនជាប់ចោទទេ គេអាចអ៊ីចឹងបាន ដោយសារគាត់ជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ គាត់គ្រាន់តែឆ្លើយទៅនឹងសំណួរទាំងឡាយណាដែលដាក់ជូនទៅគាត់នោះ ដោយមិនមានអ្វីដែលត្រូវស្ទាក់ស្ទើរនោះទេ។ ប៉ុន្តែ ពាក់ព័ន្ធមកមេធាវីការពារក្តី វាមានលក្ខណៈខុសគ្នា ពីព្រោះខាងភាគីការពារក្តីគឺគាត់នឹងត្រូវបានផ្តល់ឲ្យនូវប្រភពឯកសារទាំងអស់ ឬក៏យ៉ាងហោចណាស់អ្វីដែលគាត់បានសរសេរផងដែរ។ ប្រហែលជាគាត់បានសរសេរប្រធានបទទៅដល់៥០ឯនោះ ៥០អត្ថបទឯណោះ។ ដូច្នេះយើងត្រូវសួរគាត់នៅត្រង់ចំណុចណាមួយ។

[១៥:០៨:០៣]

លោក លោកស្រីចៅក្រម កាលណាយើងកម្រិតរឿងក្តីតែចំពោះ០០២/០១ ។ ដូច្នេះយើង-- ជាការពិតហើយ យើងកម្រិតនៅក្នុងរឿងក្តីនេះ។ អ្វីដែលសហព្រះរាជអាជ្ញាអាចធ្វើបាន និងមានលទ្ធភាពបន្តទៅទៀត នេះសម្រាប់តែបញ្ហាបរិបទនេះតែប៉ុណ្ណោះ។

ដូច្នេះ ពេលណាយើងមើលអ្វីដែលយើងចង់ស្នើសុំឲ្យគាត់ផ្តល់សក្ខីកម្ម នោះមិនមែនជាបញ្ហាតូចតាចទេ។ ប្រធានណាបទណាមួយក៏ដោយ បញ្ហាលេចធ្លោណាមួយដែលពាក់ព័ន្ធនៅក្នុងរឿងក្តីនេះ គឺគាត់ជាបុគ្គលដែលមានសច្ចភាព គឺគាត់ជាសាក្សីមួយសំខាន់បំផុតដែលត្រូវមានវត្តមាននៅទីនេះ។

[១៥:០៨:៥៧]

ត្រឡប់ទៅអ្វីដែលខ្ញុំនិយាយខាងដើម គឺថាក្នុងឆ្នាំ២០១១ គឺគេបានទាក់ទងទៅគាត់ហើយ លើកលែងៗតែសហព្រះរាជអាជ្ញាបានយកឈ្មោះគាត់មកដាក់ក្នុងបញ្ជីសាក្សីដោយមិនប្រាប់ទៅគាត់ អាហ្នឹងបានមិនអាចធ្វើទៅបាន។ ប្រសិនបើមិនខាងសហព្រះរាជអាជ្ញាទេ សាលាដំបូងអាចធ្វើការទាក់ទងតាមរយៈមន្ត្រីច្បាប់។ ហេតុអ្វីបើសិនមិនធ្វើអ៊ីចឹង? ហេតុអ្វីបានជាមិនជូនដំណឹងយើងកាលពីខែតុលាថាគាត់មាននៅក្នុងបញ្ជី។ យើងខ្ញុំបញ្ជាក់ថានៅក្នុងខែមករា ខ្ញុំបានសួរថា តើ យៀវនិន ត្រូវបានកោះហៅដែរឬទេ? នៅពេលនេះគឺខ្ញុំមិនសួរទៀតទេ។ ដោយសារតែ ខ្ញុំនៅតែមានភាពឆ្ងល់ ថាតើគាត់មានលទ្ធភាពចូលរួមនៅទីនេះដែរឬទេ? មិនមែនថាគាត់ជាប់រវល់នោះទេ តើគាត់ចង់មកទីនេះតទល់ដោយផ្ទាល់ដែរឬទេ?

ដូច្នេះយើងសូមលើកឡើងថា នៅពេលនេះពាក់ព័ន្ធថា តើបុគ្គលណាជា ឃៀរនិន។ ឃៀរនិន ជានរណា គឺគាត់ជាសាក្សីរបស់សហព្រះរាជអាជ្ញា គាត់ជាសាក្សីមិនមែនតែសហព្រះរាជអាជ្ញាទេ គឺសម្រាប់យើង ដើមបណ្តឹងរដ្ឋប្បវេណី និងអង្គជំនុំជម្រះផងដែរ។ ដូច្នេះហើយ ឃៀរនិន ត្រូវតែមកផ្តល់សក្ខីកម្ម។ គឺគាត់លោក ឃៀរនិន បានបញ្ជី ផ្តល់បញ្ជីការងារជាច្រើនហើយគាត់បានលើកឡើងថាគាត់មិនទំនេរ ក៏ប៉ុន្តែគាត់ជម្រាបថាគាត់អាចមកបាននៅក្នុងឆ្នាំ២០១៣។ ខ្ញុំសូមជម្រាបថា ប្រសិនបើគាត់ទំនេរឆ្នាំ ២០១៣ គឺគាត់អាចចំណាយពេលប្រាំបី-ប្រាំបួនខែនេះ ថាតើគិតមើលកាលវិភាគរបស់គាត់ទំនេរនៅក្នុង ឆ្នាំ២០១៣ ត្រង់ពេលណាដើម្បីមកផ្តល់សក្ខីកម្មដល់យើង។

ខ្ញុំគិតថា លោក លោកស្រីចៅក្រម ជាចៅក្រមវិជ្ជាជីវៈពិចារណាទៅលើចំណុចនេះ។

[១៥:១០:៥១]

ជាធម្មតាយើងចង់ឲ្យបញ្ចូលភស្តុតាងដែលមានលក្ខណៈរៀបរាប់លម្អិត ដោយសារតែនៅចំពោះ មុខចៅក្រម។ ចៅក្រមដែលមិនមែនវិជ្ជាជីវៈគេត្រូវតែពិនិត្យមើលទៅលើភស្តុតាងដែលមានការរៀបរាប់ ក៏ប៉ុន្តែយើងខ្ញុំដឹងអំពីវិជ្ជាជីវៈរបស់លោក លោកស្រីចៅក្រម។ លោក លោកស្រីចៅក្រមដឹងអំពីរឿងក្តី នេះ មិនថាគាត់មកផ្តល់សក្ខីកម្មនៅក្នុងឆ្នាំ២០១២, ២០១៣ ខែមករា ឬក៏ខែកុម្ភៈនោះទេ។ សហព្រះរាជ អាជ្ញា គឺគាត់លើកឡើងថា ២០១២ គឺតាម *វីដេអូលីង* តាមសោតទស្សន៍ ប្រសិនបើអត់ទេគឺមិនអាច នោះទេ គឺមានជម្រើសផ្សេងទៀត។ តែបញ្ហាចោទនេះ យើងសួរថាតើគាត់មានឆន្ទៈមកទីនេះដែរឬទេ? ឬក៏គាត់រវល់មិនមកទីនេះ?

[១៥:១១:៤១]

គឺខ្ញុំសូមលើកអំពីបញ្ហាចំណុចនេះ ខ្ញុំសូមបញ្ជាក់ទៅលើយុត្តិសាស្ត្រ។

លោក លោកស្រីចៅក្រមជាទីគោរព នៅក្នុងថ្ងៃនេះយើងខ្ញុំបានបញ្ជាក់លើឧបសម្ព័ន្ធដែលពាក់ព័ន្ធ ទៅនឹងរឿងក្តីចំនួន៧២។ ២៩ មកពី អាយ.ស៊ី.ធី.អ និងពីរ មកពីសៀរ៉ាឡេអូន និងមួយចំនួនទៀត-- និងពីរទៀតមកពី អាយ.ស៊ី.ស៊ី។ ដូច្នេះហើយយុត្តិសាស្ត្រទាំងអស់នេះ គឺជាយុត្តិសាស្ត្រតំណាងនៃរឿង ក្តី។ យើងបានធ្វើការពិនិត្យមើលហើយជ្រើសរើសរឿងក្តីទាំងអស់នោះយកមកដាក់ចូល ហើយជូន ដំណឹងក្នុងពេលខ្លីតែប៉ុណ្ណោះ។

លោក លោកស្រីចៅក្រម រឿងក្តីដែលអនុញ្ញាតឲ្យមានការធ្វើតាមប្រព័ន្ធសោតទស្សន៍។ ដូច្នេះ ហើយយើងធ្វើឲ្យមានតុល្យភាព។ យើងមេធាវីការពារក្តីជាភាគី ដូច្នេះហើយគឺយើងត្រូវតែលើកឡើង

យើងត្រូវតែចូលរួមនៅក្នុងរឿងក្តី។ យើងមានរយៈពេលកម្រិត។ ដូច្នេះហើយយើងធ្វើការពិនិត្យទៅលើយុត្តិសាស្ត្រទាំងអស់នេះ។

[១៥:១២:៥១]

ចំណុចនេះ ខ្ញុំសូមបញ្ជាក់មួយចំណុចទៀត នៅពេលដែលយើងនិយាយអំពី អាយ.ស៊ី.ធី.អ័រ និង អាយ.ស៊ី.ធី.វ៉ាយ។ នៅពេលដែលយើងនិយាយអំពីរឿងក្តីនេះ តុលាការកំពូល អាយ.ស៊ី.ធី.អ័រ និង អាយ.ស៊ី.ធី.វ៉ាយ គឺតុលាការកំពូលទាំងពីរនោះមានចៅក្រមតែមួយ។ យើងអត់និយាយស្ថាប័នផ្សេងគ្នានោះឡើយ។ នៅពេលយើងនិយាយអំពីសាលាដំបូង គឺវាមានលក្ខណៈខុសគ្នា។ យើងមិនគួរច្រានចោលរឿងក្តីរបស់ អាយ.ស៊ី.ធី.អ័រ ដោយសារតែវាមានលក្ខណៈតឹងរ៉ឹងនៅក្នុងសាលាដំបូង និងតុលាការកំពូលនោះទេ ដែលក្នុងនោះគេធានាយ៉ាងណា ចង់ឲ្យសាក្សីមកចូលខ្លួនបង្ហាញសក្ខីកម្ម។

[១៥:១៣:៣៩]

ខ្ញុំត្រូវបានជម្រាបថា ឲ្យបន្ថយល្បឿនបន្តិចដោយសារតែវាលឿនពេក។

ខ្ញុំលើកឡើងករណីមួយចំនួនតែប៉ុណ្ណោះ។ ក៏ប៉ុន្តែជាបឋមដូចដែលលោក លោកស្រីចៅក្រមបានជ្រាបរួចមកហើយ នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១២ យើងខ្ញុំបានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ហើយយើងដាក់ចំណងជើងថា"ចម្លើយតប"។ យើងដាក់ចំណងជើងថា "ចម្លើយតប" ដោយសារតែសហព្រះរាជអាជ្ញាបានសេចក្តីជូនដំណឹង យើងបានយល់ឃើញថាសេចក្តីជូនដំណឹងនោះ គឺជាសំណើទៅវិញទេ ជាការពិតទៅចៅក្រមបានបញ្ជាក់ទៅលើបញ្ហានេះ ថាបានទទួលសំណើពីសហព្រះរាជអាជ្ញា។ ខ្ញុំមិនចង់លើកឡើងថាតើសហព្រះរាជអាជ្ញាគឺជាភាគីដាក់សំណើ ឬក៏មិនមែននោះឡើយ។ យើងគិតថាអ៊ីចឹងចុះ ក៏ប៉ុន្តែយើងខ្ញុំបានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដោយបង្ហាញអំពីអង្គច្បាប់ យើងបានដកស្រង់ច្បាប់ ហើយផ្តល់ជាការណែនាំជួយអង្គជំនុំជម្រះទៅលើករណីរឿងនេះ។

[១៥:១៤:៥៤]

យើងខ្ញុំសូមអរគុណដែលផ្តល់ឱកាសឲ្យយើងខ្ញុំលើកឡើងបន្ថែមទៅលើសារណាការជាលាយលក្ខណ៍អក្សរ។ ខ្ញុំក៏សូមបញ្ជាកផងដែរ នៅពេលដែលយើងដាក់សារណានៅថ្ងៃទី០៩ ខែមីនា យើងមិនបានដឹង និងទទួលបាននូវឯកសារដែលយើងទើបតែទទួលបាននេះទេ។ សហព្រះរាជអាជ្ញា គឺគាត់មានឯកសារទាំងអស់នេះ ហើយគាត់បានទទួលការណែនាំទៅលើចំណុចនេះ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ គឺខ្ញុំមិនធ្វើការតវ៉ា និងធ្វើការរិះគន់ទៅលើឯកសារទាំងអស់នោះទេ។ នៅក្នុងចម្លើយតបរបស់យើងខ្ញុំ គឺបានបង្ហាញ

អង្គហេតុទាំងឡាយដែលយើងបានបង្ហាញនៅក្នុងនោះ ដោយមានហេតុផលជាច្រើន។ ដូច្នេះមិនមែនថាយើងលើកឡើងខុសនោះទេ ជូនតុលាការ។

[១៥:១៥:៥០]

ច្បាប់មានពាក់ព័ន្ធ និងវិវត្តន៍នៅ អាយ.ស៊ី.ធី.វ៉ាយ ថាឱក គឺជារឿងក្តីដំបូង ហើយនៅពេលនោះវិធាន គឺមិនមានចែងបទដ្ឋានណែនាំមួយចំនួននោះទេ។ ក៏ប៉ុន្តែក្រោយមកវិធានវាមានចែង គឺវិធាន៨១ស្ទួន គឺវិធានរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ គឺថ្ងៃ១២ ខែកក្កដា ឆ្នាំ២០០៧ គឺសំណើសុំរបស់ភាគីសុំឲ្យអង្គជំនុំជម្រះបង្គាប់ ប្រសិនបើស្របទៅនឹងយុត្តិធម៌ ដែលថានីតិវិធីត្រូវតែធ្វើឡើងដោយប្រព័ន្ធដោយសោតទស្សន៍។ នៅក្នុងរឿងក្តី ស្តានីស៊ីក ហាក់ដូចជាបានលើកឡើងនូវលក្ខខណ្ឌមួយចំនួន។ ស្តានីស៊ីក និង ស៊ីម៉ាតូវិច “S-T-A-N-I-S-I-C, S-I-M-A-T-O-V-I-C” គឺវាជារឿងក្តីពីរដែលខ្ញុំប្រកបឈ្មោះ ហើយវាមាននៅក្នុងសារណារបស់ខ្ញុំរួចហើយ។ ខ្ញុំយោងទៅលើកថាខណ្ឌ២១ គឺឯកសារ E166/1/1។ នៅក្នុងនោះនិយាយថា សាក្សីត្រូវតែមានហេតុផលល្អ ដោយបង្ហាញអំពីលទ្ធភាពដែលខ្លួនមិនអាចចូលរួមមកក្នុងតុលាការ។ សក្ខីកម្មរបស់តុលាការត្រូវតែសំខាន់ ដើម្បីឲ្យវាមានភាពយុត្តិធម៌ចំពោះភាគីដែលបានស្នើឡើង។ ខ្ញុំនឹងលើកទៅលើចំណុចនេះផងដែរ។

[១៥:១៧:៣៦]

ចំណុចទីបី ជនជាប់ចោទ ធ្វើយ៉ាងណាដើម្បីកុំឲ្យប៉ះពាល់ទៅដល់សិទ្ធិរបស់គាត់ក្នុងការតទល់ជាមួយនឹងសាក្សី។ ដូច្នេះ យើងខ្ញុំសូមលើកឡើងថា ដែលយើងមកពីប្រព័ន្ធតទល់គ្នានេះ គឺយើងធ្លាប់ស្គាល់អំពីប្រព័ន្ធសួរឆ្លង ឬសួរតទល់ ដែលយើងហៅថា *“ក្រូស អ៊ិចសាមមីនេសិន”* ដែលវាផ្ទុយទៅនឹងប្រព័ន្ធស៊ីវិលឡដែលចៅក្រមជាអ្នកដឹកនាំការសួរសំណួរ បន្ទាប់មកអនុញ្ញាតឲ្យភាគីសួរបន្ត។ តួនាទីរបស់មេធាវីការពារក្តីនៅក្នុងប្រព័ន្ធច្បាប់បារាំង គឺវាមិនមានអ្វីខុសពីនេះនោះទេ។ ក៏ប៉ុន្តែ វាជាចំណុចមួយល្អដែលយើងបើកឲ្យមានសន្និដ្ឋានបញ្ចប់។ ក៏ប៉ុន្តែវានៅដំណាក់កាលចុងក្រោយ ដោយសារតែយើងដឹងហើយថា ការសួរសំណួរដឹកនាំដោយចៅក្រមនៅក្នុងប្រព័ន្ធស៊ីវិលឡ។ នៅក្នុងប្រព័ន្ធនេះ វាជាប្រព័ន្ធមួយចម្រុះ ដូចដែលខ្ញុំបញ្ជាក់កាលពីព្រឹកមិញដូច្នោះដែរ គឺយើងមានប្រព័ន្ធតទល់គ្នាដោយសារតែអនុញ្ញាតឲ្យសហព្រះរាជអាជ្ញានាំមុខ ឬក៏ដឹកមុខ សួរទៅលើសាក្សី។ ហើយបន្ទាប់មកអនុញ្ញាតឲ្យភាគីម្ខាងទៀតសួរសំណួរនាំមុខ។

[១៥:១៨:៥៤]

ដូច្នេះវាជាសញ្ញាណនៃ *"ក្រូស អ៊ិចសាមមីនេសិន"* សួរឆ្លង សួរតទល់។ វាជានីតិវិធីនៅក្នុងប្រព័ន្ធដែលយើងប្រើនៅទីនេះផងដែរ។ ដូច្នេះ វាក៏អាចពាក់ព័ន្ធទៅនឹងសាក្សីដែលសំខាន់ ហើយយើងអាចមើលទៅលើសាក្សីផ្ទាល់តែម្តង។ ហើយយើងខ្ញុំជឿជាក់ថា វាសំខាន់សម្រាប់ចៅក្រមឲ្យពិនិត្យមើលថា តើអាកប្បកិរិយារបស់សាក្សីយ៉ាងម៉េច នៅពេលដែលយើងនាំគាត់មកសួរតទល់?

នៅក្នុងករណីនេះ អ្វីដែលយើងស្នើសុំ គឺយើងស្នើសុំ យៀងធិរិទ្ធ គឺម៉ោងប្រាំបួនយប់ក្រោយពីគាត់រវល់ ក្រោយពីកិច្ចប្រជុំ ក្រោយពីបង្រៀន គណៈកម្ម-- ក្រោយពីចូលរួមនៅក្នុងគណៈកម្មាធិការរបស់គាត់ ឬក៏ក្រោយពីអាហារថ្ងៃត្រង់ អាចនៅពេលអាហារថ្ងៃត្រង់ ឬក៏ពេលអាហារពេលល្ងាចនោះ គឺខ្ញុំដឹង ថានឹងក្រោយពីម៉ោងប្រាំបួនល្ងាចដូចដែលខ្ញុំបានលើកឡើង យើងនឹងហត់ក្រោយពីបានជួបប្រជុំ និងធ្វើការងារ។

ដូច្នេះ នៅម៉ោងប្រាំបួនហ្នឹង គឺគាត់ឲ្យគាត់នៅទីនោះ ហើយរហូតដល់ទៅពាក់កណ្តាលយប់។ យើងខ្ញុំសូមលើកឡើងថាបញ្ហាហ្នឹង ធ្វើដូច្នេះមិនយុត្តិធម៌សម្រាប់តែសាក្សីទេ ក៏សម្រាប់ខ្ញុំដែរ។ ខ្ញុំនឹងហត់ ហើយនិងមិនចង់ឆ្លើយនោះទេ ការធ្វើដូច្នេះ គឺជាការបង្ខំឲ្យសាក្សីអង្គុយទីនោះ។ ប្រសិនបើគាត់នុំងរវល់ ហើយហត់មែនក្រោយពីម៉ោងប្រាំបួន។ ដូច្នេះ ថាតើយើងអាចសួរតទល់គាត់យ៉ាងម៉េច? ហើយប្រាកដជាមិនអាចសួរឆ្លង សួរតទល់គាត់នោះទេ។ ទោះបីជាយើងមានការគួរសមចំពោះគាត់ក៏ដោយ។ ដោយសារតែយើងដឹងហើយ តុលាការនេះ ត្រូវគោរពទៅលើបញ្ហាអ្នកស្រាវជ្រាវ និងវិជ្ជាជីវៈផងដែរ។

[១៥:២០:៥៥]

យើងខ្ញុំសូមលើកឡើងថា វានឹងប៉ះពាល់សិទ្ធិរបស់ភាគី។ ប្រសិនបើសាក្សីផ្តល់សក្ខីកម្ម ហើយវាបង្កើតជាភាពអយុត្តិធម៌ចំពោះភាគី គឺយើងត្រូវពិចារណា។ ដូច្នេះសហព្រះរាជអាជ្ញា គាត់បានបញ្ជាក់ហើយថា គាត់បានដាក់ឈ្មោះសាក្សីនៅក្នុងបញ្ជី។ សហព្រះរាជអាជ្ញាបានលើកឡើងអំពី នួន ជា ប៉ុន្តែខាងសហព្រះរាជអាជ្ញាជាអ្នកស្នើសុំ ហើយជាអ្នករៀបចំដីកាបញ្ជូនរឿងទៅស៊ើបសួរ។ ហើយនៅពេលនេះ សហព្រះរាជអាជ្ញាគឺជាអ្នកព្យាយាមបញ្ចូលនូវឯកសារ ដោយមិនចង់យកបុគ្គលនេះមកផ្តល់សក្ខីកម្ម ឬក៏ប្រសិនបើយើងមិនស្គាល់នរណាម្នាក់នៅក្នុងប្រទេសកម្ពុជា នៅប្រទេសផ្សេង អ៊ីចឹង គឺថាយើងអាចសួរទៅលើបុគ្គលនេះ ក្នុងវិធានបទមួយកម្រិត។ គឺកម្រិតតែទៅលើសំណុំរឿង០០២/០១។

[១៥:២១:៥៤]

ប្រសិនបើយើងពិនិត្យមើលដីកាបញ្ជូនរឿងទៅស៊ើបសួរ ខ្ញុំសូមឲ្យចៅក្រមពិនិត្យដោយហ្មត់ចត់

មើលលេខហ្វូតណូតមួយ ដកស្រង់ចំណុចមួយ នៅចំណុចចាប់ផ្តើមនោះ គឺយើងឃើញមាន អេតឆេសាន់ គាត់គឺជាអ្នកវិភាគ។ គាត់វិភាគទៅលើឯកសារ ហើយមិនថាជាភាសាខ្មែរ គឺក៏គាត់និយាយភាសាខ្មែរដែរ។ គាត់ធ្វើការវិភាគទៅលើឯកសារ គាត់ផ្តល់សក្ខីកម្មនាមុនៗ គាត់ផ្តល់សក្ខីកម្មនាពេលមុន គាត់រៀបចំដីកាបញ្ជូនរឿងទៅស៊ើបសួរ ហើយប្រសិនបើគាត់មានការនិយាយរៀបរាប់តែកម្រិតទៅលើការជំនុំជម្រះ ដែលអង្គជំនុំជម្រះបានកំណត់ចំពោះសាក្សីនេះ តើយើងគិតយ៉ាងម៉េច? មិនមែនថាសហព្រះរាជអាជ្ញា គាត់មានបំណងយល់យ៉ាងណានោះទេ វានឹងប៉ះពាល់ទៅដល់សិទ្ធិ ថាតើអង្គជំនុំជម្រះនឹងធ្វើឲ្យទៅដល់សិទ្ធិដែរឬទេ? ប្រសិនបើសាក្សីម្នាក់មិនមែន អេតឆេសាន់ ទេ អាចជាបុគ្គលផ្សេង ផ្តល់មកចូលសក្ខីកម្មលើកទៅលើបញ្ហាហ្នឹង ហើយយើងរង់ចាំដល់២០១៣ ដើម្បីរង់ចាំ ប៉ែន យៀវនិន មកចូលផ្តល់សក្ខីកម្មដោយផ្ទាល់។ ដូច្នេះ ថាតើវាប៉ះពាល់យ៉ាងម៉េច?

ដូចដែលខ្ញុំបញ្ជាក់ពីមុនអ៊ីចឹង លោក លោកស្រីចៅក្រមជាចៅក្រមវិជ្ជាជីវៈ យើងមិនខ្វល់អំពីការរៀបរាប់សម្រាយទៅលើភស្តុតាងនោះទេ។ ក៏ប៉ុន្តែយើងត្រូវគិតបន្តិច នៅក្នុងរឿងក្តីខំមិនឡូ ចៅក្រមគឺគាត់មិនមែនថាដឹងអង្គហេតុទាំងអស់នោះទេ។ ក្រុមប្រឹក្សាវិនិច្ឆ័យ គឺគាត់មិនដឹងអង្គហេតុទេ។ ក៏ប៉ុន្តែនៅក្នុងប្រព័ន្ធស៊ីវិលឡូ ចៅក្រមគឺគាត់អានសំណុំរឿងទាំងស្រុង បានជ្រើសរើសឯកសារសំណុំរឿង។

[១៥:២៣:៥០]

ដូច្នេះ មិនមែនថា ចៅក្រមនឹងមិនបានមើលទៅលើការរៀបរាប់របស់សហព្រះរាជអាជ្ញានោះទេ ទោះបីជាបុគ្គលហ្នឹងគាត់មិនមកឆ្នាំពីរពាន់ដប់-- មិនមកចូលរួមនៅក្នុងឆ្នាំ២០១២ ហើយមកចូលរួមក្នុងឆ្នាំ២០១៣ ក៏ដោយ។ ដូច្នេះ នេះគឺជាទឡ្ហីករណ៍របស់យើងខ្ញុំ។ ខ្ញុំសូមបញ្ជាក់ថា វាជាសវនាការមួយដែលហាក់ដូចជាមិនចង់នាំបុគ្គលនេះមក។ វាជាបច្ចេកទេសដោយចេតនាមួយ ព្យាយាមបង្វែរទិសដៅ។ ប្រសិនបើយើងមិនមានបុគ្គលរូបនេះមកចូលទេ ថាតើរឿងក្តីហ្នឹង នឹងបានបរាជ័យ ឬក៏យ៉ាងម៉េច? នៅក្នុងរឿងក្តីតុលាការរវ៉ាន់ដា នៅក្នុងរឿងក្តីមួយ ដែលក្នុងនោះ គេបានកំណត់លក្ខខណ្ឌផងដែរ។ ខ្ញុំនឹងអានឈ្មោះ ដោយសារឈ្មោះនុ៎ងពិបាកប្រកបណាស់។ ហើយខ្ញុំក៏មានបញ្ហាប្រឈមនឹងឈ្មោះដែរ គឺ N-Z-A-B-O-N-I-M-A-N-A។ ខ្ញុំយោងទៅលើរឿងក្តីនៅក្នុងកថាខណ្ឌ២២ ឯកសារ E166/1/1។ នេះគឺជាការដកស្រង់សម្តី៖ "លក្ខខណ្ឌទាំងអស់នេះ រួមទាំងកាលវិភាគវាយតម្លៃទៅលើសារៈសំខាន់នៃភស្តុតាង។ អលទ្ធភាព ឬក៏ការមិនមានឆន្ទៈរបស់សាក្សីមក អារូហ្សា។ ហើយថាតើហេតុផលល្អមួយបានបង្ហាញអំពីអលទ្ធភាពនិងការមិនមានឆន្ទៈមកចូលខ្លួនដែរឬទេ? ភាគីដែលស្នើសុំត្រូវតែមានបន្ទុកក្នុង

ការបង្ហាញលក្ខខណ្ឌដែលមានចែងខាងលើថាបានបំពេញ។ ការស្តាប់សក្ខីកម្មតាមរយៈប្រព័ន្ធសោត-ទស្សន៍ គឺជាការលើកលែងមួយ វាជាការលើកលែងមួយ អនុញ្ញាតតែនៅពេលដែលមានយុត្តិកម្មត្រឹមត្រូវ មានឯកសារបញ្ជាក់យុត្តិកម្មត្រឹមត្រូវ។

[១៥:២៦:០៦]

សេចក្តីសម្រេចនេះ គឺប្រសិនបើខ្ញុំអានមិនខុសនោះទេ គឺថ្ងៃ៩ ខែមីនា ឆ្នាំ២០១១ ទឡ្ហីករណ៍ដែលបានលើកឡើងគឺគេដឹងហើយថាបច្ចេកវិទ្យា គឺវិវត្តន៍លឿនណាស់។ យើងមិនចាំបាច់បារម្ភទេ គឺថាដូចតែគ្នា។ ក៏ប៉ុន្តែនៅទីនេះ គេមានសេចក្តីចេញពីតុលាការ គឺតុលាការស្រដៀងគ្នានេះ ដែលសហព្រះរាជអាជ្ញាតែងតែដកស្រង់យុត្តិសាស្ត្រមក ហើយតុលាការនោះបានបញ្ជាក់នូវលក្ខខណ្ឌក្នុងហ្នឹង។

មេធាវីការពារក្តីនៅក្នុងរឿងក្តីនោះ បានស្នើសុំសាក្សីផ្តល់សក្ខីកម្មពីទីក្រុងឡាអេ ឬក៏សហរដ្ឋអាមេរិកដោយសារតែបញ្ហាសន្តិសុខ។ នៅពេលនោះមានបានបដិសេធ អង្គជំនុំជម្រះបានបដិសេធដោយសារតែបានយល់ឃើញថាការចោទប្រកាន់មានលក្ខណៈធ្ងន់ធ្ងរខ្លាំង។ ហើយបដិសេធមិនផ្តល់មិនស្តាប់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ គេបានជឿថាសាក្សីជំនាញ ហើយកាលៈទេសៈរបស់សាក្សីជំនាញនោះមានលក្ខណៈពិសេសនោះទេ។ ហើយភាគីមិនបានបង្ហាញឯកសារគាំទ្រអំពីការលើកឡើងបញ្ហាសន្តិសុខនោះទេ។

[១៥:២៧:២៧]

នៅទីនោះ គឺជាសាក្សីជំនាញ ហើយគេនិយាយអំពីកាលៈទេសៈពិសេស។ នៅពេលដែលយើងនិយាយអំពីអ្នកជំនាញ និងសាក្សី គឺយើងមានប្រភេទសាក្សីខុសៗគ្នា អាចបុគ្គលមួយចំនួនអាចមកផ្តល់សក្ខីកម្មទៅលើអត្តចរិត ហើយសាក្សីមួយចំនួន ហ្គោលស្ទូន និយាយអំពីអង្គហេតុមួយចំនួនដែលមិនមានវិវាទ ឬក៏គាត់មកផ្តល់សក្ខីកម្មសម្រាប់តែបញ្ហានៃការដាក់ទោស ឬក៏ស្ថានទម្ងន់នៃរឿងក្តី។ ក៏ប៉ុន្តែនៅពេលដែលយើងនិយាយអំពីសាក្សីជំនាញ ខាឡាវី ឬក៏ ឃៀរនិន នោះ គឺយើងនឹងស្តាប់សក្ខីកម្មជាក់លាក់។

[១៥:២៨:០៩]

នៅក្នុងរឿង-- មានរឿងក្តីមួយទៀតដែលខ្ញុំចង់ចំណាយពេលមួយចំនួនអានផងដែរ គឺមកពីតុលាការ អាយ.ស៊ី.ធី.អ័រ តុលាការកំពូល។ ដូចដែលខ្ញុំបានបញ្ជាក់ វាជាតុលាការកំពូលតែមួយ មានចៅក្រមតែមួយដូច អាយ.ស៊ី.ធី.វ៉ាយ។ គ្រាន់តែមានមុខនាទីខុសគ្នា និងនៅស្ថាប័នខុសគ្នាតែប៉ុណ្ណោះ។

ពេលខ្លះទៅ ចៅក្រមនេះទៅអារូហ្សា ស្តាប់សក្ខីកម្មរបស់ភាគីនៅទីនោះ ពេលខ្លះទៅគាត់មកទីក្រុងឡាអេ ស្តាប់សក្ខីកម្មរបស់ភាគីដែលប្តឹងទៅទីក្រុងឡាអេ។

ដូច្នេះ នៅទីនោះគឺមានសេចក្តីដែលធ្វើឡើងដោយតុលាការពីរខុសគ្នា។ មួយគឺនៅទីក្រុងឡាអេ មួយទៀតគឺនៅអារូហ្សា។ នៅក្នុងរឿងក្តីនេះ ខ្ញុំសូមអានឈ្មោះឡើងវិញគឺ Z-I-G-I-R-A-Y-I-R-A-Z-O ខ្ញុំយោងទៅលើកថាខណ្ឌ២៧ ឯកសារ E166/1/1។ នៅក្នុងរឿក្តីនេះ សក្ខីកម្មធ្វើឡើងតាមរយៈសោតទស្សន៍ហើយគេរកឃើញថាមានការរំលោភសិទ្ធិជាមូលដ្ឋាន គឺសិទ្ធិជំនុំជម្រះតាមក្នុងពេលសមស្រប។ អង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្តើមនីតិវិធីនៅអារូហ្សា តាមពីទីក្រុងឡាអេ។ គេបានស្តាប់សក្ខីកម្មរបស់សាក្សីរបស់សំខាន់របស់សហព្រះរាជអាជ្ញា បានន័យថាជនជាប់ចោទនៅអារូហ្សា ជាមួយនឹងចៅក្រម ហើយបុគ្គលមួយចំនួនទៅទីក្រុងឡាអេ។ ដូច្នេះ ជនជាប់ចោទមើលតាមប្រព័ន្ធសោតទស្សន៍ស្តាប់សក្ខីកម្ម។ ដូច្នេះខ្ញុំសូមលើកឡើងថា គ្មានអ្វីខុសគ្នាទេនៅពេលដែលយើងនិយាយអំពីជនជាប់ចោទនៅទីនេះ នៅពេលដែលយើងនិយាយអំពីមេធាវីផងដែរ ដែលមេធាវីតំណាងសិទ្ធិរបស់ជនជាប់ចោទ ប៉ុន្តែសិទ្ធិនោះជាសិទ្ធិរបស់ជនជាប់ចោទ។

[១៥:៣០:២៤]

អង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្តើមនីតិវិធីដោយសារតែសារៈសំខាន់នៃការវាយតម្លៃឲ្យបានត្រឹមត្រូវទៅលើសាក្សីរបស់សហព្រះរាជអាជ្ញា។ ដកស្រង់សម្តី៖ "ការវាយតម្លៃត្រឹមត្រូវទៅលើសាក្សីរបស់សហព្រះរាជអាជ្ញា។ បានន័យថា ចៅក្រមចង់ធ្វើការវាយតម្លៃសាក្សីឲ្យបានត្រឹមត្រូវ គឺគេនៅ--ចៅក្រមនៅអារូហ្សា ប៉ុន្តែសាក្សីផ្តល់សក្ខីកម្មពីទីក្រុងឡាអេ"។ ចៅក្រមគាត់ចង់ធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវទៅលើសាក្សីរូបនោះ។

[១៥:៣១:០៤]

អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា មានការរំលោភសិទ្ធិរបស់ជនជាប់ចោទ ខ្ញុំមិនអានឈ្មោះគាត់ទេ ជនជាប់ចោទនោះទេ ដោយសារតែចៀសវាងការវង្វេង។ វាការរំលោភសិទ្ធិជំនុំជម្រះជនជាប់ចោទនៅចំពោះមុខ។ គឺវាជាការរំលោភហួសហេតុនៅក្នុងកាលៈទេសៈនេះ។ អង្គជំនុំជម្រះតុលាការកំពូលបានដកចេញសក្ខីកម្មរបស់សាក្សីដែលបានផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍នោះ ដោយសារវារំលោភសិទ្ធិរបស់ជនជាប់ចោទ។ ដូច្នេះ ខ្ញុំចង្អុលបញ្ជាក់ចំណុចហ្នឹង ដោយសារតែវាមានរឿងក្តីច្រើនណាស់។ មួយចំនួននោះ គឺគេលើកឡើងថាមិនមានភស្តុតាងគ្រប់គ្រាន់ ហើយមួយចំនួនទៀតថា

មានភស្តុតាងគ្រប់គ្រាន់រួចហើយ។ នៅក្នុងឧបសម្ព័ន្ធដែលយើងភ្ជាប់មកជាមួយនេះ គឺយើងផ្តល់ជាការណែនាំប្រសិនបើយើងមានពេលវេលាច្រើនជាងនេះ គឺយើងខ្ញុំនឹងលើកឡើងនូវយុត្តិសាស្ត្រទាំងអស់ដែលយើងខ្ញុំបានដាក់ភ្ជាប់។

[១៥:៣២:១១]

ខ្ញុំយល់ថាយើងមានវិធានខុសពី អាយ.ស៊ី.ធី.វ៉ាយ និង អាយ.ស៊ី.ធី.អ័រ។ សហព្រះរាជអាជ្ញារួមទាំងដើមបណ្តឹងរដ្ឋប្បវេណី គាត់ពិនិត្យមើលទៅលើវិធានដែលមាននៅក្នុងទីនេះ ក៏ប៉ុន្តែនៅពេលដែលយើងអានវិធាន យើងមិនអាចធ្វើការ-- យើងមិនអាចយល់បាននោះទេ ប្រសិនបើយើងមិនពិចារណាទៅលើរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់បង្កើត អ.វ.ត.ក និងសិទ្ធិទាំងឡាយដែលជនជាប់ចោទមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ យើងខ្ញុំសូមលើកឡើងថា នៅពេលដែលយើងពិនិត្យទៅលើវិធានបទដ្ឋានទាំងអស់នេះ ទោះបីជាចេញមកពី អាយ.ស៊ី.ធី.អ័រ, អាយ.ស៊ី.ធី.វ៉ាយក៏ដោយ គឺវិធានតែងតែមានភាពខុសគ្នា។ ជាការពិត យើងឃើញថាចៅក្រមមានឆន្ទានុសិទ្ធិ។

សហព្រះរាជអាជ្ញានឹងធ្វើការតវ៉ា ផ្តល់ទឡ្ហីករណ៍ គាត់លើកឡើងថា គាត់មិនមានបំណងចង់ឲ្យសាក្សីនោះមកផ្តល់សក្ខីកម្មនោះទេ។ គាត់លើកឡើង សហព្រះរាជអាជ្ញាលើកឡើងថា ជាសាក្សីរបស់អង្គជំនុំជម្រះ ហើយឲ្យអង្គជំនុំជម្រះជាអ្នកសម្រេច។

[១៥:៣៣:១៧]

ខ្ញុំសូមបញ្ជាក់ថា នេះជាការលើកឡើងដោយមិនត្រឹមត្រូវ។ ប្រសិនបើដូច្នោះមែន សហព្រះរាជអាជ្ញាគួរតែនិយាយថា ទុកឲ្យអង្គជំនុំជម្រះសម្រេចទៅ។ ហើយឲ្យអង្គជំនុំជម្រះសម្រេចនៅពេលដែលមានភស្តុតាងគ្រប់គ្រាន់។ ហើយគាត់គាំទ្រផងដែរទៅ ថាមិនចាំបាច់ឲ្យសាក្សីរូបនោះមកផ្តល់សក្ខីកម្មក្នុងតុលាការឡើយ។

ដោយសារតែពិនិត្យមើលទៅកាលវិភាគ ប្រហែលជាយើងអាចបញ្ចប់ក្នុងពេលកំណត់។ ខ្ញុំនឹងនិយាយបញ្ចប់ក្នុងពេលបន្តិចទៀតនេះ ខ្ញុំមិននិយាយច្រើនជាងនេះឡើយ។ ក៏ប៉ុន្តែ ខ្ញុំអាចនិយាយច្រើនជាងនេះមួយម៉ោងជាងទៀត ប៉ុន្តែគ្មានអ្វី ចម្លើយអ្វីដែលត្រូវនិយាយបន្ថែមនោះទេ។

[១៥:៣៤:០២]

លោក លោកស្រីមានឯកសារ មានឧបសម្ព័ន្ធ មានវិធានច្បាប់នៅចំពោះមុខរួចហើយ។ យើងខ្ញុំទុកឲ្យអង្គជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការសម្រេច។ ក៏ប៉ុន្តែយើងខ្ញុំសូមលើកឡើង

ថា វាមិនដូចគ្នានោះទេ នៅពេលដែលយើងស្នើសុំឲ្យសាក្សីនេះផ្តល់សាក្សីពីកន្លែងចម្ងាយមក ពីទីចម្ងាយមក។ គាត់ជាសាស្ត្រាចារ្យ គាត់ល្បី គាត់នៅក្នុងស្ថាប័នប្រវត្តិសាស្ត្រ ហើយគាត់ជាប្រធានគណៈកម្មាធិការស្ថាប័ន នាយកដ្ឋាន គាត់មានសិស្ស គាត់សំខាន់ណាស់។ ដូច្នេះហើយយើងទុកឲ្យៗគាត់ទំនេរមួយរយៈសិនទៅ យើងខ្ញុំស្នើថាទុកឲ្យគាត់សម្រាកមួយរយៈសិន។ ហើយប្រសិនបើគាត់ជ្រើសរើសមកផ្តល់សក្ខីកម្មដោយផ្ទាល់នោះ គឺមិនមានអ្វីហាមឃាត់គាត់នោះទេនៅក្នុងវិធានផ្ទៃក្នុងរបស់យើង។ ហើយហេតុអ្វីបានជាយើងទាមទារឲ្យគាត់ផ្តល់សក្ខីកម្មនៅម៉ោងប្រាំបួន ទៅដល់ពាក់កណ្តាលយប់ធ្វើអី? យើងមានមន្ត្រី-- ដោយសារគេលើកឡើងថា ដោយសារយើងមានមន្ត្រីយូអ៊ិន ស្ថាប័នអង្គការសហប្រជាជាតិនៅទីនោះជួយរៀបចំ និងតាមដាននៅលើដំណើរការនេះ ឬក៏យ៉ាងម៉េច? ហើយគ្មានអ្វីមានការភ័យខ្លាចនោះទេ ក្នុង-- អំពីការរារាំងនិងការជ្រៀតជ្រែកទៅដល់លោក យៀរនិន នោះ។ ខ្ញុំគិតថា ករណីនេះគឺហេតុអ្វីយើងមិនគិតអំពីជម្រើសផ្សេង។ ជម្រើសមួយទៀតនោះ គឺឲ្យគាត់ផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ បន្ទាប់មកនៅក្នុងឆ្នាំ២០១៣ ឲ្យគាត់មកចូលខ្លួនម្តងទៀតដោយផ្ទាល់នៅក្នុងតុលាការផ្តល់សក្ខីកម្មឲ្យយើងដេញដោលបាន។ ខ្ញុំមិនជំទាស់ទេ ប្រសិនណាដរាបណាយើងអាចដេញដោលចំពោះមុខនៅក្នុងតុលាការកម្ពុជានៅក្នុងតុលាការនេះ។ នេះគឺជាជម្រើសមួយដ៏ប្រសើរបំផុត។

[១៥:៣៦:០៦]

លោក លោកស្រីចៅក្រមអាចពិចារណាថា យើងព្យាយាម ក៏ប៉ុន្តែមិនយកជម្រើសទាំងអស់នេះទេ ហើយយើងយកជម្រើសប្រព័ន្ធសោតទស្សន៍។ យើងខ្ញុំសូមបញ្ជាក់ថា បើអ៊ីចឹងមែន យើងត្រូវតែច្រានចោលសក្ខីកម្មរបស់សាក្សីរូបនេះ ដោយសារតែគាត់យុត្តិសាស្ត្របានបញ្ជាក់យ៉ាងច្បាស់ថា សក្ខីកម្មបែបនេះមិនមានទម្ងន់ ឬក៏មានទម្ងន់ស្រាល។

តាមអ្វីដែលយើងបានឃើញក្នុងថ្ងៃនេះ ខ្ញុំសូមអភ័យទោសផងដែរ ដោយសារតែយើងខ្ញុំមិនរៀបចំឲ្យបានភ្ជាប់ខ្លួន។ យើងខ្ញុំធ្វើយ៉ាងណាឲ្យអស់លោក លោកស្រីចៅក្រមបានដឹង។ នៅពេលដែលយើងមានបញ្ជីការងារ បញ្ជីរៀបរាប់ការងារដែលចង់ធ្វើនោះគឺខ្ញុំក៏រៀបចំដែរ បញ្ជីការងារអ៊ីចឹងហ៎ ពីរ-បីថ្ងៃគឺខ្ញុំអាចរៀបចំថា ខ្ញុំជាប់រវល់ធ្វើសក្ខីកម្ម ឬក៏ជាប់ទៅធ្វើការងារនៅកន្លែងផ្សេង។

ខ្ញុំសូមលើកឡើងថា យៀរនិន ត្រូវតែមកចូលខ្លួន ហើយគាត់បានបញ្ជាក់ហេតុផលហើយថា គាត់មិនទំនេរ។ ហេតុអ្វីបានជាយើងគិតថា ទោះបីការងារគាត់រវល់ គាត់មិនឲ្យគេជំនួសទៅ គាត់អាចមកផ្តល់សក្ខីកម្មនៅទីនេះ ឬក៏គាត់អាចមកផ្តល់សក្ខីកម្មនៅពេលក្រោយ។

[១៥:៣៧:៣៦]

នៅក្នុងសំណុំរឿង០០២/០១ នេះ សាក្សីគួរតែមកផ្តល់សក្ខីកម្ម ហើយយើងមិនគួរផ្តល់តាមសោតទស្សន៍នេះ សោតទស្សន៍នោះទេ លើកលែងតែមានលក្ខខណ្ឌបំពេញគ្រប់គ្រាន់។ យើងដឹងហើយថា គាត់មានមិត្តភក្តិ គាត់ស្គាល់ទីកន្លែងនេះ គាត់ដឹងថានៅទីនេះមានសុវត្ថិភាព គាត់មានគ្រួសារផងដែរ ដូច្នេះហើយថា តើហេតុអ្វីគាត់មិនមានលទ្ធភាពមកផ្តល់សក្ខីកម្មនៅទីនេះ? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីរបស់លោក នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងលើកឡើងសង្ខេបទេ ខ្ញុំនឹងលើកឡើងនៅសំអាងហេតុ ហើយនិងមូលដ្ឋានមួយចំនួន បាទមិនទាំងអស់នោះទេ។ ខ្ញុំចង់សង្កត់ថា កូនក្តីរបស់ខ្ញុំនេះគឺថា ប៉ែន យៀរនិននេះគឺថាសំខាន់ណាស់សម្រាប់កូនក្តីរបស់ខ្ញុំ។ ហើយយើងត្រូវការយោងទៅលើចម្លើយរបស់គាត់ជាច្រើននៅក្នុងរឿងក្តីរបស់យើងនេះ។

ខ្ញុំមានការអាក់អន់ណាស់ចំពោះការមិនបានយកចិត្តទុកដាក់ ខ្ញុំមិនយល់ថាហេតុអ្វីដែលគេយល់ឃើញថា វត្តមានរបស់គាត់ហាក់មិនសំខាន់នោះ។ គឺថាយើងមិនទាន់បានធ្វើវាឲ្យបានគ្រប់គ្រាន់ដើម្បីៗទាក់ទាញគាត់ឲ្យមានវត្តមាននៅទីនេះនៅឡើយទេ។

[១៥:៣៩:២៥]

ហើយខ្ញុំក៏មើលមិនឃើញថា ហេតុអ្វីក៏យើងមិនអាចហៅគាត់មកឆ្នាំ២០១៣ បាន បើសិនណាជាក្នុងឆ្នាំ២០១២ នេះមិនបាននេះ។ បើសិនជាគាត់មិនអាចៗលៃលកពេលវេលាដើម្បីធ្វើដំណើរមកកាន់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១២ បាន។ អ៊ីចឹង បើក្នុងឆ្នាំ២០១៣ ក៏យើងនឹងអាចអញ្ជើញគាត់បានដែរ។ តែជាជម្រើសនោះគឺថា សំណើសុំរបស់លោក អៀង សារី ក្រុម អៀង សារី គឺបើគាត់ពិតជាមិនអាចមកកាន់ប្រទេសកម្ពុជាបានមែននោះ យើងខ្ញុំប្រកាន់ជំហរថាដូច្នេះ គឺថាអ្នកណាម្នាក់ពីក្រុមមេធាវីការពារក្តីត្រូវអនុញ្ញាតឲ្យទៅទីនោះ ដើម្បីចោទសួរគាត់នៅទីនោះតែម្តង។ ដើម្បីវាយតម្លៃទៅលើប្រតិកម្មរបស់គាត់ហ្នឹង ក្នុងឋានៈជាសាក្សីនោះ។ ដូច្នេះ យើងខ្ញុំសូមគាំទ្រពេញទំហឹងទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តី អៀង សារី។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រុមមេធាវីការពាក្តីលោក ខៀវ សំផន!

[១៥:៤០:៥២]

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិននិយាយវែងទេ ក្រុមការពារក្តីលោក ខៀវ សំផន យើងគាំទ្រថាបើសិនជាលោក ប៉ែន យៀវនិន ត្រូវមកផ្តល់សក្ខីកម្មនៅទីនេះ គឺត្រូវមកផ្តល់សក្ខីកម្មនៅទីនេះតែម្តង។ ខ្ញុំៗគិតថា ជាការសំខាន់ណាស់ដែលយើងៗនៅពេលដែលយើងមានសាក្សី ហើយជាពិសេសគឺសាក្សីអ្នកជំនាញនោះយើងត្រូវតែមានវត្តមានគាត់។ ខ្ញុំគិតថា បុគ្គលទាំងអស់នៅក្នុងកន្លែងនេះគឺថាយើងមានកាតព្វកិច្ចវិជ្ជាជីវៈសំខាន់ណាស់ ខ្ញុំគិតថាបទពិសោធន៍អន្តរជាតិ នៅពេលដែលយើងៗត្រូវបានកោះហៅអំពីសំណាក់តុលាការមួយនោះ ជាពិសេសតុលាការអន្តរជាតិតែម្តងនោះ យើងអាចផ្តល់ទឡ្ហីករណ៍ទៅនិយោជករបស់យើងថា យើងមានការចាំបាច់ក្នុងការអវត្តមានដើម្បីមកចូលរួមដល់ការងារដ៏សំខាន់របស់តុលាការអន្តរជាតិនេះ។

[១៥:៤២:០៩]

ហើយនេះគឺថាចំពោះមុខតុលាការជាតិក៏ដូចគ្នាដែរ គឺយើងអាចផ្តល់ទឡ្ហីករណ៍នេះដែរ។ ហើយជាការពិតណាស់ដែលថា ខ្ញុំមិនអាច-- ក៏ដូចខាងសហភាគាខ្ញុំដែរ ថាខ្ញុំមិនអាចមិនសួរខ្លួនឯងថាហេតុអ្វីបានជាគាត់មិនទំនេរដល់មួយឆ្នាំពេញ ដែលថាគាត់ត្រូវបានស្នើពីខាងសហព្រះរាជអាជ្ញាផង ហើយខាងដើមបណ្តឹងរដ្ឋប្បវេណីផងថាគាត់ហ្នឹងជាអ្នកជំនាញ ធ្វើការរៀបផ្នាំមកហើយ ជាអ្នកជំនាញខាងប្រទេសកម្ពុជា ហើយប្រវត្តិសាស្ត្រកម្ពុជាដែល-- ហើយថាយើងនៅទីនេះ យើងជាតុលាការដែលទទួលបន្ទុកខាងពិនិត្យលើអង្គហេតុមួយ។ ហើយឥឡូវខ្ញុំនៅតែមិនយល់អីចឹងថា ហេតុអីបានគាត់មិនព្រមយកពេលទំនេរមកទៅនេះ។

[១៥:៤៣:០២]

ខាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ បានលើកឡើងថា ខាងប្រព័ន្ធសោតទស្សន៍នេះជាការគ្រប់គ្រាន់ហើយ។ ឧទាហរណ៍ ដូចនៅក្នុងសំណុំរឿង០០១ កន្លងមកហើយបានធ្វើហើយចំពោះអ្នកជំនាញពីររូប ហើយអស់លោកទាំងអស់គ្នានៅក្នុងសំណុំរឿង០០១ ដែរ អីចឹងខ្ញុំមិនបាច់និយាយអីឲ្យលម្អិតទេ ទាក់ទងទៅនឹងអ្នកជំនាញទាំងពីរនាក់នេះដែលបានផ្តល់សក្ខីកម្ម ដូចលោក ស្តេហ្វិន ហាស្ទែល

ដែលគាត់និយាយអំពីការលើកលែងទោស ហើយនិងលោក ហ្គោលស្តូន ដែលនិយាយអំពីការសំខាន់ក្នុងការពិរុទ្ធភាពរបស់ជនជាប់ចោទ នេះគឺជាប្រធានបទច្បាស់លាស់។ សក្ខីកម្ម ហើយនិងប្រធានបទដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះមិនអាចឱ្យយើងប្រៀបធៀបគ្នាទៅនឹងសក្ខីកម្មរបស់លោក ប៉ែន យៀរនិន ទេ។

[១៥:៤៤:00]

ហើយខ្ញុំសូមៗយោង-- លើកឡើងបញ្ហាមួយចំនួនទាក់ទងនឹងបញ្ហាដែលស្រាវជ្រាវ ហើយនិងបញ្ហាអង្គហេតុ ពីព្រោះថាមានឯកសារមួយចំនួនដែលបានបង្ហាញចំពោះមុខតុលាការ។ ហើយចំពោះឯកសារទាំងអស់នេះ ប្រហែលជាលោក ប៉ែន យៀរនិន មានការពន្យល់បន្ថែមលើអង្គហេតុ។ ដូច្នេះក្នុងករណីរឿងនេះ ហើយខ្ញុំគឺថាបញ្ហានេះជាការពាក់ព័ន្ធនឹងការគ្រប់គ្រងសម្ភារៈ ឯកសារ ឬក៏បញ្ចាំងឯកសារទាំងឡាយដើម្បីឱ្យគាត់ធ្វើការអត្ថាធិប្បាយ។ដូច្នេះគឺជាការចាត់ចែងរបស់តុលាការ។ ហើយដូចគ្នាផងដែរ គឺបញ្ហាមានពេលវេលាម៉ោងខុសគ្នានៅអាមេរិក ហើយនៅស្រុកខ្មែរនេះជាបញ្ហាដែលយើងទាំងអស់គ្នាដឹងហើយ។ គឺថា បានន័យថា កំហុសគ្នាដល់ទៅពីរម៉ោង។ ដូច្នេះគឺថាវាមានការលំបាកក្នុងការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នេះ។ ខ្ញុំដឹងថា មិនមែនជាការងាយស្រួលនោះទេ ពីព្រោះថានៅក្នុងក្របខ័ណ្ឌនៃវគ្គមួយយើងនេះ គឺថាយើងបានជួបបញ្ហាប្រភេទហ្នឹងហើយ នៅពេលដែលយើងបានស្តាប់សក្ខីកម្មតាមរបៀបនេះនោះ។ ដូច្នេះខ្ញុំគិតថា ជាការសំខាន់ក្នុងការទទូចសុំឱ្យលោក យៀរនិន រកពេលវេលាទំនេរបាន គឺថាយើងជាតុលាការអន្តរជាតិមួយដែរ អ៊ីចឹងយើងមានអាណត្តិពិសេសមួយ។ យើងគិតថាជាការសំខាន់ណាស់ បើផ្នែកនិមិត្តរូបនោះ គឺថា ឱ្យលោក ប៉ែន យៀរនិន មកផ្តល់សក្ខីកម្មនៅទីនេះ។ ហើយជាពិសេស គាត់គឺថាអ្នកជាអ្នកជំនាញ គាត់មិនមែនជាអ្នកសាក្សីទេ។ អ៊ីចឹងជាការសំខាន់ណាស់សម្រាប់តុលាការ ដើម្បីធ្វើការវាយតម្លៃលើភាពគួរឱ្យជឿបានទៅលើអ្វីដែលគាត់និយាយនោះ។

[១៥:៤៦:០៧]

ខ្ញុំនឹងបញ្ចប់ជាមួយនឹងចំណុចមួយ គឺថាបើសិនជាអង្គជំនុំជម្រះគ្រោងធ្វើតាមសោតទស្សន៍នេះ យើងក៏សូមឱ្យមេធាវី ខៀវ សំផន អាចទៅសម្ភាសគាត់ផ្ទាល់ ជួបគាត់ផ្ទាល់ សួរផ្ចាញ់គាត់នៅនឹងកន្លែង ដើម្បីឱ្យគោរពសិទ្ធិការពារខ្លួនរបស់ភាគីការពារក្តី។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្ត-- បាទសូមអញ្ជើញក្រុម-- លោកមេធាវីជាតិការពារក្តីឲ្យលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមមានយោបល់បន្ថែមទៅលើសហភាគារបស់ខ្ញុំ ទាក់ទងទៅនឹងចាំបាច់នៃវត្តមានរបស់សាក្សីជំនាញ ប៉ែន យៀរនិន ដែលត្រូវមកបង្ហាញខ្លួនចំពោះមុខអង្គសវនាការ។

[១៥:៤៧:០៨]

យើងខ្ញុំយល់ឃើញថា វត្តមានរបស់លោក ប៉ែន យៀរនិន គឺមានប្រយោជន៍សំខាន់ណាស់សម្រាប់ដំណើរការនីតិវិធីនេះ។ ហើយខ្ញុំមើលមិនឃើញថា ហេតុអ្វីបានជាលោក ប៉ែន យៀរនិន បដិសេធមិនព្រមមកដោយផ្ទាល់នោះទេ។ ខ្ញុំយល់ឃើញថា មូលហេតុដែលលោកបានលើក ដើម្បីគេចវេះពីការចូលខ្លួនមកបំភ្លឺក្នុងតុលាការ ដែលតំណាងសហព្រះរាជអាជ្ញាបានបញ្ជូននៅរសៀលម៉ោងបួនជាងនេះ វាមិនគ្រប់គ្រាន់សម្រាប់ឲ្យតុលាការទទួលស្គាល់ថា គាត់មិនចាំបាច់មកបង្ហាញនៅចំពោះមុខសវនាការដោយគ្រាន់តែធ្វើការបង្ហាញតាមរយៈ *វីដេអូលីង* នោះ។

[១៥:៤៧:៥១]

អ្វីដែលខ្ញុំមើលឃើញនេះ គឺការងាររបស់គាត់ជាសាស្ត្រាចារ្យម្នាក់ ហើយគាត់ជាអ្នកបង្រៀនកែលំហាត់សិស្សរបស់គាត់។ អានេះវាជាកិច្ចការសាមញ្ញបំផុត ដូចថាជាការងារអាជីពប្រចាំថ្ងៃរបស់គាត់។ បើសិនជាយើងផ្អែកលើមូលដ្ឋានថា គាត់មមាញឹក គាត់រវល់ក្នុងកិច្ចការប្រចាំថ្ងៃបែបនេះ ហើយអនុញ្ញាតមិនបាច់ឲ្យគាត់មកបំភ្លឺចំពោះមុខសវនាការនាពេលនេះទេ។ អ៊ីចឹងមានន័យថា មានសាក្សីជាច្រើនទៀតដែលមិនចាំបាច់មកបង្ហាញមុខចំពោះមុខសវនាការ ឬមិនចាំបាច់មកឆ្លើយបំភ្លឺចំពោះសវនាការដោយសារតែបញ្ហារវល់ក្នុងជីវភាពប្រចាំថ្ងៃរបស់គាត់។

ដូច្នេះ ការបង្រៀន ដូចខ្ញុំបានស្តាប់ឮមេធាវីខាងដើមមានប្រសាសន៍ច្រើនហើយថា អាចរកអ្នកជំនួសបាន។ ក៏ប៉ុន្តែអ្នកដែលមកឆ្លើយបំភ្លឺចំពោះមុខអង្គសវនាការនាពេលនេះ គឺមិនអាចរកជំនួសគាត់បានទេ គឺគាត់ត្រូវតែអញ្ជើញមកដោយខ្លួន។ ហើយចំណុចនេះ ក្នុងនីតិវិធីព្រហ្មទណ្ឌរបស់យើងក៏អនុញ្ញាតឲ្យតុលាការអាចបង្គាប់ឲ្យគាត់មកបំភ្លឺនៅចំពោះមុខអង្គសវនាការនេះបានដែរ។

ម្យ៉ាងទៀតបើយើងក្រឡេកមើលទៅលើជំនាញរបស់គាត់ផ្នែកប្រវត្តិសាស្ត្រ ហើយគាត់ជាអ្នក

ស្រាវជ្រាវផ្នែកទាក់ទងទៅនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិនេះទៀត គឺទាក់ទងទៅនឹងកម្មវិធីប្រល័យពូជសាសន៍។ អ៊ីចឹងមានន័យថា វារឹតតែសំខាន់សម្រាប់គាត់ ដែលត្រូវមានវត្តមាននៅទីនេះ ពីព្រោះថាការមកបង្ហាញខ្លួននៅទីនេះ វាជាកាតព្វកិច្ចរបស់គាត់ផង ហើយក៏ជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវរបស់គាត់ផងដែរ។ វាទាក់ទងទៅការងាររបស់គាត់ទៀត។

[១៥:៤៩:៤៤]

ដូច្នេះកត្តាដែលៗជំរុញឲ្យគាត់មកនេះ វាចាំបាច់ខ្លាំងណាស់។ វាមានភាពចាំបាច់សំខាន់ខ្លាំងណាស់ ហើយមិនមានមូលហេតុអ្វីដែលគាត់ត្រូវគេចវេះមិនចូលរួមនីតិវិធីដោយផ្ទាល់ ដោយលើកថាជាប់រវល់នោះទេ។

ទាក់ទងទៅនឹងវិធាន២៦ របស់យើងដែលអនុញ្ញាតឲ្យមានធ្វើជា *វីដេអូលីង* គឺថានៅក្នុងចំណុចចុងក្រោយ ខ្ញុំបាទសូមអានជូន "បច្ចេកវិទ្យានេះ មិនត្រូវអនុញ្ញាតឲ្យប្រើទេ ប្រសិនបើធ្វើឲ្យមានអន្តរាយធ្ងន់ធ្ងរ ឬមិនស្របទៅនឹងសិទ្ធិការពារខ្លួន"។ បាទ ក្នុងចំណុចនេះ គឺបានន័យថាតុលាការអាចបដិសេធចំពោះសំណើសុំធ្វើឆ្លើយបំភ្លឺតាមរយៈវីដេអូលីងនេះ ដោយហេតុថា វាមានការប៉ះពាល់ដល់ការការពារ។ អ៊ីចឹង ខ្ញុំបាទសូមលើកជូនថា តើអ្វីទៅដែលជាការប៉ះពាល់ ដល់ការការពារក្នុងករណីនេះ។ យើងឃើញនៅក្នុងប្រវត្តិរូបសង្ខេបរបស់គាត់ ផ្សព្វផ្សាយជាសាធារណៈ តាមអ៊ិនធើណែត។ បាទ យើងអាចរកឃើញ គឺគាត់ស្រាវជ្រាវទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍នេះ ច្រើនណាស់ អម្បាញ់មិញលោកមេធាវី ម៉ែខល កាណាវាស មិនតិចជាង៥០ទេ។ ប៉ុន្តែខ្ញុំបានឃើញនៅក្នុងឯកសារនេះ ថាជិត១០០ឯណោះ ជិត១០០អត្ថបទដែលគាត់សរសេរ។ ហើយគាត់ត្រូវបានគេចាត់ទុកថា ជាអ្នកជំនាញអំពីអំពើប្រល័យពូជសាសន៍កម្ពុជានេះទៀត គឺទាក់ទងនឹងខ្មែរក្រហម។ អត្ថបទរបស់គាត់ភាគច្រើន គឺធ្វើសេចក្តីសន្និដ្ឋានវាយតម្លៃថារបបកម្ពុជាប្រជាធិបតេយ្យ គឺជារបបប្រល័យពូជសាសន៍។ ដូច្នេះ ការធ្វើសេចក្តីសន្និដ្ឋាននេះ វាធ្វើឲ្យប៉ះពាល់ដល់ការការពារយ៉ាងខ្លាំងដែលតម្រូវឲ្យលោក ប៊ែន ឃៀរនិន ត្រូវតែមកឆ្លើយបំភ្លឺចំពោះមុខដោយផ្ទាល់ ដើម្បីឲ្យជនជាប់ចោទ ក៏ដូចមេធាវីការពារ ធ្វើការតទល់។ បាទ សូមអរគុណ។

[១៥:៥២:០៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ ជាបន្តនេះ សូមជាវេទិកានៃការឆ្លើយតបទៅនឹងបញ្ហាទាំងពីរ ដែលលើកឡើង

និងអះអាងដោយភាគីម្ខាងទៀត ហើយអង្គជំនុំជម្រះសូមជម្រាបថា សហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានពេលវេលាម្ភៃនាទី។ ហើយការបែងចែកអាស្រ័យលើក្រុមទាំងពីរ បែងចែកពេលវេលានេះ។ ហើយអង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅសហព្រះរាជអាជ្ញាមុនប្រសិនបើសហព្រះរាជអាជ្ញាមានបំណងធ្វើការឆ្លើយតបទៅនឹងការលើកឡើង និងអះអាងរបស់ភាគីក្រុមមេធាវីការពារក្ដី។

សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។

ខ្ញុំសូមពេលបន្តិច ដើម្បីបកស្រាយឆ្លើយតបទៅនឹងអ្វីដែលលោកមេធាវី-- ក្រុមមេធាវីការពារក្ដីបានលើកឡើង។ តាមពិត លោក ប៉ែន យៀរនិន គាត់មិនមានចេតនាគេចវេះ ដូចលោកមេធាវីបានលើកឡើងនោះទេ។ ប៉ុន្ដែគាត់រវល់ ការរវល់របស់គាត់ គឺចាំបាច់នៅក្នុងការងារប្រចាំថ្ងៃក្នុងអាជីពរបស់គាត់ជាពិត។ អ៊ីចឹង យើងប្រើប្រព័ន្ធសោតទស្សន៍តាមការស្នើរបស់ព្រះរាជអាជ្ញាគឺជាការត្រឹមត្រូវ។ ចំពោះផលប្រយោជន៍ គឺបែបមានទាំងអស់គ្នាសម្រាប់ភាគី។ ហើយលោកខាងមេធាវីការពារក្ដី លោកអាចចោទសួរតាមរយៈប្រព័ន្ធសោតទស្សន៍បាន-- តាមរយៈប្រព័ន្ធអេឡិចត្រូនិចបាន តាមប្រព័ន្ធកន្លែងអាយធីទំនើបនេះ។

[១៥:៥៣:២៥]

អ៊ីចឹង គឺក្នុងរយៈពេលនេះ ខណៈពេលនេះ យើងប្រើប្រាស់លទ្ធភាពនៃពេលវេលាគឺដើម្បីផលប្រយោជន៍នៃយុត្តិធម៌ឲ្យបានលឿន ឲ្យឆាប់បំផុត។ ប្រសិនបើ យើងចាំដល់ពេលដែលគាត់អាចអញ្ជើញមកបាន នៅទីនេះ ២០១៣ គឺមានទៅដល់ផលប៉ះពាល់ដល់ពេលវេលាដែលយើងចង់ពន្លឿននីតិវិធីសវនាការនៅពេលនេះ។ អ៊ីចឹង ការប្រើប្រាស់ប្រព័ន្ធនេះ គឺជាប្រព័ន្ធល្អ ដែលសហព្រះរាជអាជ្ញាយល់ឃើញថាគប្បីប្រើ ហើយកន្លងមក យើងបានប្រើប្រាស់ប្រព័ន្ធរួចទៅហើយ។ ហើយរឿងនេះគឺ មិនប៉ះពាល់ទៅដល់ភាពអន្តរាយនៃនីតិវិធី ឬក៏ប៉ះពាល់ភាពអន្តរាយដទៃទៀតទេ។

អ៊ីចឹង ខ្ញុំស្នើសុំដោយទទូច សុំឲ្យអង្គជំនុំជម្រះមេត្តាទទួលយកនូវសំណើសុំរបស់សហព្រះរាជអាជ្ញាក្នុងន័យនៃការពារ និងពន្លឿនលឿននៃនីតិវិធីនេះ ឲ្យបានឆាប់ដើម្បីផលប្រយោជន៍នៃយុត្តិធម៌ ធ្វើយ៉ាងម៉េចឲ្យរឿងក្ដីនេះ ដំណើរការទៅដោយប្រកបដោយប្រសិទ្ធភាព និងរលូន ហើយ

គ្មានផលប៉ះពាល់អ្វីកើតឡើងទៀតទេ។ បាទ សូមអរគុណ ហើយដោយសារពេលវេលាមានកម្រិត ខ្ញុំសូមឲ្យសហការីរបស់ខ្ញុំបន្ថែមទៀត នូវអ្វីដែលគាត់ចង់និយាយ។

សូមអរគុណលោកប្រធាន។ សូមអរគុណ។

[១៥:៥៤:៣៤]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្វាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមនិយាយដោយខ្លី។ ជាដំបូង ខ្ញុំកត់សម្គាល់ពីភាគីបដិបក្ខអំពីសារៈសំខាន់នៃវត្តមានរបស់អ្នកជំនាញរូបនេះ គឺថាយើងត្រូវស្តាប់សក្ខីកម្មគាត់ដោយផ្ទាល់។ មេធាវីខាងលោក កាណាវ៉ាស ហើយនិងខាង ខៀវ សំផន បានយល់ឃើញថាមិនមានហេតុផលជាក់លាក់ដែលបញ្ជាក់ថា អ្នកជំនាញនេះ មិនអាចមកបាននោះទេ។

ដូច្នេះខ្ញុំចង់បញ្ជាក់ជូនថា វាជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការកំណត់អំពីបញ្ហានេះ គឺមិនមែនភាគីជាអ្នកសម្រេចទេអំពីលក្ខណៈវិនិច្ឆ័យដែលត្រូវបំពេញនោះ អ្វីទាំងអស់គឺស្រេចទៅលើអង្គជំនុំជម្រះ។

ខ្ញុំចង់គូសបញ្ជាក់នូវចំណុចមួយ ដែលខ្ញុំមិនទាន់បានលើកនោះ ក៏ប៉ុន្តែមេធាវី កាណាវ៉ាស បានបន្ទោសដល់ខាងយើងខ្ញុំ ថាមិនបានទទួចឲ្យបានគ្រប់គ្រាន់ធ្វើយ៉ាងម៉េចឲ្យលោក ប៉ែន យៀវនិន នោះផ្តល់នូវការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីភាពទំនេររបស់គាត់ ហើយគាត់ជាប់ភាពមមារញឹកជាប់ក្នុងអាជីពរបស់គាត់ក្នុងរយៈពេលនេះ។

[១៥:៥៥:៥១]

យើងខ្ញុំបានធ្វើទៅតាមអ្វីដែលលោកប្រធាន-- អង្គជំនុំជម្រះបានស្នើសុំឲ្យយើង ដើម្បីបំពេញទៅតាមការស្នើសុំរបស់អង្គជំនុំជម្រះ។ ក៏ប៉ុន្តែក្នុងពេលទន្ទឹមគ្នានេះ លោក កាណាវ៉ាស បានលើកទឡ្ហីករណ៍ជាលាយលក្ខណ៍អក្សរនៅក្នុងកថាខណ្ឌ១៤ គាត់និយាយថា មេធាវីការពារក្តីឆ្លៀតឱកាសនេះក្នុងការស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងក្នុងការចេញនូវដីកាមួយ ដែលហាមឃាត់រាល់ការពាក់ព័ន្ធ-- រាល់ការទំនាក់ទំនងរវាងភាគីតែម្ខាងជាមួយនឹងសហព្រះរាជអាជ្ញា ហើយជាមួយនឹងអ្នកជំនាញ។ ហើយនៅចុងខែកុម្ភៈ យើងទទួលបាននូវអត្ថបទនៃទឡ្ហីករណ៍ជាលាយលក្ខណ៍អក្សរនេះ ក៏ប៉ុន្តែមេធាវីការពារក្តីបានចាត់ទុកការទំនាក់ទំនងនេះថាជាការទំនាក់ទំនងជាមួយនឹងភាគីតែមួយ ហើយបានបន្ទោសទៀតថា យើងបានទំនាក់ទំនងជាមួយអ្នកជំនាញ។ ក៏ប៉ុន្តែនេះគឺជាអាណត្តិដែលប្រគល់ឲ្យយើងដោយ

អង្គជំនុំជម្រះឲ្យយើងធ្វើការទាក់ទងជាមួយនឹងលោក ប៉ែន យៀរនិន ដើម្បីស្វែងរកនូវបែបបទដែលអនុញ្ញាតឲ្យគាត់ធ្វើសក្ខីកម្មនៅចំពោះមុខតុលាការ។ នេះមិនមែនជាការទំនាក់ទំនងជាមួយនឹងភាគីតែម្ខាងដោយការសម្ងាត់នោះទេ។ វាជាការផ្ដល់អាណត្តិដោយតុលាការ។

លោក កាណាវាស ក៏បាននិយាយថា នៅឆ្នាំ--

[១៥:៥៧:០៩]

**ប្រធានអង្គជំនុំ៖**

លោក កាណាវាស រង់ចាំការជំទាស់របស់ភាគីម្ខាងទៀតចប់សព្វគ្រប់សិន ព្រោះលោកមានពេលវេលាដូចគ្នានឹងពេលវេលារបស់ភាគីខាងតំណាងអយ្យការជាមួយនឹងសហមេធាវីនាំមុខដែរ។

សូមបន្តទៀត!

**លោក វាំងសង់ វ៉ាយដ៍ ដេស្បាឯលៈ**

សូមអរគុណលោកប្រធាន!

លោក កាណាវាស បាននិយាយថានៅក្នុងឆ្នាំ២០១១ យើងបានទំនាក់ទំនងជាមួយនឹងអ្នកជំនាញហើយបាន គឺគាត់បាននិយាយថា សហព្រះរាជអាជ្ញាបានទំនាក់ទំនងជាមួយនឹងអ្នកជំនាញ។ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ថា យើងខ្ញុំមិនបានទំនាក់ទំនងជាមួយនឹងសាស្ត្រាចារ្យ ប៉ែន យៀរនិន នៅឆ្នាំ២០១១ នោះទេ គឺថារហូតទាល់តែអង្គជំនុំជម្រះប្រគល់បេសកកម្មឲ្យយើងទាក់ទងគាត់ ទើបបានយើងទាក់ទងគាត់។

[១៥:៥៨:១២]

ដូច្នេះ គឺតាមវិធាននោះ គឺថាយើងមិនអាចទាក់ទងជាមួយនឹងសាក្សី ឬក៏អ្នកជំនាញនោះទេ បើតាមវិធានរបស់យើងនោះ។ គឺទាល់តែមានការអនុញ្ញាតពីអង្គជំនុំជម្រះ។ ហើយគាត់បាននិយាយថានៅវេលាម៉ោង៩យប់នោះ គឺថាលោកសាស្ត្រាចារ្យគាត់នឹងអស់កម្លាំងហើយ ពិតជាអាចកើតមានមែនគឺថាគាត់អាចហត់នៅពេលម៉ោងនោះ។ ប៉ុន្តែយើងមិនបានសំណើ យើងមិនបានស្នើឲ្យគាត់ធ្វើសក្ខីកម្មនៅម៉ោង៩យប់ទេ គឺគាត់ទេ លោក ប៉ែន យៀរនិន ទេ គាត់ជាអ្នកស្នើសុំមកយើងវិញ ថាតើគាត់អាចផ្ដល់សក្ខីកម្មឲ្យដល់ម៉ោង៩យប់ ពីព្រោះដោយសារមានគន្លាតការងារ គន្លាតពេលវេលា១២ម៉ោង រវាងកម្ពុជា និងអាមេរិកនោះ។ ដូច្នេះបញ្ហានេះ គឺខាង ប៉ែន យៀរនិន ទេជាអ្នកស្នើនោះ។

[១៥:៥៩:០៩]

ដូច្នេះ គឺថាពិតណាស់ មិនមានអ្នកណាអាចជំនួស ប៉ែន យៀរនិន បានទេ ហើយយើងបានលើកឡើងអំពី ក្រេក អេតធេសាន់។ ចុះហេតុអីបានជាលោក កាណាវាស បានគិតជំនួសទៅលើសហព្រះរាជអាជ្ញាទៅវិញនោះ ថាមិនមានអ្នកណាជំនួសគាត់បាននោះ។ ដូច្នេះគាត់នឹងអាចនិយាយថា អ្នកជំនាញនេះមិនសមស្របទេ ត្រូវជំនួសដោយអ្នកផ្សេងទៀតនោះ។ គឺថាអ្វីដែលគាត់លើកឡើងហ្នឹង គឺថាមិនមានមូលដ្ឋាននោះទេ។ នេះគឺជាអ្នកជំនាញរបស់អង្គជំនុំជម្រះ សូមបញ្ជាក់ម្តងទៀត មិនមែនជាអ្នកជំនាញរបស់សហព្រះរាជអាជ្ញានោះទេ។

ពាក់ព័ន្ធទៅនឹងរឿងក្តីរបស់ ប៊ើនីម៉ាន់ នៅថ្ងៃទី៩ មីនា ឆ្នាំ២០១១ ខ្ញុំបាទសូមបញ្ជាក់ថាលក្ខណៈវិនិច្ឆ័យឆន្ទៈនេះ មិនមែនជាលក្ខណៈវិនិច្ឆ័យដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក យើងនេះទេ។ លក្ខណៈវិនិច្ឆ័យនៅតុលាការ យូហ្គោស្លាវី មានលក្ខណៈផ្សេងពីនេះ គឺមានលក្ខណៈតឹងតែង ជាងអ្វីដែលអនុវត្តនៅចំពោះមុខ អ.វ.ត.ក នេះ។ ហើយអាចឃើញនៅក្នុងវិធាន២៦(១) ផងដែរ គឺអាចចែងអំពីលក្ខខណ្ឌពិសេសដែលអាចបញ្ជាក់ថា អាចមិនមានការធ្វើសក្ខីកម្ម គឺថាអាចផ្តល់សក្ខីកម្មតាមរយៈវីដេអូបាន។

នៅចំពោះមុខតុលាការមិនអចិន្ត្រៃយ៍អន្តរជាតិពីរ គឺមានលក្ខខណ្ឌដែលអាចជំរុញ ឬក៏បង្ខំឱ្យសាក្សី ឬក៏អ្នកជំនាញក្នុងការធ្វើសក្ខីកម្ម ឬក៏មកបង្ហាញខ្លួន ហើយស្ថានភាពនៅនេះ នៅទីនេះ គឺផ្សេងពីគ្នា នៅទីនេះយើងមិនចាប់បង្ខំបានទេ មិនដូចនៅតុលាការផ្សេងទៀតនោះទេ។ ហើយពាក់ព័ន្ធទៅនឹងសុចរិតភាពរបស់តុលាការនៅទីនេះ យើងយល់ថានៅទីនេះគឺយើងស្ថិតនៅក្នុងបន្ទប់តែមួយ យើងអាចមើលឃើញភាគីទាំងអស់ យើងស្ថិតនៅកន្លែងដូចគ្នា។ ប៉ុន្តែអ្នកជំនាញនេះ គឺថាគាត់បានដឹងច្បាស់អំពីអ្វីដែលគាត់ត្រូវនិយាយទៅកាន់នោះ។

[១៦:០១:២១]

ដូច្នេះ គាត់ដឹងច្បាស់ណាស់ថាវាគឺជាសវនាការជាឱឡារិក ជាអធិកអធមនោះ វាមិនមែនជាការសន្ទនាគ្នាឯក-- រវាងបុគ្គលឯកជននោះទេ។ នៅក្នុងកថាខណ្ឌ២៦ នៃចម្លើយតបរបស់លោក អៀង សារី បាននិយាយដូចតទៅនេះ មានការដកស្រង់ "គេអាចកើតមានបានថា អ្វីដែលសាក្សីដែលគាត់និយាយឯកជន គឺថាចួនកាលទៅគាត់មានការអៀនខ្មាស ក្នុងការមិននិយាយក្នុងសវនាការសាធារណៈ"។ ដូច្នេះក្នុងករណីនេះវាមិនមែននេះទេ គាត់ដឹងច្បាស់ណាស់ពីអ្វីដែលគាត់អាចនិយាយនោះ។ ហើយការបង្ហាញតាមវីដេអូ មិនមែន-- ក៏មិនជាការសន្ទនាគ្នារបៀបឯកជននោះដែរ។

[១៦:០២:០៥]

ដូច្នេះខ្ញុំសូមបញ្ចប់ត្រង់ចំណុចនេះ ហើយយើងសូម-- ខ្ញុំរក្សាទុកនូវអ្វីដដែល ដែលខ្ញុំ ដែលយើងខ្ញុំបានលើកឡើង ហើយសូមយោងទៅលើអ្វីដែលយើងបានដាក់ជាលាយលក្ខណ៍អក្សររួចទៅហើយនោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំគ្រាន់តែប្រើពេលវេលាតិចតួចបំផុត។ ខ្ញុំគិតថាមិនចាំបាច់ឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីនោះទេ។ មិនមែនដោយសារថា យើងមានឆន្ទៈនិយាយដូច ជាន់គ្នាទៅលើសហព្រះរាជអាជ្ញានោះទេ យើងគ្រាន់តែចង់បើករង់ក្រចកតូចតែប៉ុណ្ណោះ។ ខ្ញុំគិតថា ការកត់សម្គាល់នៅក្នុងសវនាការបែបនេះ គឺមិនត្រឹមត្រូវនោះទេ ហើយវាមិនសមរម្យនោះទេចំពោះយើង។

[១៦:០៣:០៤]

ខ្ញុំគិតថា គាត់មានឆន្ទៈក្នុងការនិយាយថា ហាក់ដូចជាដើមបណ្តឹងរដ្ឋប្បវេណីនោះមិនមានតួនាទីនៅទីនេះអ៊ីចឹង។ ចំពោះខាងយើងខ្ញុំវិញ ខ្ញុំមិនចង់ឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីទេ។ មិនមែនដោយសារតែខ្ញុំមិនឮអំពីទឡ្ហីករណ៍ដែលទាមទារឲ្យការឆ្លើយតបនោះទេ។

**ប្រធានអង្គជំនុំ៖**

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីទាំងបីក្រុម។ មានពេលវេលា ២០ នាទីសម្រាប់ធ្វើការឆ្លើយតបចុងក្រោយបង្អស់ទៅលើបញ្ហាទាំងពីរ។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមចាប់ផ្តើមឆ្លើយតបទៅនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីជាទូទៅ គឺគាត់តែងតែយកតាមជំហររបស់សហព្រះរាជអាជ្ញា។

[១៦:០៤:០១]

អ្វីដែលខ្ញុំចាំ គឺយើងខ្ញុំសូមលើកឡើងថា ភាគីទាំងពីរនេះ គឺលើកឡើងទឡ្ហីករណ៍ដូចគ្នា។ ហើយពួកគាត់មានការតំណាងផលប្រយោជន៍ផ្សេងគ្នា ក៏ប៉ុន្តែពួកគាត់តែងតែគាំទ្រគ្នាទៅវិញទៅមក ហើយខ្ញុំវាអាស្រ័យទៅលើ ខ្ញុំគិតថាវាអាស្រ័យទៅលើមេធាវីនីមួយៗ។ ប៉ុន្តែខ្ញុំសូមលើកឡើងថា មេធាវីតំណាង

ដើមបណ្ដឹងរដ្ឋប្បវេណីតែងតែទទួលស្គាល់ និងគាំទ្រទៅលើជំហររបស់សហព្រះរាជអាជ្ញា។ បើអ៊ីចឹង គឺអ៊ីចឹងចុះ។

នៅពេលនេះ គឺខ្ញុំសូមឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។ យើងខ្ញុំបានបញ្ជូនលិខិតមួយច្បាប់ ប្រហែលជានៅថ្ងៃ៩ ឬក៏នៅថ្ងៃ១០ ហើយបន្ទាប់មកនៅថ្ងៃ១៣ ខែមីនា ឆ្នាំ២០១២ បន្ទាប់នៅថ្ងៃ១៣ មីនា ឆ្នាំ២០១២ យើងបានបញ្ជូនលិខិតទៅមន្ត្រីច្បាប់ជាន់ខ្ពស់។ ហើយនៅក្នុងលិខិតនោះ យើងបានកត់សម្គាល់ថា សហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាត ឲ្យទាក់ទងជាមួយនឹងលោកសាស្ត្រាចារ្យ ឃៀរនិន។ នេះគឺជាការធ្វើទំនាក់ទំនងតែភាគីម្ខាង ដែលយើងអាចកំណត់សញ្ញាណអ៊ីចឹង។ យើងមិនមែនជាភាគីចូលរួមក្នុងការទាក់ទងហ្នឹង។ ដូច្នេះបានន័យថា យើងខ្ញុំមិនទទួលបានការអនុញ្ញាត។ ការអនុញ្ញាតដូច្នោះគឺក្នុងគោលបំណងជាក់លាក់។ ហើយយើងក៏មិនធ្វើការអះអាងថា សហព្រះរាជអាជ្ញាបំពេញហួសតួនាទីរបស់ខ្លួនផងដែរ។ ក៏ប៉ុន្តែនៅក្នុងលិខិតដដែល ខ្ញុំលើកឡើងថាក្នុងពេលអនាគត ការទំនាក់ទំនងណាក៏ដោយនាពេលក្រោយរវាងសាស្ត្រាចារ្យ ឃៀរនិន និង វេ.ស៊ូ និងសាលាដំបូងគួរតែបញ្ជាក់ឲ្យយើងខ្ញុំដឹង។ ដូចដែលខ្ញុំបានបញ្ជាក់ពីមុន យើងខ្ញុំចង់ជាភាគីម្នាក់ផងដែរ តំណាងទៅដល់មេធាវីការពារក្ដី ជាពិសេសចង់ភាគីដែលចង់ចូលជាភាគីដែលពិភាក្សាក្នុងចំណោម ខេលី, ស្មីត,និង ឃៀរនិន ដោយសារតែហេតុផលមួយចំនួន។

[១៦:០៦:១២]

ដោយសារតែ គឺគេលើកឡើងទៅលើបញ្ហាមួយចំនួន។ លោកសាស្ត្រាចារ្យ ឃៀរនិន បានស្នើសុំឲ្យធ្វើការទំនាក់ទំនងជាក់ស្ដែងពួកគាត់បញ្ជូន-- លោកបានបញ្ជូននូវលិខិតមួយយ៉ាងជាក់លាក់ ហើយមានការកែប្រែ។ ខ្ញុំដឹងថា ដូចមេធាវីផ្សេងបានបញ្ជាក់ សហព្រះរាជអាជ្ញានៅទីនេះហាក់ដូចជា បានសង្កត់បញ្ជាក់ទៅលើចំណុចសំខាន់នៃសក្ខីកម្មរបស់លោក ឃៀរនិន។ យើងដឹងថាគាត់រវល់ លោកឆេនដ៍ល័រ ជាគ្រូបង្គោល ក៏ប៉ុន្តែគាត់នៅតែរកពេលវេលាមកផ្ដល់សក្ខីកម្ម ផ្ដល់ភស្តុតាងទៅលើបញ្ហាដែលសំខាន់គាត់បានសរសេរ។ យើងខ្ញុំសូមលើកឡើងថា អ្វីដែលសហព្រះរាជអាជ្ញាអាចយកពីលោកឃៀរនិន គឺដោយសារតែសហព្រះរាជអាជ្ញាបានសង្កត់ធ្ងន់ បញ្ជាក់ឲ្យលោក ឃៀរនិន នោះ បញ្ជាក់ថាតើថ្ងៃទំនេររបស់លោកនៅថ្ងៃណា? ហើយថ្ងៃរវល់នៅថ្ងៃណា? ប្រសិនបើខ្ញុំមានលិខិតទំនាក់ទំនងទាំងអស់នេះ ខ្ញុំមិនធ្វើតវ៉ានោះទេ ក៏ប៉ុន្តែយើងខ្ញុំមាននូវលិខិតទាំងអស់នេះ យើងខ្ញុំដឹងថា អង្គជំនុំជម្រះបានផ្ដល់ការអនុញ្ញាតដល់សហព្រះរាជអាជ្ញាធ្វើការទាក់ទងជាមួយនឹងលោក ឃៀរនិន។ ក៏ប៉ុន្តែនៅពេល

ណាមួយក៏ដោយ យើងកំពុងនិយាយថា មុនពេលដែលសហព្រះរាជអាជ្ញាទទួលរឿងក្តី សហព្រះរាជអាជ្ញា គឺប្រហែលជា-- នៅពេលដែលសហចៅក្រមស៊ើបអង្កេតទទួលរឿងក្តី ប្រាកដជាគាត់នឹងធ្វើការទាក់ទងជាមួយនឹងលោក ឃៀរនិន អំពីថា តើគាត់មានឆន្ទៈមកផ្តល់សក្ខីកម្មដែរឬទេ?

[១៦:០៨:១២]

នៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរគឺប្រហែលជាមានការលើកឡើងដោយប្រយោល ឬក៏ដោយផ្ទាល់ទៅលើការទាក់ទងជាមួយនឹងលោក ឃៀរនិន។ អ្វីដែលពាក់ព័ន្ធនៅក្នុងការពិភាក្សានៅក្នុងថ្ងៃនេះ គឺលោក ឃៀរនិន ត្រូវបានចាត់ទុកថាជាសាក្សីរបស់សហព្រះរាជអាជ្ញា។ ហើយសហព្រះរាជអាជ្ញាចាត់ទុកនិងទទួលស្គាល់លោក ឃៀរនិន ជាសាក្សី។ ហើយគឺគាត់មិនអាចថាមានសាក្សីណាជំនួសលោក ឃៀរនិន នោះទេ ខ្ញុំមិនមែនស្នើដូច្នោះនោះឡើយ។ ក៏ប៉ុន្តែខ្ញុំគ្រាន់តែបញ្ជាក់ថា លោក ឃៀរនិន មិនមែនតែជាមនុស្សបុគ្គលមួយរូបអាចផ្តល់តែសក្ខីកម្មហ្នឹងទេ គឺមានបុគ្គលផ្សេងដែលមាននៅក្នុងប្រទេស-- អាចនៅក្នុងប្រទេសនេះ អាចផ្តល់ជាភស្តុតាង សក្ខីកម្មទៅលើវិសាលភាពនៃសំណុំរឿង ០០២/០១។ នេះគឺជាលក្ខណៈវិនិច្ឆ័យមួយទៀត ដែលវាអាចប៉ះពាល់ទៅដល់ភាគីស្នើសុំសាក្សី ជាពិសេសសូមដាក់បញ្ចូលនូវសក្ខីកម្មរបស់សាក្សី។

[១៦:០៩:២៥]

យើងខ្ញុំសូមស្នើថា វាជាជម្រើសមួយផ្សេង ក៏ប៉ុន្តែវានៅតែជាបញ្ហាចោទ។ សាក្សីរូបនេះដែលគាត់សរសេរអត្ថបទជាច្រើន។ គាត់បានធ្វើដំណើរមកប្រទេសកម្ពុជា ហើយនៅពេលនេះ នៅក្នុងទិវានៅក្នុងឱកាសប្រវត្តិសាស្ត្រនេះ គឺគាត់បែរជាមិនបានមកផ្តល់ភស្តុតាងនៅក្នុងតុលាការ នៅក្នុងស្ថាប័ននេះ។ ខ្ញុំលើកឡើងចំណុចនេះ ដោយសារតែលោកហ្នឹងគាត់លើកឡើងថា គាត់អាចទំនេរឆ្នាំ២០១៣ ក៏ប៉ុន្តែប្រសិនបើចង់ឲ្យខ្ញុំផ្តល់សក្ខីកម្ម គឺសូមពេលវេលាម៉ោងប្រាំបួនទៅដល់ម៉ោងដប់ពីរនៅប្រទេសរបស់ខ្ញុំ។ ខ្ញុំសូមបញ្ជាក់ថា ចំណុចនេះអង្គជំនុំជម្រះគួរតែពិចារណា ទាក់ទងជាមួយនឹងគាត់ សួរគាត់ឲ្យបានច្រើនជាងនេះ ហើយប្រហែលជាសហព្រះរាជអាជ្ញាអាចធ្វើការទាក់ទងជាមួយនឹងលោក ឃៀរនិន ឡើងវិញ ឬក៏ឲ្យតំណាងភាគីទៅកន្លែងនោះតែម្តង ទៅប្រទេសនោះតែម្តងសួរទៅលើ ដេញដោលទៅលើ ឃៀរនិន ហើយថាតើយើងមានកំណត់ហេតុណាផ្សេង ដែលបានកត់ត្រាអំពីការចោទប្រកាន់ដែលខ្ញុំបានលើកឡើងថា មានការដាក់សម្ពាធទៅលើលោក ឃៀរនិន ដែរឬទេ?

[១៦:១០: ៥២]

ខ្ញុំសូមបញ្ជាក់ចុងក្រោយ យើងខ្ញុំមិនចោទប្រកាន់សហព្រះរាជអាជ្ញាថា ធ្វើការងារដោយមិនមានការគោរពវិជ្ជាជីវៈនោះទេ។ ក៏ប៉ុន្តែការធ្វើទំនាក់ទំនងតែភាគីម្ខាង គឺបានធ្វើដោយមិនមានឲ្យជូនដំណឹងទៅដល់ភាគីម្ខាងទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រុមមេធាវីការពារក្ដីផ្សេងទៀត ប្រសិនបើមានបំណងក្នុងលើកឡើងនូវបញ្ហាជំទាស់នេះ។

**លោកស្រី អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអត់មានការអត្ថាធិប្បាយអីទៀតទេ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំក៏អ៊ីចឹងដែរ អត់មានទេ។

[១៦:១១:៣៧]

**លោក គង់ សំអុន៖**

លោកប្រធាន សូមលើកជាសំណូមពរទាក់ទងទៅនឹងបញ្ហានេះ គឺថាយើងខ្ញុំសូមប្រកាន់ជំហរថា សូមឲ្យលោក ប៉ែន ឃៀរនិន អញ្ជើញមកដោយផ្ទាល់នៅក្នុងសវនាការនេះ ដើម្បីឲ្យមេធាវីការពារអាចសួរដេញដោលបាន ដោយសូមឲ្យក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យទៅលើមូលដ្ឋាននៃការដែលលោក ប៉ែន ឃៀរនិន មិនអាចមកចូលរួមនេះបានថាតើគួរឲ្យទទួលយកបានទេ ដោយគ្រាន់តែជាការរវាល់នៅក្នុងវិជ្ជាជីវៈ។

[១៦:១២:១១]

ហើយទីពីរ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យទៅលើឧបសគ្គផ្សេងៗ ដែលអាចកើតឡើងជាយថាហេតុ និងផលវិបាកផ្សេងៗដែលកើតឡើងតាមរយៈការធ្វើ វីដេអូលីង នេះ។ ហើយទីបី បញ្ហាទំនាក់ទំនងជាមួយសាក្សីបែបនេះក្នុងពេលក្រោយទៀត ដូចលោក ម៉ៃខល កាណាវាស ជម្រាបជូនអំមិញឲ្យភាគីបានដឹងផងពីការរីកចម្រើននៃការទំនាក់ទំនងចំពោះសាក្សីនោះ កុំឲ្យភាគីមួយធ្វើការទំនាក់ទំនងទៅ ហើយភាគីដទៃទៀតអត់បានដឹងពីការលួតលាស់នៃទំនាក់ទំនងនោះបាទ។ ហើយម្យ៉ាងទៀត ខ្ញុំសូមឆ្លើយតបទៅនឹងតំណាងសហព្រះរាជអាជ្ញាដែលលើកថា ការធ្វើវីដេអូលីង នេះ ដើម្បីពន្លឿននីតិវិធីសវនាការនោះ ខ្ញុំបាទយល់ឃើញថា វាអាចទទួលយកបានតែក្នុងករណីដែលវាមិនប៉ះពាល់ដល់សិទ្ធិ

របស់អ្នកការពារ។ សិទ្ធិជនជាប់ចោទ ក៏ដូចជាសិទ្ធិការការពារ។

[១៦:១៣:០៨]

បញ្ហានេះ យើងឃើញថាបើសិនជាយើងធ្វើឲ្យលឿន ឲ្យតែបានតែខាងលឿន តែយើងមិនបានគិតពីយុត្តិធម៌ដែលអាចកើតមានឡើង ដូចថាប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទជាដើម ក្នុងការប្រើប្រាស់មធ្យោបាយក្នុងការពារតទល់ជាមួយនឹងសាក្សី។ ដូច្នេះវាអាចធ្វើឲ្យដំណើរការនោះវាលឿនទៅដោយឥតប្រយោជន៍។

បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ សម្រាប់កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃព្រឹកចន្ទទី១៩ ខែមីនា ឆ្នាំ២០១២ នៅក្នុងសប្ដាហ៍ក្រោយ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទបីរូប មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃចន្ទទី១៩ ខែមីនា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៤:១៥ នាទី)*